# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣០ លេខ ៣ ខែមិនា

ព.ស. ២៥០០ គ.ស. ១៩៥៨

– ភ្នំពេញ –

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣០ លេខ ៣ ខែមិនា

ព.ស. ២៥០០ គ.ស. ១៩៥៨

ភ្នំពេញ

# ពិធីទទួលរថយន្តជាព្រះរាជអំណោយសម្តេចព្រះឧបយុវរាជ

កាលពីថ្ងៃព្រហស្បតិ៍ ទី ២៧ កុម្ភៈ ១៩៥៨ ម៉ោង ១៦ និង ៣០ នាទី មានធ្វើពិធីទទួលរថយន្ត ការមិញ៉ូនណែត១ កម្លាំង២សេះ អំពីសម្តេចព្រះឧបយុវរាជ ដែលទ្រង់ព្រះរាជទានដល់សមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃពុទ្ធសាសនិក ។

វរសមណៈ និងវរជន ដែលនិមន្ត អញ្ជើញមកជួបជុំនៅទីនោះ ផ្នែកបព្វជិត សម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្ត ព្រះពោធិវ័ង្សប្រធានពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ព្រះរាជាគណៈឋានានុក្រម, ព្រះថេរានុត្ថេរៈ ផ្នែកគ្រហស្ថ សម្តេចចៅហ្វាវាំងវរវៀងជ័យ ប៉ែន-នុត នាយករដ្ឋមន្ត្រី សមាជិករដ្ឋាភិបាល នាម៉ឺនសព្វមុខមន្ត្រី លោកឃួន-ណៃ ប្រធានសមាគមគិលានសង្គ្រោះ សមាជិកសមាគមនេះ ក្រុមបុគ្គលិកមន្ទីរពេទ្យព្រះសង្ឃជាដើម ។

ម៉ោង ១៧ សម្តេចព្រះឧបយុវរាជទ្រង់ស្តេចយាងដល់ ព្រមទាំងលោកវរសេនីយឯកមាស-ហ៊ុល រាជង្គរក្ស ក្រុមប្រឹក្សាព្រះរាជា ព្រះរាជបរិពារ ។

ក្រោយដែលបានធ្វើគារវកិច្ចចំពោះព្រះសង្ឃ សម្តេចព្រះឧបយុវរាជទ្រង់ថ្លែងព្រះសុន្ទរកថាមួយ រៀបរាប់អំពីហេតុដែលទ្រង់បានរថយន្តនេះពីសមាគមដំឡើងគ្រឿងចក្ររថយន្ត នៅវិថីព្រៃនគរ រថយន្តនេះទ្រង់នឹងធ្វើអំណោយ ចំពោះសមាគមគិលានសង្គ្រោះ សម្រាប់ដឹកនាំព្រះសង្ឃ

☛ (តទៅក្របខាងចុង)

1958_3

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ផ្នែកសាសនា ទំព័រ

- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ ព្រះមហា ជាង-ខាត់ រៀបរៀង . . . . . . ១៩៣
- ផ្លូវ ២ យ៉ាងក្នុងព្រះពុទ្ធសាសនា ព្រះទេពសត្ថា ពិម-តូរ រៀបរៀង . . . . . ១៩៩
- សេចក្ដីពិចារណាទៃពុទ្ធសាសនិកជនម្នាក់ (តមក) លោកភ៉ាប-ប៊ុក រៀបរៀង . . ២០៥

ផ្នែកអក្សរសាស្ត្រ

- រឿងអង្គុដ្ឋកុមារ លោក ឈាង-ហាប់-អាន រៀបរៀង . . . . . . . . . . . ២០៩
- រឿងទេវទត្តរបស់អម្រឹតព្យត្រីម៉ុក (តមក) លោកញ៉ក-ថែម ពិនិត្យ . . . . . . ២២៥
- រឿងសាមកុក (តមក) . . . . . . ឧកញ៉ាទ្វ-កន ប្រែ . . . . . . . ២៣៣
- រឿងព្រេងនិងរឿងប្លកណាទៃប្រទេសជប៉ុន លោក ភ៉ោ-ប៊ុក ប្រែរៀបរៀង . . . ២៤១
- រឿងអ្នកគង្វាលចៀមបិត្តស្ទូតក្រង់និងព្រះរាជធីតា (តមក) លោកផេង-គ្រី រៀបរៀង ២៤៩
- រឿងចៅបាយក្ដាំង (តមក) លោកទៀង-តៃ-ឈុន ប្រែរៀបរៀង . . . . . ២៥៥

ផ្នែកកំណត់និងប្រវត្តិការណ៍

- ពិធីអនុសាវរីយ៍: មហាសន្និបាតលើកទី ១៤ ខែមន្ត្រីសង្ឃ លោក ឯន-ប៉ង់ រៀបរៀង ២៦៧
- មហាសន្និបាតសមាគមមិត្តពុទ្ធិកវិទ្យាល័យ លោក ភ៉ោ-ប៊ុក រៀបរៀង . . . . ២៧៩
- ទេសភាពក្នុងប្រទេសនេបាល់និងរដ្ឋបិង្គ័ល លោក ភ៉ោ-ប៊ុក រៀបរៀង . . . ២៩៥
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហាជាង-ខាត់ រៀបរៀង . . . . . ២៩៨

មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជារ ២៣០/០០

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

## TABLE DES MATIERES

*PARTIE RELIGIEUSE* :


-Histoire du Bouddhisme au Cambodge ( suite ) par Vén. *PANG-KHAT* . . . . . . . . . . . . . . . . . . 193
-Deux devoirs dans le Bouddhisme par Vén. *KEM-TO* . .. 199
-Réflexion d'un Bouddhiste (suite) par *M. RAY-BUC* . . . 205


*PARTIE LITTERAIRE* :


-Histoire du « PETIT POUCET » traduite par *M. LEANG-HAP-AN* . . . . . . . . . . . . . . . . 209
-Histoire de Devanda de *M. MOK* (suite) revue et corrigée par *M. NHOK-THEM* . . . . . . . . . . 225
-Histoire de Samkok (suite) traduite par *M. NOU-KAN* . . . 233
-Conte et Légende du Japon (suite) traduits par *M.RAY-BUC* . . . . . . . . . . . . . . . . . 241
-Le Berger fidèle de la princesse (suite) par *M. PHENG-CHRIV* . . . . . . . . . . . . . . 249
-Légende du « Sieur Croûte de riz » (suite) traduite par *M. TIANG-TAY-CHHUN* . . . . . . . . . . . 255


*NOTES ET CHRONIQUES* :


-Quatorzième réunion annuelle des dignitaires religieux pour l'année 1958 par *M. EN-PANG* . . . . . . 267
-Assemblée Générale de l'Association des Amis du Lycée Bouddhique par *M. RAY-BUC* . . . . . . . 279
-Voyage de Nepal à Bengale par *M. RAY-BUC* . . . . 285
-Dictionnaire Sanskrit-Khmèr (suite) par Vén. *PANG-KHAT* . . . . . . . . . . . 288



Prix d'abonnement annuel ( comprenant 12 numéros ) : 230 r 00

# ផ្នែកសាសនា

## ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ជាំង - ទាត់ រៀបរៀង

( តមក )

| | អតីតនាម | បច្ចុប្បន្ននាម |
|---|---|---|
| ១. ព្រះមជ្ឈន្តិកត្ថេរ | ទៅ កស្មិរៈ គន្ធារៈ | កស្មិរៈ កន្ទារៈ |
| ២. ព្រះមហាទេវត្ថេរ | ទៅ មហិស មណ្ឌល | ខេត្តមៃសោរ ( Mysore) |
| ៣. ព្រះរក្ខិតត្ថេរ | ទៅ វនវាសីប្រទេស | ខាងឧត្តរទិសនៃខេត្តកន្នរៈ ( Kannara) |
| ៤. ព្រះយោនកធម្មរក្ខិតត្ថេរ | ទៅ អបរន្តប្រទេស | ខេត្តគុជរាត ( Gujrat ) |
| ៥. ព្រះមហាធម្មរក្ខិតត្ថេរ | ទៅ មហារដ្ឋ | ខេត្តមរាថ ( ·Marathe ) |
| ៦. ព្រះមហារក្ខិតត្ថេរ | ទៅ យោនកប្រទេស | អាណាចក្រក្រិក ទិសពាយ័ព្យឥណ្ឌា |
| ៧. ព្រះមជ្ឈិមត្ថេរ | ទៅ ហិមវន្តប្រទេស | តំបន់ហិមាល័យខាងឧត្តរទិស |
| ៨. ព្រះមហាមហិន្ទត្ថេរ | ទៅ តម្ពបណ្ណិ | កោះសិរីលង្កា |
| ៩. ព្រះសោណកត្ថេរឧត្តរត្ថេរ | ទៅ សុវណ្ណភូមិ | សុវណ្ណភូមិ (អាស៊ីអាគ្នេយ៍) |

*ដំណើរប្រភពកោះសិរីលង្កា ដែលបានពោលមកនេះ មានសិលា-ចារឹកព្រះរាជប្រកាសនៃព្រះបាទធម្មាសោកមហារាជ ច្រើនកន្លែងទៀត*

ខ្លះនៅក្នុងប្រទេសឥណ្ឌា ខ្លះទៀតនៅក្រៅប្រទេសឥណ្ឌា ដែលទ្រង់ព្រះរាជបញ្ជាឲ្យដំកល់ទុក ក្នុងទីឋាននានា ដែលព្រះអង្គផ្សាយពុទ្ធសាសនាទៅដល់ ៗ

ខ្ញុំដកស្រង់ព្រះរាជប្រកាសទាំងនោះ បំពោះតែគោល ៗ ខ្លះ យកមកទុកក្នុងទីនេះ សម្រាប់ប្រដាប់ការបេះដឹងរបស់យើង ព្រោះប្រកតទាំងនេះ អ្នកប្រាជ្ញទាំងឡាយ តែងអះអាងថាជាសេចក្តីពិត គួរជឿបានដុចតទៅនេះ៖

"ក្រោយរាជាភិសេក ទ្រង់បានធ្វើសង្គ្រាម មានជ័យនៅកលិង្គរដ្ឋ ចាប់ឈ្លើយបាន ១៥០.០០០ នាក់ សម្លាប់ចោលអស់ ១០០ ០០០ នាក់ ស្លាប់ក្នុងសមរភូមិច្រើនអនេកទៅទៀត (ព្រោះតែមានមហន្តរាយនៃសង្គ្រាមនេះហើយ) តមក, ទ្រង់មិនលះបង់ការប្រតិបត្តិធម៌ និងការផ្សាយព្រះធម៌ឡើយ (ព្រះរាជប្រកាសលេខ ១៣) ។ ជ័យព្រះអង្គគឺធម្មវិជ័យ ( ព្រះរាជប្រកាសលេខ ៤ ) ធម្មវិជ័យដែលទ្រង់ឈ្នះក្នុងទីនេះ និងទីឆ្ងាយទៅទៀតដល់ ៦០០ យោជន៍ (ព្រះរាជប្រកាសលេខ ១៣) ។ នៅក្នុងព្រះរាជអាណាចក្រនៃព្រះអង្គ និងប្រទេសជិតខាង ព្រះរាជប្រកាសព្រះអង្គ (ព្រះរាជប្រកាសលេខ ១៣) បានប្រាប់ឈ្មោះទីឋានតទៅនេះគឺ យោនកៈ ឬ យវនៈ, កម្ពោជៈ, បាណ្ឌ្យៈ, ចោលៈ, ចេរៈ, បុលិណ្ឌៈ,

នឹងតាម្ពបណ្ណិ កោះសិរីលង្កា ។ល។ ឆ្ងាយទៅទៀត. ព្រះរាជប្រកាសព្រះអង្គមានប្រាប់នាមព្រះបាទអន្តិយកៈ ឬ អន្តិយោកៈ ព្រះរាជប្រកាសលេខ ២ នឹងព្រះរាជា ៤ អង្គទៀតគឺ តុរមាយៈ ឬ តុរមយៈ ១, ព្រះបាទអន្តិកិនិ ឬ អន្តិកិនៈ ១, ព្រះបាទមគៈ ឬ មកៈ ១, ព្រះបាទអលិកសុន្ទរៈ ឬ អលិកសុទ្ទរៈ ឬ អលិកសន្ទ្រ ១, (ព្រះរាជប្រកាសលេខ ១៣) ឈ្មោះទីឋាននឹងនាមព្រះរាជាទាំងនេះ សរសេរគេប្រែប្លែកៗគ្នាខ្លះ ។ អ្នកប្រាជ្ញបុរាណ បានស្រាវជ្រាវគេឃើញថា :

១- ព្រះបាទអន្តិយកៈនោះគឺ ព្រះបាទអន្តិយោកុស (Antiochus Ier Soter) ២៨០-២៦១ មុនគ្រិស្តសករាជ ឬអន្តិយោកុសទី ២ ( Antiochus II Theos ) ២៦១-២៤៦ មុនគ្រិស្តសករាជ ជាព្រះរាជានៃប្រទេសស៊ីរី (Syrie)

២- ព្រះបាទតុរមេយៈ គឺព្រះបាទប្តូឡេមេ ( Ptoléme Philadelphe ) (២៨៥-២៤៦ មុនគ្រិស្តសករាជ) ជាព្រះរាជានៃប្រទេសអេហ្ស៊ីប

៣- ព្រះបាទអន្តិកិនិ គឺព្រះបាទអន្តិគោន(Autigone)២៧៦-២៣៩ មុនគ្រិស្តសករាជ ជាព្រះរាជានៃប្រទេសក្រិក ម៉ាសេដ្វាន (Macedane)

៤ ព្រះបាទមគៈ គឺព្រះបាទម៉ាគ័ស (Magas) (៣០០-២៥៨ មុនគ្រិស្តសករាជ) ជាព្រះរាជានៃប្រទេសស៊ីរែន (Cyréne) ជាប្រទេស

ចំណុះក្រិក ឋិតនៅខាងលិចប្រទេសអេហ្ស៊ីប ទ្វីបអាហ្វ្រិកា ។

៨ ព្រះបាទអលិកសុន្ទរៈ គឺព្រះបាទអឡេកសង់ដ្រ៍ (Alexandre) (៤៣២-២៩៨ មុនគ្រិស្តសករាជ) ជាព្រះរាជានៃប្រទេសអេពីរ (Epire) ឬអឡេកសង់ដ្រ៍ (២៩២-២៤៤ មុនគ្រិស្តសករាជ) ជាព្រះរាជានៃប្រទេសកូរិន្ទ (Corinthe) ។

កង់ព្រះរាជប្រកាសព្រះបាទធម្មាសោកមហារាជ មិនឃើញមានកត់ត្រាឈ្មោះសុវណ្ណភូមិ ក្នុងព្រះរាជប្រកាសព្រះអង្គ ដូចប្រកតកោះសិរីលង្កាទេ គ្រាន់តែមានសេចក្តីបញ្ជាក់ថា ទ្រង់បានផ្សាយពុទ្ធសាសនាទៅគ្រប់ទិសានុទិស ។ ដោយស្នាព្រះហស្តព្រះអង្គ នឹងព្រះរាជាអង្គខ្លះទៀត ដូចព្រះបាទកនិស្កៈជាដើម ព្រះពុទ្ធសាសនាផ្សាយទៅ ខាងបច្ចិមទិស ដល់រាជអាណាចក្រក្រិក ដល់ទ្វីបអាហ្វ្រិកាភាគឧត្តរ ខាងអាស៊ីភាគកណ្តាល ដល់ប្រទេសចិន, ម៉ុងគោលី, កូរេ, ជប៉ុន, ខាងឧត្តរទិស ដល់ប្រទេសទីបេត៍, ខាងទក្ខិណទិសដល់កោះសិរីលង្កា ហួសឆ្ងាយទៅទៀតដល់សុវណ្ណភូមិ ។

សេចក្តីដូចបានពោលរៀបរាប់មកហើយប៉ុណ្ណេះ យើងជឿជាក់ថា ព្រះសោណកត្ថេរនឹងព្រះឧត្តរត្ថេរ ជាសមណទូតនាំពុទ្ធសាសនា មកដល់សុវណ្ណភូមិកាលពីពុទ្ធសតវត្សទី ៣ ពិតមែនហើយ ដូចសេចក្តីដែល

មានបែងទុក ក្នុងប្រកពកោះសិរីលង្កាស្រាប់ តែពីបាកនឹងកំណត់ឲ្យទៀងទាត់ថា ដែនដីបន្ទោះប្រទេសឥណ្ឌា នឹងប្រទេសចិននេះ ចំហាងត្រង់ណាជាសុវណ្ណភូមិ ដែលព្រះថេរ. ទាំងពីរអង្គ មកតាំងមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនានុះ? នឹងថា នៅប្រទេសភូមា ក៏នៅមានការជជែកគ្នា នឹងថា នៅប្រទេសសៀម ក៏មិនសមហេតុផលគ្រប់គ្រាន់ ឬ នឹងថា នៅប្រទេសណា ក៏មិនប្រាកដដែរ ព្រោះជាហេតុការណ៍ ដែលមានមកមុនប្រវត្តិកាលនៃប្រទេសទាំងឡាយ ដែលមានក្នុងភូមិភាគនេះទាំងអស់ទៅទៀត ។ បណ្ដាប្រទេសទាំងឡាយ ដែលកាន់ពុទ្ធសាសនាថេរវាទ នៅក្នុងភូមិភាគនេះទាំងអស់ ប្រទេសនីមួយ ៗ ក៏បានទុករឿងព្រះថេរៈទាំងពីរអង្គ នឹងសុវណ្ណភូមិនេះ ជាប្រវៃតណីបុរាណ របស់ប្រទេសរៀងខ្លួន ហើយអះអាងគ្រប់គ្នាថា តាំងនៅក្នុងដែនដីតែរៀងខ្លួនទៀត ដូចសេចក្ដីដែលលោក ប៉ ឌុយប៉ុង សរសេរថា ៖

"ប្រវៃតណីប្រទេសភូមានឹងសិលាចារឹក ពីគ្រិស្តសតវត្សទី ១៥ បានពោលអះអាងថា ព្រះបាទធម្មាសោកមហារាជ បានបញ្ជូនសមណទូតមកកាន់ប្រទេសភូមា ៣ លើក ពីពុទ្ធសតវត្សទី ៣ តែបំនួននឹងនាមសមណទូតមានតែពីរអង្គ ដូចប្រកពកោះសិរីលង្កាដែរ ។ ឯប្រវត្តិដែលនិយាយពីព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរ និមន្តមកកាន់សុវណ្ណភូមិនេះ

ប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទ នៅអាស៊ីភាគអាគ្នេយ៍ បានដឹងទាំងអស់គ្នាជាអាទិ៍ ដូចប្រទេសសៀម ហ៊ានទាំងពោលថា ប្រវត្តិសោណ-កត្ថេរនិងឧត្តរត្ថេរនេះជាប្រវត្តិប្រទេសរបស់ខ្លួន ហើយតាំងនៅក្នុងប្រទេសខ្លួនថែមទៀតផង៖ រឿងរ៉ាវព្រះសោណកត្ថេរនិងព្រះឧត្តរត្ថេរ ទាំងពីរអង្គនេះ មានកាលបរិច្ឆេទទំនងជាមិនពិតត្រឹមត្រូវទេ តែគេរក្សាទុកថាជាប្រពៃណីសមណទូតនៃពុទ្ធសាសនា ដែលមានមកដល់ឥណ្ឌូចិនបច្ចិមទិសភាគ តាំងពីបុរាណកាល ” ។

រឿងរ៉ាវសុវណ្ណភូមិ ជារឿងដែលយើងគួរតែចង់ចេះដឹងណាស់ហើយ យើងគប្បីតែស្រាវជ្រាវរកឲ្យឃើញ សម្រាប់ប្រជាប់ការចេះដឹង ព្រោះជារឿងដែលទាក់ទងនឹងប្រទេសយើងដោយចំពោះ ។

តទៅ, ខ្ញុំសូមឱកាសរៀបរាប់ ពីដំណើរដើមទងសុវណ្ណភូមិបន្តិចសិន សម្រាប់ប្រជាប់នៃការចេះដឹងរបស់យើង សឹមនិយាយពីព្រះពុទ្ធសាសនា ដែលចូលមកកាន់ប្រទេសខ្មែរយើងជាលំដាប់ ព្រោះថាការចេះដឹងរឿងសុវណ្ណភូមិសព្វគ្រប់ ជាហេតុនាំឲ្យយើង យល់ប្រស្នាព្រះពុទ្ធសាសនា ដែលមកប្រតិស្ឋាននៅប្រទេសយើងដោយបរិបូណ៌ ។

ដើមទងដែលនាំឲ្យជនជាតិឥណ្ឌាមកកាន់សុវណ្ណភូមិ ក្នុងកាលនោះ

(មានត)

# ធុរៈក្នុងព្រះពុទ្ធសាសនា ២ យ៉ាង

ព្រះទេពសត្ថា កែម-គួរ រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យ គឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដោយសេចក្ដីគោរព ។

វេលានេះ អាត្មាភាពសូមសំដែងអំពីធុរៈព្រះពុទ្ធសាសនា ២ យ៉ាង តាមសេចក្ដីនិមន្តរបស់លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។ មុននឹងសំដែងធម៌នេះ អាត្មាភាពសូមពណ៌នាអំពីជំនឿរបស់មនុស្សទូទៅ ដែលមានសេចក្ដីប្រកាន់ខ្ជាប់ទៅលើសាសនានីមួយៗ និងកំណើតព្រះពុទ្ធសាសនាដូចមានសេចក្ដីបរិយាយ ដោយសង្ខេបតទៅនេះ :

ធម្មតាមនុស្សក្នុងលោក តាមតែសញ្ជាតិណាក៏ដោយ សុទ្ធសឹងតែមានជំនឿទៅក្នុងអ្វីមួយ បើមិនច្រើនក៏តិចដែរ ដែលខ្លួនយល់ឃើញថា ជាវត្ថុស័ក្ដិសិទ្ធិគួរពឹងពាក់ពំនាក់អាស្រ័យ គួរគោរពបូជា ពុំសូវមាននៅទោលតែឯកឯងឥតទីពឹងឡើយ ។ ឯវត្ថុស័ក្ដិសិទ្ធិទាំងនោះគេច្រើននិយមយកលទ្ធិដែលជាប់វេណីរបស់បុព្វបុរសសម្រាប់ជាតិនីមួយៗ ដែលធ្លាប់ប្រព្រឹត្តប្រតិបត្តិកាន់ជាប់តៗគ្នាមកកំណត់ហៅថា សាសនា ។

សាសនានោះសោតទៀត មានរបៀបរបបផ្សេងៗពីគ្នា តាមមតិរបស់សាស្តាចារ្យនីមួយៗប្រឌិតបង្កើតឡើងមានឡើង ដើម្បីនឹងឲ្យបរិស័ទចុះចូលជឿស្តាប់គោរពតាមគានដូចយើងបានឃើញ បានឮមកហើយដែលមាននៅក្នុងលោកនេះ ។

បណ្តាសាសនាទាំងអស់ក្នុងលោក មានតែព្រះពុទ្ធសាសនាមួយទេ ដែលជាសាសនាមានសារៈសំខាន់បណ្តាច់ជាងសាសនាឯទៀត ។ ទាំងអស់ ព្រោះជាសាសនាអាចធ្វើមនុស្សគ្រប់ឋានៈជាអ្នកប្រតិបត្តិតាមឲ្យមានសន្តិភាព មេត្រីភាពនិងសេរីភាព ទូទៅក្នុងលោក រហូតដល់ព្រះនិព្វានជាទីបំផុត ។ កំណើតនៃព្រះពុទ្ធសាសនានេះគឺ មហាបុរសយ៉ាងឆ្នើមមួយរូប ជាអ្នកមានវិចារណញ្ញាណយ៉ាងជ្រាលជ្រៅ បានរកឃើញសេចក្តីប្រតិបត្តិដែលមានខ្លឹមសារវិសេស អាចធ្វើមនុស្សលោកគ្រប់ឋានៈ ដែលជឿហើយប្រតិបត្តិតាម ឲ្យដល់នូវទីបំផុតទុក្ខបាន បានទាំងប្រកាសផ្សាយទុកមានជាប់មកដល់សព្វថ្ងៃនេះ ឯមហាបុរសនោះគឺ ព្រះសម្មាសម្ពុទ្ធរបស់យើងហ្នឹងឯង ។ ដំណើរដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ស្វែងរកសេចក្តីប្រតិបត្តិដែលមានខ្លឹមសារនោះ ពុំមែនទើបនឹងស្វែងរកក្នុងជាតិមួយជាទីបំផុតនេះទេ គឺទ្រង់ស្វែងរកអស់កាលជាច្រើនជាតិណាស់ ដូចមានប្រវត្តិដែលអ្នកប្រាជ្ញទាំងឡាយ បានចារឹកទុកក្នុងគម្ពីរជាច្រើន មាន

គម្ពីរបឋមសម្ពោធជាដើម ដែលមានសេចក្ដីដំណាលថា កាលដែលព្រះសម្ពុទ្ធបរមគ្រូរបស់យើង នៅក្នុងឋានៈជាពោធិសត្វនៅឡើយនោះ មានឈ្មោះថា សុមេធបណ្ឌិត បានបំពេញបារមីធម៌ទាំងឡាយមានទានបារមីជាដើម អំណើះកាលអំពីនោះមក សូម្បីព្រះអង្គកើតជាជាតិអ្វីក៏ដោយ ទោះជាតិជាមនុស្សក្ដី ជាតិជាអមនុស្ស មានទេវតាជាដើមក្ដី ជាតិជាតិរច្ឆានក្ដី សុទ្ធតែបានបំពេញបារមីធម៌គ្រប់ៗជាតិ ដើម្បីស្វែងរកមោក្ខធម៌ តម្រាំងហូតដល់បច្ឆិមជាតិ ( ជាតិជាទីបំផុត ) ដែលមានឈ្មោះថា សិទ្ធត្ថកុមារ អស់រយៈកាលគំរប់ ៤ អសង្ខេយ្យ ១សែនកប្ប នៅតែមិនទាន់ជួបប្រទះនឹងខ្លឹមរបស់សេចក្ដីប្រតិបត្តិគឺមោក្ខធម៌នៅឡើយ ។

លុះព្រះបរមពោធិសត្វលះរាជសម្បត្តិ ហើយចេញទ្រង់ព្រះផ្នួសស្វែងរកមោក្ខធម៌ មិនយូរប៉ុន្មានក៏បានឃើញជាក់ច្បាស់នូវមោក្ខធម៌គឺ សព្វញ្ញុតញ្ញាណ ដែលមានខ្លឹមសារដោយប្រាជ្ញាញាណរបស់ព្រះអង្គឥតមានទើសទាក់ ឬក៏ប៉ាំងនឹងអ្វីឡើយ ហាក់ដូចជាគេត្រាលពន្លឺភ្លើងទៅក្នុងទីងងឹត ដែលយើងហៅថា ព្រះអង្គត្រាស់ដឹង ទ្រង់គង់លើរតនបល្ល័ង្ក ក្រោមពោធិព្រឹក្សមានឈ្មោះថា ព្រះពុទ្ធ ។

ចាប់ដើមពីត្រឹមនោះមក ព្រះពុទ្ធជាម្ចាស់ ទ្រង់ទេសនាប្រកាស

ផ្សាយឱវាទានុសាសនធម៌គឺពាក្យប្រៀនប្រដៅដ៏មានខ្លឹមសារដែលព្រះអង្គបានត្រាស់ដឹងនោះឯង ដល់សត្វនិករទូទៅក្នុងត្រៃលោក ។

ឱវាទានុសាសនធម៌ដែលព្រះអង្គទ្រង់សំដែងប្រោសសព្វសត្វអស់រយៈកាល ៤៥ ឆ្នាំ ពីត្រឹមឆ្នាំដែលបានត្រាស់ទៅដល់ឆ្នាំដែលបរិនិព្វាននោះ គឺទ្រង់សំដែងតែក្នុងឱវាទ ៣ យ៉ាងគឺ ១ - សព្វបាបស្ស អករណំ ការមិនធ្វើអំពើអាក្រក់ទាំងពួងដោយកាយ វាចា ចិត្ត ឱវាទនេះចាត់ទៅជាវិន័យ ហៅថា វិនយបិដក. ២ - កុសលស្សូបសម្បទា ការបំពេញកុសលផ្សេងៗ ដោយកាយ វាចា ចិត្ត ឱវាទនេះចាត់ទៅជាព្រះសូត្រ ហៅថា សុត្តន្តបិដក. ៣ - សចិត្តបរិយោទបនំ ការធ្វើចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់ចាកកិលេសមានលោភៈ ទោសៈ ជាដើម ឱវាទនេះចាត់ទៅជាអភិធម្ម ហៅថា អភិធម្មបិដក; ឱវាទទាំង ៣ យ៉ាងនេះឯង ជាគោលនៃព្រះពុទ្ធសាសនា ។

ព្រះពុទ្ធសាសនា បើចាត់ទៅជាធុរៈ ដែលពុទ្ធសាសនិកត្រូវបំពេញមាន ២ យ៉ាងគឺ គន្ថធុរៈ ១ វិបស្សនាធុរៈ ១ ។ ការតាំងព្យាយាមដ៏មុតមាំខំសិក្សានូវពុទ្ធវចនៈ គឺព្រះត្រៃបិដកតាមកម្លាំងសតិបញ្ញា និងសមត្ថភាពរបស់ខ្លួន បានរៀនចាំស្ទាត់គ្រប់បិដកទាំង ៣ ក្តី ត្រឹមតែបិដកមួយក្តី ឬត្រឹមតែនិកាយមួយក្តី ឬក៏ដោយហោចទៅត្រឹមតែពុទ្ធវចនៈបទណាមួយ

ក្តី ហើយអាចបង្ហាត់បង្រៀនគេកើត អាចសំដែងណែនាំពន្យល់គេកើត ហើយមានសេចក្តីប្រតិបត្តិត្រឹមត្រង់តាមពុទ្ធវចនៈនោះៗ មិនឲ្យឃ្លៀងឃ្លាតផង ហៅថា គន្ថធុរៈ ។

ការសិក្សារៀនសូត្របានចេះចាំពុទ្ធវចនៈបទណាមួយ ឲ្យស្ទាត់ប្រាកដហើយបានធ្វើខ្លួនឲ្យស្រាលគឺបើខាងគ្រហស្ថ លះយកវាសកិច្ច ( ការរវល់គ្រប់គ្រងផ្ទះ ) ចេញ. បើខាងបព្វជិត លះពលិពោធ ( ការកង្វល់ផ្សេងៗ ) មានការរវល់ក្នុងអាវាស ឬការគ្រប់គ្រងពួកក្រុមជាដើមចេញតាមពេលដែលគួរលះបាន ហើយរកទីសេនាសនៈដ៏ស្ងប់ស្ងាត់លើកអាវុធគឺបញ្ញាឡើង ពិចារណាឃើញច្បាស់នូវទោសរបស់សង្ខារធម៌ទាំងខាងក្នុងទាំងខាងក្រៅ ដែលជាសភាវៈនាំឲ្យកើតឡើង ទាំងនាំឲ្យវិនាសសាបសូន្យទៅវិញ ចំពោះអត្តភាពរបស់ខ្លួន ឬចំពោះអត្តភាពមនុស្សសត្វដទៃឲ្យឃើញថា សុទ្ធតែលុះនៅក្នុងអំណាចត្រៃលក្ខណ៍ដូចគ្នាទាំងអស់ ការនឹករំពឹងពិចារណារឿយៗ ដកបទាល់តែចិត្តនឿយណាយធុញទ្រាន់ចំពោះសត្វនឹងសង្ខារទាំងអស់ បើឧបនិស្ស័យមានមកពីបុព្វជាតិចាស់ក្លាជាជំនួយខ្លះផង ក៏បានលុះនូវគុណធម៌ជាន់ខ្ពស់មានសោតាបត្តិផលជាដើម បើពុំដូច្នោះទេ គង់នឹងបានជាឧបនិស្ស័យក្នុងបច្ចុប្បន្ននឹងអនាគតទៀតពុំខាន សេចក្តីពណ៌នាមកដោយសង្ខេបប៉ុណ្ណេះ ហៅថា វិបស្សនាធុរៈ ។

ធុរៈទាំងពីរយ៉ាងដូចបានពណ៌នាមកហើយនេះ ជាសេចក្ដីសង្ខេបខ្លីពេក បើអស់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយ ចង់ជ្រាបសេចក្ដីច្បាស់លាស់ជាងនេះ សូមមើលព្រះត្រៃបិដក ដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពចេញខ្លះហើយនោះ ទើបឃើញសេចក្ដីពិស្ដារទូលំទូលាយល្អណាស់ ដែលយើងហៅថា ព្រះត្រៃបិដកៗជាឈ្មោះគោលដើមរបស់គម្ពីរទាំងឡាយ ។ ព្រះត្រៃបិដកចែកចេញជា ៣ គឺ វិនយបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ ។

ពុទ្ធឱវាទដែលមានសេចក្ដីបញ្ញត្តិ និងអនុញ្ញាតមិនឲ្យបុគ្គលប្រព្រឹត្តល្មើសតាមអំពើចិត្ត ហៅថា វិន័យ បើបែកខាងបព្វជិត ហៅថា អនាគារិយវិន័យ បើខាងគ្រហស្ថហៅថា អាគារិយវិន័យ មាន ឈ្មោះ ៥ គម្ពីរគឺ មហាវិភង្គ ឬ ភិក្ខុវិភង្គ ១ ភិក្ខុនីវិភង្គ ១ មហាវគ្គ ១ ចុល្លវគ្គ ១ បរិវារៈ ១ បើរាប់ទៅជាពួកក្រុមឬជាគន្ថដែលកំណត់ដោយធម្មក្ខន្ធនោះ មាន ២ ហ្មឺន ១ ពាន់ធម្មក្ខន្ធ ហៅថា វិនយបិដកៗនេះ មានចំនួន ១៣ សៀវភៅ ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពចប់ផ្សាយចេញតាំងពីពុទ្ធសករាជ ២៤៧៩ គ.ស. ១៩៣៦ តាំងពីឆ្នាំនោះរហូតមកដល់ឥឡូវនេះ បានសើរើបោះពុម្ពបន្ថែមតាំងពីភាគ ១ ភាគ ២ ជាលំដាប់មកទៀត ដើម្បីបំពេញសេចក្ដីត្រូវការរបស់លោក អ្នកពុទ្ធបរិស័ទកុំឲ្យខ្វះខាត ។

(មានត)

# សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់

## លោក វ៉ាយ-ប៊ុក រៀបរៀង

(តមក)

ដោយហេតុនេះបានជាតាំងពីព.ស.៤.២០០ឆ្នាំមកហើយ ពួកលទ្ធិពុទ្ធសាសនាខាងថេរវាទគឺផ្នែកខាងត្បូង, មិនដែលមានការទទួលបំបួសភិក្ខុនីសោះឡើយ ។ បើតាមគម្ពីរ "ទីបវំស" ប្រវត្តិការណ៍ប្រទេសសីឡុង, គេមានឃើញភិក្ខុនីដែលបាននិមន្តទៅរួបរួមក្នុងពិធីបុណ្យដែលព្រះបាទអសោកបានធ្វើក្នុងព្រះពុទ្ធសាសនា តែខាងក្រោយមក, គេមិនដែលឮពោលអំពីភិក្ខុនីសង្ឃនេះសោះ; ព្រះភិក្ខុនីសង្ឃក៏លែងមានតាំងពីឆ្នាំនោះមក ។

បើដូច្នេះ តើនឹងមានភិក្ខុនីសង្ឃពីណាមក? បើគ្មានភិក្ខុនីសង្ឃតើបានភិក្ខុនីណាធ្វើជាឧបជ្ឈាយ៍ កម្មវាចាគ្រូសូត្របាន ។ នេះហើយហេតុរឿងរ៉ាវផ្សេងៗ ដែលនាំឲ្យបាត់ភិក្ខុនីសង្ឃ ។

សួរ តើភិក្ខុនីដែលបួសក្នុងពេលដែលព្រះអង្គគង់ធរមាននៅតែនាងណាខ្លះ? ឆ្លើយ ស្ត្រីដែលបួសជាបឋមគឺ ព្រះនាងប្រជាបតិគោតមីជាម្ដាយមីង (ព្រះបិតុច្ឆា) របស់ព្រះអង្គ, ព្រះនាងយសោធរាជាមាតារាហុលកុមារ,

ជាព្រះអគ្គមហេសីរបស់ព្រះអង្គ, ស្ត្រីជាញាតិសាលោហិតរបស់ព្រះអង្គ ។

បើតាមគម្ពីរ "ថេរីគាថា" មានភិក្ខុនីមួយរូបឈ្មោះនាងខេមាជាអតីតអគ្គមហេសីព្រះបាទពិម្ពិសារ នេះបានបួស ជាលំដាប់តមកជាមួយនឹងនាងវិមលា ដែលជាស្ត្រីផ្កាមាស, ឥឡូវ នាងគោរសក់, គ្រងចីវរស្បង់លឿង, និមន្តទៅទ្រង់ បិណ្ឌបាត ។ ក្រៅពីនេះនៅមានស្ត្រីនៃពួកសេដ្ឋី, គហបតី កដុម្ពីក បានលះបង់គ្រួសារ ទៅបួសជាច្រើនដែរ ។ តែតាំងពីព្រះបរមគ្រូទ្រង់ចូលកាន់បរិនិព្វាន ចំនួនព្រះភិក្ខុនីកាន់តែថយចុះតាមលំដាប់រហូតដល់ព្រះពុទ្ធសាសនាយូរកាលបាន ១០០០ ឆ្នាំ ស្រាប់តែគ្មានស្ត្រីបួសសោះ ។ កាលព្រះអង្គចូលបរិនិព្វានគេបានបន្ទោសព្រះអានន្ទត្រូវម្តេចក៏អនុញ្ញាតឲ្យស្ត្រី មកខ្ញែសោកលើព្រះបរមសពព្រះអង្គដែលនាំឲ្យមានមន្ទិលសៅហ្មង ។

សួរ· ដែលព្រះអង្គទ្រង់បញ្ញត្តិគីនរឹងចំពោះព្រះភិក្ខុនីដូច្នេះ តើព្រះអង្គទ្រង់ស្អប់ពួកស្ត្រី ឬព្រះអង្គទ្រង់មានព្រះរាជបំណងចង់តម្កើងភេទបុរសឲ្យខ្ពស់ជាងភេទស្ត្រីឬព្រះអង្គទ្រង់ប្រមាថមើលងាយភេទស្ត្រី?

ឆ្លើយ· មិនមែនដូច្នោះទេ ព្រះសម្មាសម្ពុទ្ធទ្រង់បានសម្រេចសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន, ទ្រង់គ្មានកិលេស, តណ្ហា, អវិជ្ជា, ទ្រង់មិនអាចប្រព្រឹត្តបាបអកុសលទៅបាន ទ្រង់គ្មានបុណ្យ,

គ្មានបាប, ទ្រង់បរិសុទ្ធស្អាតទៅហើយ ៗ ម្យ៉ាងវិញទៀត, ព្រះអង្គទ្រង់បាន ធ្វើព្រះរាជសមាសេនឹងព្រះនាងយសោធរា ឬព្រះនាងពិម្ពា, ជាមាតារាហុល កុមារផងដែរទៀត ៗ ទ្រង់បានទទួលនិមន្តទៅឆាន់ នៅគេហដ្ឋាននាង អម្ពបាលីជាស្ត្រីផ្កាមាស, ស្ត្រីរបាំជានាងនាដការបេះប្រៀនពីពេះថែមទៀត; អម្ពបាលីបានស្តាប់ព្រះអង្គទេសនាក៏បានកើតធម្មចក្ខុ សុំចូលជាឧបាសិកា ក្នុងព្រះពុទ្ធសាសនា; លំដាប់តមក, នាងបានបួសជាភិក្ខុនី ហើយបាន ចម្រើនមេត្តាភាវនា ក៏បានសម្រេច អរហត្តផល ជាអរិយបុគ្គល ៗ ម្យ៉ាងទៀត, ដូចនាងធម្មទិន្នា ជាភរិយាវិសាខឧបាសក បានលះបង់ គ្រួសារទៅបួសជាភិក្ខុនី ក៏បានសម្រេច អរហត្តផល ចំណែកឯនាងវិសាខា ជាមហាឧបាសិកាក៏និមន្តព្រះអង្គព្រមទាំងព្រះភិក្ខុសង្ឃ ឆាន់មិនដែល ដាច់ ៗ ឧទាហរណ៍ ខាងលើនេះសឲ្យឃើញថាព្រះអង្គទ្រង់មិនមែន ប្រមាថមើលងាយភេទស្ត្រីសោះឡើយ ៗ

ក្រៅពីនេះនៅមានស្ត្រីជាច្រើនដែលបានបួសជាភិក្ខុនីចូលមកកាន់ ព្រះពុទ្ធសាសនាឬចូលមកជាឧបាសិកាឬបួសជាសិក្ខមានាជាសីលវតី, ជា យាយជី ៗ

សួរ· ស្ត្រីដែលកសាងក្រៅពីភិក្ខុនី តើមានប្រភេទប៉ុន្មានយ៉ាង ?

ឆ្លើយ ស្ត្រីដែលកសាងក្រៅពីភិក្ខុនីគឺស្ត្រីអាចនឹងមានចិត្តប្រាថ្នា:

១-ជាកន្សៀសារពេជ្ជ ;

២-ជាពុទ្ធមាតា ;

៣-ជាមហាឧបាសិកា ;

៤-ជាស្រីកែវស្តេចចក្រពត្រាធិរាជ ;

៥-ជាស្រីទេពអប្សរបរិកញ្ញា ;

៦ ជាអគ្គមហេសីព្រះមហាក្សត្រិយ៍,

៧-ជាពជជននី ;

៨-ជាព្រះអង្គម្ចាស់ក្សត្រី

៩-ជានារីរត្ន ;

សួរ• តើព្រះសិទ្ធត្ថកុមារមានអគ្គមហេសីប៉ុន្មានរូប ? ។

ឆ្លើយ• ព្រះសិទ្ធត្ថកុមារមានអគ្គមហេសី ៣ រូបគឺ: ១ ព្រះនាងម្រគជា, ២ ព្រះនាងគោបិកា. ៣- ព្រះនាងយសោធរា ។ ព្រះនាងយសោធរាទ្រង់ជាអគ្គមហេសី, ឯព្រះនាងម្រគជា និង ព្រះនាងគោបិកាជាមហេសី ។

បើតាមគម្ពីរព្រះពុទ្ធសាសនាប្រទេសចិននាម "ប៉ូសេងចេ" ព្រះវិន័យនៃគណៈមូលាសិជាស្តិវាទិន, មានទិទានរៀងដូចខាងក្រោម :

(មានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងអង្គុដ្ឋកុមារ

លោក ឈាង ហាប់-អាន សាស្ត្រាចារ្យ

ពុទ្ធិកវិទ្យាល័យព្រះសុរាមរិត រៀបរៀង

---

កាលណោះ មានអ្នកតាប់១សប្តីប្រពន្ធ មានកូន ៧ នាក់ ។ កូនច្បងមានអាយុ ១០ ឆ្នាំ ។ ឯកូនពៅទើបនឹងបានអាយុ ៧ ឆ្នាំ ។

មាតាបិតា មានសេចក្តីក្រលំបាកជាអនេក, ហើយកូនទាំង ៧ នាក់ដែលនៅក្នុងវ័យ កំពុងស្រេកឃ្លាន តែងទារចំណីជាប្រក្រតី ។ មាតាបិតាមានមនោសញ្ចេតនាស្នេហាកូនពៅជាងគេ ដោយកូនពៅនោះមានគំនិតស្លូតបូតហើយចេះអត់ធន់ ពុំមានយំស្រែកដល់បន្តិចបន្តួចឡើយ ។ កុមារនេះមានកាយតូចពេកណាស់ ។ កាលដែលទើបនឹងកើតភ្លាមមកនោះ មានទំហំប្រមាណប៉ុនមេដៃប៉ុណ្ណោះ ទើបគេសន្មតឲ្យឈ្មោះថាអង្គុដ្ឋកុមារ ។

អង្គុដ្ឋកុមារធ្វើកិច្ចការក្នុងផ្ទះផងគេ ប៉ុន្តែពុំសូវគាប់ចិត្តដល់អ្នកទាំងអស់ឡើយ ៗ កុមារនេះមានប្រាជ្ញាវៃឆ្លាតជាងបងៗទាំងអស់ ហើយមានសមត្ថភាពជាអ្នកពុំសូវមាត់ក ហើយជាអ្នកស្តាប់ការណ៍យ៉ាងមធ្យ័តៗ

ឆ្នាំមួយជាឆ្នាំអត់ឃ្លានដ៏ក្រៃលែង បុរសប្តីប្រពន្ធបានពិគ្រោះគ្នាថា នឹងយកកូនទៅប្រោសចោល ៗ នៅពេលល្ងាចមួយនោះ កូនទាំងអស់ក៏ដេកលក់ស្កប់ស្កល់ ៗ បុរសប្តីប្រពន្ធនាំគ្នាទៅអង្គុយ នៅជិតគប់ភ្លើង ពិភាក្សាយ៉ាងអាណោចអធម៌ ៗ បុរសប្តីនិយាយថា " ខណៈនេះយើងពុំអាចនឹងរកស៊ីចិញ្ចឹមកូនទាំងអស់ ឲ្យរស់ជីវិតបានឡើយ យើងមុខជានឹងដាច់ពោះស្លាប់ជាពុំខាន គួរណាស់តែយើងនាំកូនទាំងអស់ យកទៅប្រោសចោលក្នុងព្រៃ នៅវេលាស្អែកនេះ ដោយយើងនាំវាឲ្យទៅជាមួយ ហើយក្នុងពេលដែលទុកវាឲ្យនៅបងទស យើងនឹងនាំគ្នារត់ចោលមកវិញ"ៗ ញ័រទ្រូងនាងភរិយាតបថា " ឱ អ្នកអើយ! អ្នកអាចកាត់សេចក្តីមេត្តាបានដែរឬ? " ៗ ប្តីបាននិយាយអង្វរភរិយាជាច្រើនដង ៗ ពិតមែនតែនាងឃើញថាទាល់ក្រលំបាកហើយ ប៉ុន្តែ ឋានៈនាងជាម្តាយ ពុំអាចដាច់ចិត្តយកកូនទៅប្រោសចោលឡើយ ៗ

តមក នាងបាននឹកគិតអំពីសេចក្តីអត់ឃ្លាន ដែលបានសន្ធឹតសង្កិនជាទម្ងន់ នាងឃើញពិតថា នឹងរកចិញ្ចឹមកូនពុំបានឡើយ ទើបនាងដាច់ចិត្ត

ធ្វើតាមប្ដី នាងក៏ទៅដេកបារម្ភទ្រហោយំអាសូរកូនទៅតូចៗរញ៉ីៗ

ទៅអង្គុដ្ឋកុមារ បានឮពាក្យទោទារបស់បិតាមាតាទាំងអស់ ដោយ កុមារលបចុះពីលើគ្រែខ្លួន ទៅឈរស្ដាប់នៅកៀនស្បែកជើងឪពុក ដោយ ពុំបានធ្វើឲ្យអ្នកណាឃើញសោះ ៗ កុមារត្រឡប់មកកន្លែងវិញ ដោយ រិះគិតរកឧបាយអស់មួយរាត្រីធំ ៗ កុមារក្រោកពីដំណេកហើយលបរត់ទៅ មាត់ស្ទឹងរើសដុំក្រួសតូច ១ ដាក់ពេញថែបទន្សេងមកផ្ទះវិញ ៗ

ព្រឹកព្រាងព្រះសុរិយា ឪពុកម្ដាយនាំកូនចេញទៅក្រោសចោល ៗ អង្គុដ្ឋកុមារ ដឹងគិតទាំងអស់ ប៉ុន្តែ ពុំមានប្រាប់ឲ្យបង ១ ដឹងឡើយ ៗ អ្នកទាំងអស់គ្នាចូលទៅក្នុងព្រៃព្រឹក្សមួយយ៉ាងធំ ៗ បុរសឪពុកតាំងធ្វើជា កាប់ទសយ៉ាងញាប់ដៃ ហើយតាត់ឲ្យកូនតូច ១ ប្រមូលទសបងជាបាច់ ១ៗ មាតាបិតាឃើញកូនកំពុងធ្វើការងារ ក្មេចស្មារតីនិងបងទស ក៏លបរត់ចេញ យ៉ាងរហ័ស បត់តាមផ្លូវខ្វង់រត់បាត់ទៅ ៗ

លុះកុមារទាំងអស់ឃើញបាត់ឪពុកម្ដាយ ក៏នាំគ្នាស្រែកយំយ៉ាងទ្រហឹង អឺងកងពេញព្រៃ ៗ កុមារអង្គុយនៅស្ងៀម ដោយខ្លួនស្គាល់ផ្លូវច្បាស់នឹង ត្រឡប់ទៅវិញ ពីព្រោះកាលដែលមកនោះ កុមារបានលួចទំលាក់ក្រួសបំ- ណាំចប់រហូតមក ៗ កុមារឆ្លើយទៅបង ១ ថា " សូមបងទាំងអស់កុំភ័យ ឪពុកអ្នកម៉ែទុកយើងទៅទីនេះ ប៉ុន្តែ មកតាមខ្ញុំៗ នឹងនាំឲ្យដល់ផ្ទះវិញ,, ៗ

កុមារនាំបង ៗ ដើរតាមផ្លូវដើមរហូតទាល់តែដល់មកផ្ទះវិញ ។ ដល់ហើយ កុមារទាំងអស់ពុំហ៊ានចូលទៅក្នុងផ្ទះឡើយ ហើយនាំគ្នាឈរតំរៀបនៅមាត់ទ្វារ ដើម្បីចាំស្តាប់ការពិភាក្សារបស់ម្តាយឪពុក ។

ក្នុងពេលបុរសប្តីប្រពន្ធត្រឡប់មកដល់ផ្ទះវិញនោះ លោកសេដ្ឋីបានបើកប្រាក់ខែឲ្យ ១០ រៀល ព្រោះលោកទើបនឹងនឹកឃើញ ។ បុរសប្តីអរណាស់ដោយបានសោហ៊ុយ នឹងទិញអាហារចំអែតពោះ ។ ប្តីក៏ប្រើភរិយាឲ្យទៅកន្លែងសម្លាប់សត្វ ។ ដោយពុំដែលបានស្គាល់ជាតិរស់សាច់ម្តងសោះជាអង្វែងមក នាងភរិយាក៏ទិញសាច់មួយដុំធំល្មមនឹងទាំងពីរអាស្រ័យបានបីដង ។ ក្នុងពេលដែលអ្នកទាំងពីរ បង្គុំគ្នាបរិភោគ នាងភរិយានឹករំពៃព្រួយទៅកូន ហើយនិយាយថា “ ឱ អនិច្ចា កូនយើងឃ្លាតទៅណាអស់ហើយ បានជាពេលនេះនៅតែយើងពីរនាក់យ៉ាងនេះ ! អ្នកប្រុសថ្លៃអើយ អ្នកនេះហើយដែលកាត់អាល័យ យកកូនទៅបំបរបង់នោះ ! ឱកូនមាសម្តាយទាំងអស់អើយ តើអ្នកខ្លាចផ្សាក្នុងព្រៃយ៉ាងណាទៅ ឱព្រះម្ចាស់ថ្លៃអើយ ឬមួយចចកខ្លាប្រហារជីវិត ជាចំណីអស់ទៅហើយ អ្នកប្រុសអើយ អ្នកគ្មានមេត្តាសោះ ។

បុរសប្តី លុះឮពាក្យសង្រេងរបស់ភរិយា ក៏នឹកខ្លាចចិត្តមួយរំពេច មុខដោតទៅដោយទឹកភ្នែក ។ ប៉ុន្តែ ដោយភរិយានិយាយបន្ទោសប្រំ

ដែលញយ ៗ បុរសប្តីអត់ទ្រាំពុំបាន ក៏គំហកឲ្យឈប់មាត់ ។

នាងករិយារឹងរឹតតែខ្លោចផ្សា និយាយទាំងយំសស្រាក់ឡើងទៀតថា “ ឱព្រះម្ចាស់ថ្លៃអើយ តើកូនខ្ញុំទៅណាអស់ទៅ! ឱកូនបណ្តូលជីវិតម្តាយអើយ កូននៅទីណាម្តេចក៏ពុំឮមាត់ ។ កុមារទាំងអស់ដែលនៅឈរតំរៀបគ្នាមាត់ទ្វារ លុះឮពាក្យម្តាយសំបូងសង្រ្វែងហៅដូច្នោះ ក៏នាំគ្នាស្រែកយំឆ្លើយស្របឡើងថា “ អ្នកម៉ែអើយ យើងខ្ញុំនៅទីនេះ កូននៅឯណេះ! ” ។ នាង មាតាអរណាស់ ស្ទុះចេញទៅបើកទ្វារទទួលកូនហើយលោតទៅបីត្រកងកូនថើបគ្រប់ ៗ គ្នា និយាយថា “ ឱគុណព្រះម្ចាស់ថ្លៃខ្ញុំអើយ រាសនាខ្ញុំខ្ពស់ណាស់បានឃើញមុខកូនវិញយ៉ាងនេះ! ឱកូនស្ងួនពន្លកម្តាយ ឯងឃ្លានណាស់ហើយឬ! នែ ដេជ្ជាមាសម្តាយ! ម្តាយខ្លោចផ្សានឹងឯងណាស់ ” ។ ដេជ្ជានេះជាឈ្មោះបុត្រច្បងដែលនាងស្រឡាញ់ស្មើជីវិត ជាងបុត្រទាំងអស់ ។

គ្រួទាំងមូលប្រជុំគ្នាបរិភោគអាហារនៅជុំវិញគុះ ។ បុត្រម្នាក់ ៗ ក៏តាំងរ៉យរឿងប្រាប់ឪពុកម្តាយ អំពីដំណើរនៃសេចក្តីវេទ្ធ ដែលបន្ទាបឡើងនៅក្នុងព្រៃ ។ ឪពុកម្តាយមានសេចក្តីកំពយពន់ប្រមាណនឹងបុត្រសឹងលេបបាយពុំចូល ។

មិនយូរប៉ុន្មាន សោហ៊ុយនោះក៏អស់សូន្យទៅ ។ បុរសប្តីប្រពន្ធ

ក៏ផ្លាក់ខ្លួនទៅក្នុងសេចក្ដីអត់ឃ្លានជាថ្មី ៗ យ៉ាងនេះហើយបុរសប្ដីក៏សន្មត់ថា យកបុត្រទៅប្រាសចោលម្ដងទៀត ឲ្យឆ្ងាយជាងមុន ពីព្រោះជៀសវាងកុំឲ្យការស្រេកឃ្លានមកគ្រប់សង្កត់ផ្ដួលដល់ខ្លួនទាន់ ៗ

អ្នកទាំងពីរពុំអាចពិគ្រោះគ្នាឲ្យជិតស្ងាត់ ពីគេបៀកទៅអង្គុដ្ឋកុមារបាន ៗ កុមារបានដឹងហើយក៏ប្រុងប្រៀបថា នឹងប្រើឧបាយដូចមុនទៀត ៗ លុះដល់ព្រលឹមឡើង កុមារបំរុងនឹងលបចេញទៅរើសគ្រួសទៀត ប៉ុន្តែទ្វារផ្ទះចាក់សោជល់ទៅពីរជាន់យ៉ាងជាប់ ៗ កុមារទាល់គំនិត ៗ ក្ដីច្បាស់កាលណា មាតាបានយកនំបុ័ង មកលៃកាត់ជា៧ ចំណែក ចែកកូនគ្រប់គ្នា ៗ អង្គុដ្ឋកុមារ បានឱកាសនឹកឃើញថា នឹងបេះនំបុ័ងចំណិតតាមផ្លូវចំណាំ ជំនួសដុំគ្រួសជាការប្រសើរដែរ ៗ គិតដូច្នោះភ្លាម កុមារទទួលចំណិតនំបុ័ងពីម្ដាយ ដាក់នៅក្នុងហោប៉ៅភ្លាម ៗ

ដល់ពេលកាលណា បុរសប្ដីនឹងប្រពន្ធក៏នាំកូនចេញទៅ ៗ ម្ដងនេះ បុរសប្ដីនាំចូលទៅក្នុងព្រៃជ្រៅក្រាស់ឃ្មឹក ហើយងងឹតស្លុង ៗ បុរសនាំកូនយកទៅចោលឆ្ងាយ ល្មមតែនឹងវិលមកវិញពុំរួច ហើយក៏បង្វែររត់ចោលមកផ្ទះវិញ ៗ អង្គុដ្ឋកុមារគ្មានរន្ធត់សោះ ដោយគិតថា នឹងនាំបង ៗ ត្រឡប់តាមផ្លូវដែលខ្លួនធ្វើចំណាំមកវិញបានដូចប្រាថ្នា ៗ ប៉ុន្តែដល់ឆាកមកក្រោយ កុមារក៏គាំងគាំងស្មារតី ដោយពុំបានប្រទះនឹងកំទេចនំ

ប៉ុនដល់មួយចំណិតទៀយ ពីព្រោះសត្វរើសស៊ីអស់ទៅ ៗ ម្តងនេះ មុខដាវផ្លែនពិតប្រាកដ ៗ កុមារទាំងនាំបងកាត់ព្រៃចូលរាលរកផ្លូវចេញ ៗ ប្រឹងគ្រាប់ណាស់ ចំងាយផ្លូវកាន់តែស្រឡឹមឆ្ងាយដាច់សង្វែងទៅ ១ ៗ កុមារទាំងអស់វង្វេងនាំបងប្អូន ដើរផ្គុំគ្នាទៅតាមព្រៃ ៗ

ព្រះសុរិយាទន់ទាបហៀបនឹងលិចបាត់ទៅដើមព្រៃ ៗ ស្មើទន់ខ្សោយបន្តិចម្តង ១ ៗ កុមារខ្លាចផ្សាស្រែកយំរកម៉ែយ៉ាងខ្លាំង ៗ ព្រៃទាំងមូល ក៏លេតពន្លឺសូន្យឈឹងមួយរំពេច ៗ កុមារទាំងអស់ធ្លាក់ខ្លួនទៅក្នុងសេចក្តីបារម្ភឥតឧបមា ៗ ក៏យំទៀង ១ កុមារព្រួសព្រួសស្វែរកបបកផ្លែព្រៃលូយ៉ាងខ្លាំងអឹងអាប់ នៅជុំវិញខ្លួន ៗ កុមារតាំងផ្តុំប្រឌុបគ្នា ពុំហ៊ានមាត់កនឹងងាកក្បាលផង ៗ តមក សន្ធឹកស្លឹកបណ្តើឈើទ្រូសម្ងេរិប ១ យ៉ាងញ៉ើរកុមារពឹងខ្លាចមហិមា ៗ ផ្គរន្ទុះផ្ទុះឡើងផ្គូងផាំងនៅឯនាយ ៗ ផ្លេកបន្ទោរភ្លែត ១ តែប្រដេញនៅលើមេឃ ធ្វើឲ្យកុមារលែងបើកភ្នែក ៗ មួយរំពេចគ្រាប់ភ្លៀងធ្លាក់បង្អោរយ៉ាងត្រជាក់មួយមេធំ ៗ កុមារងាររញ៉ែប្រឌុបគ្នាយ៉ាងស្អិត ៗ ព្រាំពុំបានកុមារនាំគ្នារកលេងកកន្លែងជ្រក ៗ មិនបានប៉ុន្មានម៉ែត្រផង កុមារទាំងអស់ធ្លាក់ទៅក្នុងកក់យ៉ាងស្អិត ហើយខំប្រាំឡើងវិញខ្លួនប្រឡាក់ស្រម៉ក ៗ

សេចក្តីគ្នាបានបិតក្នុងកាយអង្គកុមារ ជាអ្នកមានស្មារតី តាំងប្រាំ

ទៅរើសដើមឈើមួយខ្ពស់ស្រឡឹម ៗ នៅលើចុង កុមាររំពៃមើលគ្រប់ទិស ៗ មួយរំពេច កុមារឃើញពន្លឺភ្លើងប្រទីបលឹម ៗ នៅឯនាយព្រៃ ៗ កុមារសំរូតចុះមកវិញ ៗ ដល់មកដី កុមារពាក់ភ្នែកពុំយល់ឡើយ ៗ ប៉ុន្តែម្តងនេះកុមារលែងខ្លាចហើយ ៗ កុមារពីរ គ្រោះទៅបង ៗ ត្រូវពាក្យក៏កាន់ដៃគ្នាទាំង ៧ យ៉ាងជាប់ ដើរតម្រង់សំរៀមទៅទិស ដែលខ្លួនឃើញពន្លឺប្រទីបនោះ ៗ បន្តិចមក កុមារទាំងអស់ក៏ចេញផុតពីក្នុងព្រៃ ៗ

តមកទៀត កុមារទាំងអស់បានទៅដល់ផ្ទះ ដែលមានដុតប្រទីបនោះ ៗ កុមារគោះទៅមាត់ទ្វារកំផែង ៗ ស្ត្រីចើកឆាយសប្បុរសម្នាក់ ចេញមកបើកទ្វារទទួលកុមារក្មាម ៗ ស្ត្រីនោះបានសាកសួរកុមារទាំងអស់ថា មានការអ្វី ៗ អង្គុដ្ឋឆ្លើយតបថា ពួកខ្ញុំជាកូនកំព្រាវង្វេងម្ដាយឪពុក នៅក្នុងព្រៃ ហើយដែលមកនេះ ដើម្បីសូមផ្ទះសំណាក់មួយរាត្រី ៗ ឃើញកុមារទាំងនេះ មានរូបឆោមល្អ នាងស្ត្រីនិយាយទាំងយំសស្រាក់ថា ៖ ក្មួយតូច ៗ ទាំងអស់អើយ អ្នកមកពីណា អ្នកពុំដឹងកន្លែងនេះ ជាអាស្រមយក្ស ដែលតែងបរិភោគកូនក្មេងទេឬ ? ៗ ក័យញ័រជាងបងទាំងអស់ អង្គុដ្ឋកុមារឆ្លើយតបថា “ ៖ អ្នកមីងជំមានធម៌សប្បុរសអើយ បើយ៉ាងហ្នឹងឲ្យខ្ញុំត្រឡប់ទៅណាវិញ ? ព្រៃនេះមានសុទ្ធសឹងតែសត្វសាហាវ វាមុខមិនបង្អង់នឹងផ្តាច់សិរសាយើងខ្ញុំបរិភោគឡើយ ! ហេតុនេះខ្ញុំជឿជាក់ថា លោកយក្ស

គង់នឹងមានមេត្តា ដល់យើងខ្ញុំកំសត់នេះជាពុំខាន សូមអ្នកមីងជួយអង្វរលោកជំនួសយើងខ្ញុំ ដោយករុណាផង ។

នាងកិរិយាយក្សមានចិត្តទន់ខ្លោចផ្សា ក៏ទទួលជួយយកអាសាកុមារ ដោយនាងគិតស្មានថា នឹងលាក់បានពីកណ្តាប់ដៃប្តី រហូតដល់ក្តី ។ នាងក៏នាំកុមារទាំង ៧ នាក់ចូលទៅក្នុងផ្ទះ ហើយយកទៅឲ្យអាំងភ្លើងនៅជើងក្រាន ដែលមានមេចៀមមួយយ៉ាងសស្គុះ ឆ្អើរនៅលើចង្អើរទុកសំរាប់ជាអាហារយក្ស ។

កំពុងតែអាំងភ្លើង ៈ កុមារទាំងអស់ឮសន្ធឹកខ្ទរញ៉ាវប្រឋពីទីងសំរែកយ៉ាងខ្លាំងនោះ ភ្ញាក់ផៃង កុមារដឹងជាក់ជាយក្សត្រឡប់មកដល់ហើយ ។ មួយរំពេច នាងស្រីឲ្យកុមារទាំងអស់លូនចូលទៅក្រោមគ្រែ ហើយនាងដើរចេញទៅបើកទ្វារឲ្យស្វាមី ។

ចូលមកដល់, យក្សក៏ប្រើកិរិយាឲ្យរៀបអាហារនិងស្រាឲ្យបរិភោគ ។ ចៀមឆ្អើរនៅឆៅស្រស់នៅឡើយ ប៉ុន្តែ ជាការប្រសើរចំពោះអាហារយក្ស ។ យក្សក៏ណាចប្រឹងស្រូបក្លិនដាក់ជុំវិញខ្លួន ដោយបានធុំក្លិនសាច់ស្រស់ ។ កិរិយាដឹងកិច្ច ក៏និយាយទៅថា "ក្រែងឯងធុំក្លិនកូនគោដែលខ្ញុំទើបនឹងពន្លះស្បែកអម្បាញ់មិញទេឬ? ។ យក្សក៏ហ៊ោកសំឡក់ទៅកិរិយាថា "អញធុំក្លិនសាច់ស្រស់ជាចម្លែក ក្នុងទីនេះប្រហែលជាមានសត្វអ្វីថ្មីទៀតហើយ" ។ គ្រាន់តែថាប៉ុណ្ណោះក្តាម យក្សក្រោក

ចេញពីគុ ហើយដើរតម្រង់ទៅកន្លែងគ្រែ ដែលលាក់កុមារ ។ យក្សឱន មើលទៅក្រោមគ្រែក្លាតសំឡេងថា " ហ៊ឹមហេតុការនេះ បញ្ជាក់អញ ហើះ រាប់ចង់ឲ្យអញចាំពាក្យលាឥឡូវ ឃើញទេសត្វមួយគំនរ អញនឹង អញ្ជើញសម្លាញ់អញបានពីរបីនាក់ មកជប់លៀងក្នុងពេលខាងមុខនេះ ។

យក្សតាំងចាប់ទាញកុមារមួយម្ដង ១ ចេញពីក្រោមគ្រែ ។ កុមារ ភ័យឥតឧបមា ក៏នាំគ្នាលុតជង្គង់សំពះយក្ស ។ យក្សកំណាចមិនមាន មេត្តា បែរជាបើកភ្នែកសាហាវធំ ១ ស្រែកសន្ធាប់ថា " ប្រពៃណាស់ អញ នឹងប្រហារពស្ទួរឲ្យបានឆ្ងាញ់ឥឡូវនេះ ! " ។ ថាហើយយក្សតាំងចូលទៅ ទាញយកកាំបិតធំមួយ ហើយសំដៅទៅជិតកុមារទាំងអស់ ។ យក្សតាំង សំលៀងកាំបិតនឹងថ្មមួយដុំគាន់នៅដៃឆ្វេង ។ ហើយក៏ចាប់កុមារម្នាក់ ក្ដាប់ជាប់ក្នុងដៃ ។ ប៉ុន្តែភរិយាស្រែកឃាត់ទៅថា " នែអ្នក ឯងប្រញាប់ ប្រហារអី ចាំថ្ងៃស្អែកមិនបានឬ ? យក្សសន្ធាប់ទៀតថា " កុំចេះ អញ ត្រូវតែប្រហារឥឡូវនេះ " នាងភរិយាអង្វរថា " ចុះសាច់ឯណេះខ្វះអីនៅ គរគោក នៅគោមួយ ចៀមពីរនឹងជ្រូកមួយចំហៀងធំ " ។ យក្សសើច ឆ្លើយតាមសម្រួលថា " អេឯងនិយាយត្រូវ បើដូច្នោះដាក់ម្ហូបឲ្យវាស៊ីផងទៅ ដើម្បីកុំឲ្យរាក់សាច់ រួចហើយនាំវាយកទៅឲ្យដេកឲ្យស្រួលបួល ! " ។ នាងភរិយាមានអំណរដ៏ក្រៃលែង ហើយក៏តាំងរៀបអាហារឲ្យកុមារបរិភោគ

យ៉ាងច្រើន ៗ ប៉ុន្តែ កុមារទាំងអស់បែរជាបរិភោគពុំចូល ដោយភិតភ័យផ្អក ៗ ក្នុងពោះពុំមានស្រាន្ត ៗ ចំណែកយក្សកំណាចខំប្រឹងផឹកស្រាដោយមានអំណរនឹងសត្វបម្រុកនោះ ៗ មិនតិចតួចយក្សផឹកជាប់ម្តៃកច្រើនជាងធម្មតា ៗ ស្រវឹងទន់ដៃជើងយក្សក៏ដេរទ្រេតទ្រោតទៅដេក ៗ

យក្សកំណាចនេះមានបុត្រី ៧ នាក់ នៅវ័យកុមារទាំងអស់ ៗ កុមារីទាំងនេះមានសម្បុរល្អឥតឆាយ ដោយអាស្រ័យតែសាច់ស្រស់ដូចឪពុក ៗ ប៉ុន្តែនាងមានភ្នែកតូច ហើយមានពណ៌ខៀវម្លុលក្រុំ ច្រមុះកោងក្រញ៉ុក មាត់ធំបងើង មានធ្មេញធំ ៗ វែងស្រួចលាំ ដោយដុះឃ្លាតពីគ្នាយ៉ាងរង្វើល ៗ កុមារីទាំងនេះ នៅពុំទាន់សាហាវនៅឡើយទេ ។ ប៉ុន្តែ ធ្លាប់ចាប់កូនក្មេងទាំងញាក់ហុតឈាមខ្លះមកហើយ ៗ មាតាតែងនាំបុត្រីទាំងនេះយកទៅផ្តេកពីព្រលប់នៅលើគ្រែមួយ ដំរៀបគ្នាទាំង ៧ នាក់ ហើយមានទាំងបំពាក់ម្កុដនៅលើក្បាលមួយ ៗ ម្នាក់ជាចំណាំ ៗ

នៅក្នុងបន្ទប់កូនស្រីយក្ស មានគ្រែមួយទៀតដាក់ទន្ទឹមគ្នា ៗ គឺក្នុងគ្រែនេះហើយដែលនាងកិរិយាយក្ស យកកុមារកំសត់ទាំងប្រាំពីរឲ្យទៅដេក បន្ទាប់មក នាងកិរិយាក៏ចូលទៅដេកក្នុងដំណេកនឹងយក្សប្តីទៅ ៗ

អង្គុដកុមារ ដឹងជាក់ជាបុត្រីយក្សមានម្កុដមួយ ៗ ម្នាក់ ពាក់នៅលើក្បាលជាចំណាំ ៗ កុមារតាំងក្រោកឡើងលបដើរតិច ៗ ទៅដោះម្កុដ

ពីក្បាលបង ៗ ទាំងអស់ព្រមទាំងម្កុដខ្លួន ហើយទៅលបដកម្កុដពីបុត្រីយក្ស បំពាក់ម្កុដឲ្យទៅវិញ ៗ កុមារយកម្កុដមកបំពាក់បងៗព្រមទាំងខ្លួន ហើយក៏ដេកទៅ ៗ ធ្វើយ៉ាងនេះកុមារលៃបំភាន់យក្ស បារម្ភក្រែងវាមកការចាប់ទាំងយប់ នឹងបានប្រឡំនាំយកកូនវាទៅប្រហារ ហើយក្រមខ្លួននឹងបានខ្លួបទុក្ខជាពុំខាន ។ កិច្ចនោះបានសម្រេចដូចប្រាថ្នា ៗ

ប្រមាណជាពាក់កណ្តាលអធ្រាត្រ យក្សស្វាងស្រាបន្តិចក៏ក្រោកឡើង ៗ សេចក្តីសាហាវអន្ទះអន្ទែងរបស់យក្សផ្ទុះឆេះពីដួងចិត្តក្លាយ ៗ យក្សមិនបង់ចាំព្រឹក នឹងប្រហារកុមារទាំងនោះសោះ ៗ ទើបយក្សស្ទុះក្រោកចេញពីគ្រែទៅចាប់យកកាំបិតមួយយ៉ាងធំ ហើយនិយាយថា "អើ អញទៅលេងអាកូនសត្វទាំងនេះ ឲ្យវាដឹងដៃម្តង!" ៗ យក្សចាំគ្រែជាក់ក៏ចូលទៅបន្ទប់កូនស្រី ដើម្បីចាប់កុមារយកមកប្រហារទាំងយប់ ៗ យក្សតម្រង់ទៅគ្រែនោះហើយលូកដៃស្ទាបៗក្បាលគ្រប់ៗ គ្នាឃើញមានម្កុដទាំងអស់ៗ យក្សក្អាកមាត់ថា "យីអញផឹកច្រើននាំវង្វេងអស់ !" ៗ ថាដូច្នោះហើយយក្សដើរទៅគ្រែកូនស្រីវិញ ៗ យក្សលូកដៃស្ទាប ៗ ក្បាល ៗ មួយរំពេចយក្សនិយាយថា "នែ អាកូនសត្វនៅឯណោះសោះ!" ៗ និយាយបណ្តើរយក្សកាំងស្ទាបក្បាលកាត់កកូនស្រីឯងបណ្តើរទាល់តែអស់ យក្សសប្បាយពន់ពេកញាក់មុខញាក់មាត់ចំណាក់កាំបិត ដើរទៅដេកនឹងប្រពន្ធទៀត ៗ

បន្តិចមក អង្គុដ្ឋកុមារដែលពុំមានភ្នែកបន្តិចសោះ ក៏បានឮមាត់យក្ស ស្រមុកយូៗ ។ កុមារទាំងដាស់បងៗ ឲ្យក្រោកស្ទាត់ស្ទៀមក្ទាម ហើយ ខ្សឹបៗ ឲ្យលបចេញតាមខ្លួនមក ។ កុមារទាំងអស់ព្រមព្រៀងលួចចុះតិចៗ កាត់តាមសួនច្បារ ហើយនាំគ្នាឡើងតាមកំផែងលោតផ្លោះទៅក្រៅទាំង អស់គ្នាបានដូចប្រាថ្នា ។ កុមារទាំងនាំគ្នារត់ត្របាញ់ជើង ក្នុងពេលពាក់ កណ្ដាលអធ្រាត្រធំ ដោយនឹកខ្លាចពុំដឹងជាទៅទិសណាជាទិសណា ។

ទៀតក្ដី យក្សក្រោកឡើងនិយាយកាន់ទៅភរិយាថា " ប្ចូរឯងក្រោក ឡើងយកសម្ញៀកបំពាក់ទៅពាក់ឲ្យអាកូនសត្វទៅ " ។ នាងភរិយាបាន ឮពាក្យបង្គាប់របស់ស្វាមីយ៉ាងនេះ ក៏សែនធ្ងល់ជាអនេកដោយស្មានថា យក្សមានមេត្តាមកវិញ ។ នាងក៏ដើរចូលទៅក្នុងបន្ទប់ទុកកុមារនោះ ។ គ្រាន់តែដល់ភ្លាម នាងភ្ញាក់ខ្លួនព្រើតបាត់ស្មារតី ដោយបានឃើញបុត្រី ទាំង ៧ នាក់ ដាច់កដេកនៅក្នុងឈាមជំគ្រាស់ឃ្លក ។

បាត់យូរពេក យក្សស្មានថា ភរិយាពុំធ្វើតាមបង្គាប់ ក៏ចូលទៅតាម បំរុងនឹងជួយធ្វើភរិយា ។ គ្រាន់តែដល់ភ្លាម យក្សបាត់ស្មារតីនឹងហេតុ ដ៏សាហាវនោះ ក៏ស្រែកទ្រហោថា " យើ អស្ចារ្យណាស់ហ្ន៎! អាកូនសត្វ នេះវាសងសឹកអញពេញទី " ។

យក្សក្រោធសឹងធ្លាក់ឈាមពីមាត់ ទើបស្រែកឲ្យភរិយាយកស្បែក

ដើរទី ៣៧ យោជន៍មកឲ្យខ្លួន ដើម្បីពាក់ទៅតាមចាប់កុមារ យកមកប្រហារវិញ ៗ ពាក់ស្រេច យក្សតាំងហោះទៅភ្លាម ៗ មួយសន្ទុះយក្សក៏ដល់ទៅផ្លូវដែលកុមារនាំគ្នារត់ ៗ

រីឯកុមារ ក្នុងមួយយប់នោះ ដោយវាសនាល្អក៏បានទៅដល់ ជិតខ្ទមមាតាបិតានៅតែមួយរយម៉ែត្រប៉ុណ្ណោះ ៗ កុមារងាកមកក្រោយឃើញយក្សនៅស្រទ្បឹមខ្ពស់ស្គុះហោះលយលឿនផ្លោះផ្ទង់ភ្នំមួយទៅភ្នំមួយ ធ្វើស្លឹងធំទូលាយ ដូចជាធ្នង់កូនថ្កុកតួបឥតឧបមា ៗ កុមារនាំគ្នាបះតែរត់ ៗ អង្គុជកុមារមានស្មារតី ងាកទៅជើងថ្នល់ឃើញមានផែនថ្មមួយផ្ទាំងធំមានប្រហោងយ៉ាងស្រួលនឹងពួនលាក់អាត្មាទាំងអស់បាន ៗ មួយរំពេច កុមារឲ្យបងៗគ្រាលចូលទៅពួននៅក្នុងប្រហោងថ្មនោះ ៗ យក្សក៏កាន់តែមកជិតដល់ ដោយពុំបានឃើញហ្វូងកុមារសោះ ៗ

មិនបានតាំងមួយនាទីផង យក្សមកដល់ទីនោះ ៗ អស់កំលាំងជាអនេកព្រមទាំងនៅស្រវឹងបន្តិចៗផង យក្សក៏សន្តក់ឈប់សំរាកនៅលើផែនថ្មនោះ ៗ យក្សតាំងសំងំឲ្យមានកំឡាំងនឹងហោះតាមទៅទៀត ៗ

ដោយខ្យល់ត្រជាក់ៗយក្សក៏ដេកលក់ស្រមុកគ្រូកៗ ខ្ទរអស់ផែនដី ៗ កុមារដែលនៅក្នុងរូងថ្មភ័យញ័រអស់សព្វាង្គ ៗ អង្គុជកុមារគ្មានញាប់ញ័រអ្វីសោះ ហើយបង្គាប់ទៅបងៗឲ្យចេញរត់សំដៅទៅផ្ទះ ដែលខ្លួនចំណាំច្បាស់នៅត្រើយនោះ ៗ បងក៏ធ្វើតាមបង្គាប់ប្អូន ៗ

លុះឃើញបងៗដល់ផ្ទះអស់ហើយ អគ្គិដ្ឋកុមារក៏តាំងលបទៅជិតយក្សដែលកំពុងដេកលក់មិនដឹងខ្លួន លួចទាញដោះស្បែកជើងយក្សតិច ៗ ៗ ស្បែកជើងនោះធំហើយវែងរលាំឥតគណនា ៗ ប៉ុន្តែដោយជារបស់ទិព្វ កុមារស៊កជើងពាក់ទៅត្រូវល្មមគ្មានខ្វះ ៗ

សំរេចដូចបំណង កុមារតាំងបោះសំដៅទៅលំនៅយក្សវិញ ៗ ដល់ហើយកុមារឃើញភរិយាកំពុងបោកខ្លួន យំដូចអកនឹកខោចកូនស្រី ៗ កុមារស្រដីទៅថា "ហៃអ្នកមីង ប្ដីអ្នកមីងមានគ្រោះថ្នាក់ធំណាស់ ឥឡូវនេះត្រូវពួកចោរប្លន់ព្រួតគ្នាចាប់បានហើយ វាបានសន្យាថានឹងប្រហារជីវិតប្ដី បើប្ដីអ្នកមីងគ្មានមាសនឹងប្រាក់ពេជ្រយកទៅលោះវា ក្នុងពេលដែលវាហៀបនឹងកាត់កនឹងដាវជ័សស្លាប ស្រាប់តែពូយក្ស ក្រឡេកមកឃើញខ្ញុំ ហើយក៏ហៅខ្ញុំឲ្យចូលមកជិតនិយាយអង្វរថា ឲ្យខ្ញុំពាក់ស្បែកជើងនេះរត់មកផ្ទះប្រាប់អ្នកមីង ឲ្យយកមាសពេជ្រដ៏មានដម្លៃទាំងអស់ហើយឲ្យប្រគល់ដល់ខ្ញុំយកទៅឲ្យចោរនោះឆាប់ៗទាន់វេលា ! " ៗ ភរិយាយក្សស្លុតស្មារតី ក៏ម្នីម្នាទៅប្រមូលមាសប្រាក់ពេជ្រដ៏មានដម្លៃ យកមកប្រគល់ឲ្យទៅអគ្គិដ្ឋ-កុមារនាំយកទៅលោះស្វាមី ៗ បានទទួលរបស់របរដ៏មានដម្លៃទាំងអស់ស្រេច កុមារដ៏មានឫទ្ធិតាំងប្រកទៅក្នុងស្បែកជើងណែនហើយបោះពួយវឹងសំដៅមកលំនៅឪពុកម្ដាយដើម ៗ មិនយូរប៉ុន្មាន កុមារក៏មកដល់ផ្ទះជួបជុំបងប្អូនម្ដាយឪពុកយ៉ាងសប្បាយ ៗ

ចំណែកឯយក្សលុះភ្ញាក់ឡើងបាត់ស្បែកជើងក៏ខឹងគេទោម្ញេញ ឯណានឹកអាល័យបុត្រី ឯណានឹកខ្មាសការយាវិញ ៗ ខឹងហួសប្រមាណយក្សខាំមាត់បោកក្បាលសម្លាប់ខ្លួនឯងក្នុងខណៈនោះទៅ ៗ

ក្រោយមក បានឮដំណឹងសុះសាយទៅពេញទាំងនគរ ៗ ថ្ងៃមួយអគ្គិដ្ឋកុមារក៏ពាក់ស្បែកជើងទិព្វចូលទៅគាល់ព្រះរាជា ដើម្បីស្នើការសូមខ្លួនទៅពិនិត្យការណ៍ចម្បាំងកងទ័ព ដែលកំពុងប្រយុទ្ធឆ្ងាយពីរយោជន៍ពីនគរ ៗ ព្រះរាជាព្រមអនុញ្ញាតឲ្យកុមារទៅតាមមើលការណ៍ដើម្បីវិលមកទូលព្រះអង្គវិញ ឲ្យទាន់ព្រះរាជហឫទ័យ ៗ កុមារដ៏មានឫទ្ធិក៏បានហោះទៅសមរភូមិ ៗ កុមារត្រឡប់នាំការណ៍ពិតមកថ្វាយព្រះ-រាជាក្នុងពេលល្ងាចថ្ងៃនោះវិញថា កងទ័ពខាងព្រះរាជាមានជ័យជំនះលើបច្ចាមិត្ត ៗ ព្រះមហាក្សត្រទ្រង់មានព្រះរាជអំណរ ហើយក៏ទ្រង់ថ្វាយរង្វាន់ ដ៏មានដម្លៃច្រើនដល់កុមារ ៗ

ជាលំដាប់មកទៀត កុមារ តែងធ្វើជាអ្នកជំនួយខាងរត់សំបុត្ររបស់អ្នកនគរទាំងមូល ៗ ស្រីៗតែងពឹងពំនាក់កុមារឲ្យនាំយកសំបុត្រនេះទៅសួរសុខទុក្ខប្តីនិងញាតិសាលោហិត ដែលនៅឆ្ងាយដាច់ស្រែង ៗ កុមារទទួលផលដ៏ឧត្តមចិញ្ចឹមគ្រួសារញាតិមាតាបិតានូវបងទាំងអស់ គ្មានឲ្យលំបាកមួយវេលាណាឡើយ ៗ

- ចប់ -

# រឿងទេវន្ទ (ពាក្យកាព្យ)

លោក អម្មាត្យត្រីម៉ុក រៀបរៀង ក្នុងរាជ្យព្រះករុណាព្រះបាទសម្ដេចព្រះនរោត្ដម

លោក ញ៉ុក-ថែម ពិនិត្យ ( គមក )

---

ឥសីផ្ដាំថា បើបានយាត្រា កុំព្រះភូធរ ហៀរហោះរម្ងង់ តែម្ដង
បោះបោរ ចូរត្យត្រូបវ័រ ចាំពាក្យដីកា ៗ ទៅតែហួសក្ដិ ទទឹងជាធំ នៅមុខ
នោះណា មានស្រះមួយធំ ស្ដេចកុំយាត្រា ចូរឈប់និទ្រា នៅឆ្នេរស្រះ
ស្រី ៗ ទំនើងស្ដេចចង់ សេពសោយស្រប់ស្រង់ បុប្ផាបុប្ផ៍ នូវរុក្ខផលា
អាហារបំណី ចំណង់អ្វី ៗ តាមចិត្តប្រាថ្នា ៗ ព្រឹកព្រានស្រាងស្រេច
ស្រួលបួលសឹមស្ដេច បោះបោរយាត្រា បើដល់ដែនយក្ខ អបល័ក្ខណ៍មោហា
ហាក់ហៅព្រោះប្រា ការគេលអ្វី ៗ ៗ កុំផ្ទក(១) មើលវា កុំស្ដាប់វាថា
កុំជឿសំដី បើព្រះចមពៅ ឈប់នៅនោះនៃ នឹងបង់សេចក្ដី បំណង់ប្រាថ្នា ៗ

ពោធិបគ្គិ ទូលថាអញ្ចុំ ទទួលពុទ្ធដីកា ដោយដាក់ដំកល់ មណ្ឌល

---

១ គឺកំព្រឿក ។

សំរេសា កុំព្រះដីកា ព្រួយនឹងអញខ្ញុំ ៗ ស្រេចព្រះភូមិន្ទ ស្តេចប្រទក្សិណ ឥសីបីដុំ អាស្រមស្រេចស្រាប់ សម្តេចព្រះបរម ពោធិទត្តម ក្រញូក្រាប លុតលា ៗ កែក្រាយបោរបរ រូបរកេសរ ឯកអង្គថ្ងៃថ្ងា លុះក្រៅអាស្រម ពិតពុំវេរា ឡើងគង់អាជា-នេយ្យនាំហោះទៅ ៗ ស្តេចហោះហួស ភ្នំ យល់ស្រះមួយធំ ព្រះបាទបមតៅ ស្រង់សោយផលា អាហារឥត សៅ ស្តែងស្តេចផ្ទុំនៅ អស់ឯកការត្រី ៗ ស្តែងស្តេចស្រប់ស្រង់ ជម្រះ ព្រះអង្គ ទៀងទើបនរបតី គង់សេះហោះដល់ មណ្ឌលយក្ខិនី យក្ខយល់ ចក្រី អវឯងគិតថា ៗ

អះអញនឹងរំ បញ្ញោតអ្នកនេះ ជាកក្ខគោគ្គា ក្រុងយក្ខគនគិត និម្មិត-សាលា មួយមានអស់អា- ហារហើយហៅហៅ ៗ ពង្សព្រុទ្ធង្គួរ ពុំបើកបន្ទូល ប្រឹងបរសេះទៅ យក្ខយល់ហ្នោះសោត គ្រៅក្រោធក្តាត់ក្តៅ ហៀវហោះរាំងទៅ អំពីព្រះកក្រ្តូ ៗ និម្មិតសាលា មានគ្រឿងសេយ្យនា ដូចទីមហាចក្រ និម្មិតអាត្មា ឯងជាស្រីម្នាក់ កាយគបលក្ខណ៍ ដូច ស្រីសួគ៌នាយ ៗ ហើយហាហៅថា ឱអ្នកទៅណា អញ្ជើញមកអាយ ស៊ីស្លាឈប់ខាន សម្រាន្តអង្គកាយ ព្រឹកព្រាងសូរ្យសាយ សង្រ្គមអ្នកទៅ ៗ

ពង្សព្រុទ្ធបក្រ ពុំឈ្ងៀងព្រះកក្រ្តូ ពុំស្តាប់ពាក្យហៅ គិតក្រែងអំ ពល់ យក្ខយល់ចមតៅ ប្រឹងបរសេះទៅ ពុំមើលអាត្មា ៗ រាងហិចហោះ

ទៅ ពីកក្ដិបមទៅ និម្មិតសាលា មានតូបត្រ្ទិ មានស្រីផងជា អ្នក លេងស្លូតស្លាំ ស្លូរសព្ទល្មីងល្មើយ ៗ រេរាំរូបពង លាស់លន់យាស-យាង ហាក់ហុចហៅហើយ កែក្រាយឈ្នងឈ្នៀង ជ្រួបជ្រៀងព្រ-ងើយ ក្លេងក្លាត់ផ្លាស់ផ្ទើយ សព្ទសោតសមស្លូរ ៗ ហាក់ដូចតន្ត្រី អំពីសួគ៌ស្រី សម្ដេចព្រះភូ- ធរេន្ទ្រសេដ្ឋ លោកៈវិទូ ពុំស្ដាប់សព្ទសូរ ពុំផ្ទេកនេត្រទៅ ៗ

យក្ខយល់រឹងរឹះ ថាអះអ្នកនេះ ហៅហ្លួសលំនៅ អង្គអញនេះនឹងធ្វើងស្លឹងហ្លួសទៅ អង្គអញអាសៅ អសារខានស៊ី ៗ ត្រូវអញទៅតាម តាំ-ស៊ីហុតឈាម ឲ្យក្សយដីរ គិតស្រេចថៃ ចក្លាយ ក្លែងកាយឥន្ទ្រិយ ជាយក្ខត្រី តំបងតាមទៅ ៗ ឈើឈរញ៉ៅញែក ទោរទន់ដោយតេជ យក្ខយន់យោរយៅ ខេវខឹងផ្ទោះផ្ទើក ក្រឡេកក្រឡៅ សព្ទស្លូរខ្លួទៅ បំផ្លូប-រន្ទះ ៗ សេះសោតយន់យល់ យក្ខះទៀបដេញដល់ ទៀងទើបទូលព្រះពង្សព្រុទ្ធឧត្ដម អញខ្ញុំសូមពះ ដោយតេជតបះ នឹងយក្ខមោហា ៗ បូរស្ដេចចុះទៅ គង់នឹងនិត្យនៅ តាំងតបេស្ដា ខ្ញុំយុទ្ធនឹងយក្ខ ឲ្យជាក់ដៀងប្រា- កដកើតកាលគ្រា នេះទឹងឲ្យស្ដែង ៗ តោធីប្រសើរ ចរចុះពីលើសេះសោតឥតក្រែង ចរចូលឈរឈប់ ក្រោមម្លប់ឥតល្វែង ចិត្តបង់សំដែង បុណ្យបារមីមាន ៗ

យក្ខបន់ចាប់ស្តេច គ្រវីខ្នះពេជ្រ យក្ខយន្តពុំហាន គិតថាអញចាប់ សម្លាប់អស្សយាន ស៊ីសិនគង់បាន អ្នកនេះទាំងឡាយ ៗ គិតស្រេចក្រឡាប់ ក្រឡះបុលចាប់ សេះសោតប្រះប្រាយ ស្រែកសព្ទពងសីហ៍ បន្ទឺញ្ញាយ លោតឡើងកកាយ កាន់អាកាសា ៗ មាត់មុខខាំស៊ី ជើងមុខទាំងពីរ ជាន់ត្រូវទភា ជើងក្រោយជាន់ជាក់ ក្តៅយក្ខមោហា ដាច់សាច់មំសា លោហិតខ្ចរខ្ចាយ ៗ ហោះឡើងលើភ្នំ ប្រមៀលអស់ជុំ សិលាទាំងឡាយ ដកឈើរើថ្ម ចោលមកព្រោងព្រាយ មមាមិញម៉ាយ ស្លាប់ក្សត្រថ្ងៃ ៗ ទេព្តាផាយផាត់ ការកាយមហាក្សត្រ សេះសោតក្រោធក្រៃ អញ្ជើញព្រះមហា ក្សត្រាថ្កាថ្ងៃ គង់ហោះឯព្ធ អាកាសវេហា ៗ ចរចូលតភាំង ទល់ទព្វពាំង នឹងយក្ខមោហា ទ្រង់ខាន់វាយវាត់ កាប់កាត់យក្សា យក្ខសោតមរណា ដាច់ខ្លួនខ្ចាត់ខ្ចាយ ៗ

សេះនាំហោះដល់ ត្រឹមត្រើយមណ្ឌល ស្ទឹងធំទូលាយ ស្រេចសោយស្តេចស្រង់ ព្រះគង្គាកាយ ត្បូរគង់សប្បាយ ក្រោមដើមព្រះជ្រៃ ៗ ស្តេចសូត្រចិន្តា- មណីមន្តជា ព្រះមន្តទិព្វថ្ងៃ ត្រីផងនៅក្នុង កម្ពង់ជលស័យ ពុំអាចអាស្រ័យ និត្យនៅនឹងបាន ៗ សោតសឹងឡើងមក ពាសពេញកុះករ បន្ទំក្សត្រក្សាន្ត ទាំងមហាលោមា ជាតិជាប្រធាន រឹងត្អឹងពុំបាន សឹងមកវន្ទា ៗ សួរសព្វហេតុផង ស្តែងស្តេចនឹងជូន អញ្ជើញក្សត្រា

គង់ទៀងលើខ្នង បម្រុងគង្ហា ត្រឹងផងតោមជា បរៈរាហៃលហៃ ៗ សេះហ៊ាច ហោះទៅ ឈប់ឈរចាំនៅ មើលក្សត្រក្បាន្តង មាត់ត្រើយស្ទឹងម្ខាង ស្ដេច យាងទៅតែ នឹងត្រីហៃលហៃ ព្រះបាទបង្រួនបង្ហាស់ ៗ ដល់ហើយបម ទៅ គង់សេះហោះទៅ ដល់ផ្ទះជូនតាស់ ក្នុងទំនៀន គេស្រមក្បាន្តពេក ណាស់ បើកបង្ហួលត្រាស់ នឹងជូនតាស់ថា ៗ តាជួននិត្យទៅ ឯកឯក កូនទៅ កំព្រាកំព្រា អាស្ទូវឲ្យទៅ និត្យនៅផងក៏ ទៅនឹងគេ្យ ចិញ្ចឹមតា យាយ ៗ ជ្រិតទៅឯកឯង ដើរព្រៃឆ្ងៃង មកពីស្រុកឆ្ងាយ តាស់ពីគ្រេក អរ ស្ទោះសរិកាយ គេកាជនថ្វាយ ស្ដេចសេពសោយស្រេច ៗ សូរសព្ទ នាមករ ទំទេសនគរ បុរីរដ្ឋស្ដេច ស្រេចទើបព្រះអង្គ ពូជពង្សសារពេជ្ លុតលើលាគេប មកកាន់អស្សយាន ៗ

បូរបង់ទៅនៅ រះគស៊ីស្មោ ព្រៃព្រះហោមពាន្ត បើប្អូនមានទុក្ខ ពុំ សុខក្នុងប្រាណ -នឹកដល់កុមារ បូរធាបវិលមក ៗ សេះសោគឈាទៅ ដើរគស៊ីស្មោ ដោយព្រៃឈ្មូងធក ព្រះម្កុដគ្រែកព ត្រឡប់វិលមក និត្យ នៅរះគ ចិញ្ចឹមជូនតាស់ ៗ

យាយតែងបេះផ្កា គ្រឹបក្រងបង់ជា កីផ្កាធ្មកឆ្ងាស់ ថ្វាត់ថ្វាយជីតា ជាតិជាអម្ចាស់ រៀងមកយាយតាស់ នោះតែងក្រងថ្វាយ ៗ ក្សណា ក្សត្របា្ហស់បង្រួន បេះបុប្ផាផង រះរៀបរៀងកាយ តាប់បេសតាក់បង់ ក្រាល

ត្រង់លើគលាយ ពណ៌ពិតលែបខាយ ដោយប្រាជ្ញាញាណ ។ អធិដ្ឋាន ថា បើនាងនោះណា ជាគូបុព្វណ ជាស្រីគ្នាថ្ងៃ កន្សែងពោធិញ្ញាណ កាយ គបបុណ្យបាន បាទបរិចារិកា ។ ឃើញផ្កាអន្គអញ នេះត្រេកស្រឡាញ់ ហាក់ដូចយល់គ្នា ផ្សែងស្រេចប្រែប្រាយ ប្រាប់យាយចាស់ថា យាយ អើយយកផ្កា ទៅថ្វាយក្សត្រី ។ ពីថ្ងៃនេះទៅ ទុកឆារឲ្យទៅ ត្រង់ដួស ប្រក្រតី យាយបានទៅហើយ យាយអើយក្រថ្មី ចិត្តទៅប្រណី ជៀតយាយ ចាស់ហើយ ។ យាយស្ដាប់ព្រះមហា- បុរសហើយថា ឲ្យអ្នកថ្ងៃអើយ បានអ្នកបេះក្រង ស្ដាប់ស្នងយាយហើយ ទ្រង់ឃោយបានស្បើយ បាន បាត់ឈឺខ្លួន ។

ថាហើយយកផ្កា ទៅថ្វាយធីតា នាងយល់គម្រង បុប្ផាផលប្លែក ចំឡែកសព្វផង ព្រះហឫទ័យចង់ គួបគើតស្នេហា ។

ទើបសួរយាយចាស់ ផ្កានេះប្លែកណាស់ បានពីនរណា នរអ្នកបេះចង បេះក្រងទងផ្កា នេះប្លែកបូរថា ដោយពាក្យពិតត្រង់ ។

យាយចាស់ទូលថា បពិត្រធីតា ប្រសើរវរវង្ស ខ្ញុំតែងក្រងថ្វាត់ ថ្វាយក្សត្រីទ្រង់ មិនដែលឲ្យអង្គ អ្នកណាក្រោលក្រង ។

នាងស្ដាប់យាយចាស់ ពិតពុំជឿគ្រាស់ សួរពីរបីដង យាយធ្វើយ ប្រាប់ប្រែ ថាតែខ្ញុំក្រង ពុំថ្វូងដោយដង ដោយដំណើរត្រង់ ។ ទើប

នាងបណ្ដេញ អស់ស្រីផងចេញ ហៅយាយចូលក្នុង សង្កេតសួរស្រួល យាយទូលតាមត្រង់ បពិត្រសូមទ្រង់ ប្រោសប្រាណមេត្តា ។

ដ្បិតអង្គអញខ្ញុំ មែនមានចៅកំ ឡោះមួយលីលា ពីប្រទេសឆ្ងាយ តែកាយឯកា មកសូមនៅជា មួយនឹងអម្ចាស់ ។ នាមឈ្មោះទេវន្ទ ប្រសើរសោភ័ណ ឥតមានទោសទាស់ វិសេសវិសាល ត្រកាលល្អណាស់ ប្រុសប្រាជ្ញច្បាស់ លែងលោកដទៃ ។

នាងឮព្រឺព្រួច ព្រះហឫទ័យកាន់គួច កើតក្ដីអាល័យ ហាក់យល់កង្រា ព្រះមហាក្សត្រថ្លៃ សោកសំណាងនៃ នាងនោះប្រាថ្នា ។ នឹងព្រះពង្ស ពោធិសត្វឧត្ដមា ច្រើនជាតិជាក់ជា កន្សែសម្ដេច សារពេជ្រសាស្ដា ញាណញោយ្យសម្មា-សម្ពោធិញ្ញាណ ។ ត្រាស់ថាដូច្នោះ យាយទៅ មុនចុះ ទៅរៀបទីឋាន ឯអង្គអញឯង បង់លេងខ្សាន ឲ្យសុខឲ្យសាន្ត ឲ្យក្សេមសប្បាយ ។ ក្រោយយាយទៅលង់ តិចទើបនាងទ្រង់ សំអាងព្រះកាយ នាំអស់ស្និទ្ធស្នំ ចាស់ទុំទាំងឡាយ ចរចូលថ្វាត់ថ្វាយ បង្គំបិតា ។ ទូលថាអញខ្ញុំ លុតលាអង្គអ- ម្ចាស់ចរយាត្រា ទៅលេង ខ្សាន កំសាន្តចិន្តា សុំមាតាករុណា ប្រោសប្រទានទៅ ។

ស្ដេចស្ដាប់បុត្ររត្ន ពិតពុំខាំងឃាត់ បើកបន្ទូលហៅ អាមាត្យមួយ ថ្វាត់ ហើយក្សត្របមចៅ ត្រាស់ឲ្យរៀបទូវ សេនាពជយាន ។ អាមាត្យ

លុកលា ចេញរៀបសេនា សេនីពលហាន តូរ្យតន្ត្រីត្រែ គ្រប់គ្រស្វរគាំ សេនាសិនមាន គ្រឿងគ្រប់ដោយដៃ ។

នាងលាក្សត្របាន វិលវិញរាជដ្ឋាន ប្រាសាទទិព្វថ្ម ស្រីស្រស់ទ្រង់គ្រឿង រុងរឿងប្រពៃ ដូចជាទេវី នីអ្នកផ្ទឹមបាន ។ យានយាសកាយករ លីលាចេរចរ ចេញពាក់រាជដ្ឋាន គន់លើត្រែមាស ឱកាសថ្កើងថ្កាន សេនាពលហាន ហែៗចេរចរ ។ អស់ស្នំបរិពារ ពាស់ទុំស្រិង្គារ តូច ៗ ល្អ ៗ រាងរៅ រៀវរៀវ ស្រស់ស្រៀវស្រគរ គ្នីគ្នាប្រើសប្រ- ដាប់ដង្ហែទៅ ។ តន្ត្រីសង្ខ័ត្រ ប្រគំដង្ហែ ក្សត្រីចមទៅ វិសេសវិសាល គ្រអាលឥតសៅ លង់លុះដល់ទៅ ទង្វាទពុំលង់ ។ សម្តេចក្សត្រី កបកល្យាណី ផាក់ផ្លាស់គ្រឿងទ្រង់ នាំអស់បរិពារ ស្រិង្គារគ្រប់អង្គ លីលាចុះស្រង់ ស្រះស្រីរង្ថា ។ ផ្កាយផ្ទះ កេសី វរាជក្សត្រី គ្រេកព្រះទ័យា នូវស្នំហែលហិច ហែលគេចដេញគ្នា សើចសាំះហោហា កញ្ច្រោកទះទឹក ។

ខ្លះហែលបេះបាន បទុមាមាន សុគន្ធាធិក លំបង់កេរាយ កបកាយ- ស្មោមស្ទឹក លូតលាស់លើទឹក រុះរោយគេសរ ។ បេះបង្កុលណី កម្រុទ បុប្ផ ទក្សលគន្ធ សើមសៀតបង់ដួត បង្គួតបង្គ បេះបានថ្វាយវររក្សរាជ- ក្សត្រី ។ នាងសាន្តសុខសល់ ក្នុងព្រះកមល ដូចទេពស្ទូតស្រី

(ហទក)

# រឿងសាមកុក

## កណ្ឌទី ៣០

ឧកញ៉ាវិបុលរាជសេនា ង៉ួ-ហុង ប្រែរៀបរៀង

( តមក )

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

សន្តានបងប្អូនអួនសៀវ នឹងបណ្ដាស្ត្រីអ្នកស្រុក ឲ្យបានសេចក្ដីក្ដៅក្រហាយឡើយ ដែលលោកជាកូននឹងចូលទៅនោះ ឃើញថាជាការល្មើសនឹងពាក្យមហាទេពរាជ ។

ចោភីបានស្ដាប់ពុំដូច្នោះ ក៏ស្រែកគំហក ហើយដើរចូលទៅដល់ល្វែងក្នុង ឃើញស្រី ២ នាក់ ឱបគ្នាយំទួញ ចោភីក៏កឹកឈ្លួលឆេះហូតក្រប៊ីចេញនឹងកាប់ស្រីទាំង ២ នាក់នោះចេញ ហើយបែរត្រឡប់គិតទាន់ទើបសួរថា ទៅទាំងពីរនេះឈ្មោះអ្វី? ហេតុម្ដេច បានជាមកអង្គុយយំដូច្នេះ? នាងឡេដាំងឆ្លើយតបវិញថា ខ្ញុំឈ្មោះនាងឡេដាំង ជាភរិយាអួនសៀវ នាង

នេះឈ្មោះអៀនស៊ី ជាភរិយាអ្នកហ៊ុចៅហ្វាយស្រុកអ៊ុជីវ ដែលជាបុត្រអ្នកសៀវ ចោគីក៏ថាឲ្យនាងអៀនស៊ីងើបមុខឡើងនឹងមើល ក៏ឃើញមុខមាត់នឹងរូបរាងល្អស្រស់ប្រិមប្រិយ ក៏កើតសេចក្ដីស្នេហាស្រឡាញ់ ទើបប្រាប់ថា យើងឈ្មោះចោគីជាបុត្រមហាឧបរាជ យើងនឹងរក្សាថែទាំមិនឲ្យមានសេចក្ដីអន្ដរាយបានឡើយ ។

ឯចូឆក៏ជិះសេះនាំទៅហ៊ុវនឹងសេនាទាហាន ចូលទៅដល់ទ្វារស្រុកគីជីវ ទៅហ៊ុវក៏មានចិត្តគិតថា ចូឆនឹងខ្លួនជាកៀនសំឡាញ់គ្នា មកពីដើម ក៏បរសេះស្រួតមកទន្ទឹមនឹងសេះចូឆ ហើយយកសែសេះបង្អុលត្រង់ទ្វារស្រុកថា បើយើងមិនត្រិះរិះឲ្យធ្វើចម្បាំង ក៏នឹងមិនបានមកឃើញទ្វារស្រុកគីជីវនេះឡើយ ។ ចូឆបានឮហើយក៏ធ្វើជាអស់សំណើច ហើយមិនតបថាអ្វីសោះ តែបណ្ដាទាហានទាំងពួងនោះ ក៏មានចិត្តខឹងក្ដៅនឹងទៅហ៊ុវពន់ប្រមាណ ។ ចូឆក៏ចូលទៅដល់ទ្វារផ្ទះអ្នកសៀវ ហើយសួរអ្នកចាំទ្វារថា នរណាបុលមកធ្វើអន្ដរាយភរិយាបុត្រនឹងបងប្អូនអ្នកសៀវខ្លះ ? នាយទ្វារជំរាបថា ឥឡូវចោគីបុត្រលោកចូលទៅនៅខាងក្នុង ។ ចូឆក៏ឲ្យហៅខ្លួនចោគីចេញមក ហើយនិយាយរលឹកប្រដៅ មិនឲ្យធ្វើកវតទៅ ។

ខណៈនាងឡេងជីចេញមកគំនាប់ចូឆហើយថា ដែលចោគីចូលមកនេះ បានការពាររក្សាប័ក្ខពួកខ្ញុំម្ចាស់ ស្រួលបួលណាស់ បើកុំតែបានចោគី

មកការពារ ទាហានទាំងពួងនឹងប្រមាថមើលងាយ ធ្វើអន្តរាយផ្សេង ៗ មិនខាន ឥឡូវ ខ្ញុំម្ចាស់នឹងលើកនាងកៀងសុំជាកូនប្រសា ឲ្យជាភរិយាហោកីចុះ ៗ បូឆក៏ឲ្យហៅខ្លួនចេញមក ឃើញនាងកៀងស៊ីមានរូបរាងល្អស្អាតគួរជាភរិយាហោកី ក៏រៀបចំឲ្យទៅរួមសុខ-ទុក្ខនឹងគ្នា បូឆក៏ឲ្យរៀបតែងតុ ជាតុមួយទៀតមានផ្កាភ្ញី សែនគំនាប់សពអូនសៀវ ហើយក៏យំសោកាល័យជាច្រើន ៗ ទីប្រឹក្សានឹងសេនាទាហានទាំងពួង ឃើញដូច្នោះក៏មានសេចក្ដីសង្ស័យ ទើបដំកបសួរបូឆថា លោកនឹងអូនសៀវធ្វើសឹកសង្គ្រាមជាប់ដៃនឹងគ្នាមក ឥឡូវលោកពយយកបានទាំងស្រុកគីជីវផង ហើយហេតុម្ដេច ក៏មកតែងគ្រឿងសែនគំនាប់ ជាសេចក្ដីពាប់អាន ហើយថែមទាំងយំយែករលឹកអាល័យអូនសៀវទៅវិញ ៗ

បូឆក៏ក្លែងឧបាយ ប្រាថ្នានឹងឲ្យទាហានទាំងពួង សរសើរចិត្តថ្លើមបូឆថាជាអ្នកមានសត្យានុសត្យពិតត្រង់ ហើយក៏ពណ៌នាសេចក្ដីថា កាលគ្រាតង់គុ តាំងខ្លួនជាមហាចបកដនោះ យើងនឹងអូនសៀវ ហើយនឹង៧ខេត្រ លើកកងទ័ព ទៅតាំងនៅ ក្រៅគយ៉ាស៊ុយគួន ដើម្បីនឹងកំចាត់តង់គុចេញ អូនសៀវក៏លបសួរយើងថា បើធ្វើសឹកសង្គ្រាមចាញ់តង់គុហើយ តើយើងនឹងទៅតាំងប្រមូលសេនាទាហាននៅទីតំបន់ណា ដើម្បីនឹងបានគិតការតទៅទៀត? យើងបានសួរអូនសៀវថា ខ្លួនអ្នកនឹងទៅនៅទីតំបន់ណា? អូន

សៀវប្រាប់យើងថា នឹងមកនៅខាងអាណាខេត្តទិសឧត្តរនេះ ព្រោះជាទីធំទូលាយ ទាំងស្បៀងអាហារក៏មានបរិបូណ៌ សេនាទាហានក៏ចំណានក្នុងការសឹកសង្គ្រាម នឹងបានគិតការធំតទៅ យើងក៏បានថាខ្លួនយើងនេះមិនរើសទីកន្លែងទេ ទោះទៅនៅទីដែនណាមានមនុស្សរាប់អានរួមចិត្តគំនិតគិតការជាមួយនឹងយើង ៗ ក៏នៅគិតការត្រង់ទីនោះ ទោះបីអ្នកសៀវនឹងយើងជាគូវិវាទ ធ្វើសឹកសង្គ្រាមនឹងគ្នាក្តី ក៏នៅជាកៀននឹងគ្នា មកពីដើម បានជាយើងនឹករឿងកំសត់អត់ស្រក់ទឹកភ្នែកមិនបាន ដោយមាននិស្ស័យដូច្នេះ ៗ

ទាហានទាំងពួង បានស្តាប់ប្អូនថាដូច្នោះ ក៏នាំគ្នាសរសើរថា ចិត្តមហាទបរាជមានសត្យានុស័ត្យពិតត្រង់ល្អមែន ៗ ប្អូនក៏ចាត់ចែងមាសប្រាក់គ្រឿងសម្លៀកបំពាក់ ឲ្យនាងឡៅជីជាភរិយាអ្នកសៀវជាច្រើនហើយ បង្គាប់ថាបណ្តាអាណាខេត្តខាងទិសឧត្តរនេះ អាណាប្រជារាស្ត្រមានសេចក្តីក្តៅក្រហាយ ព្រោះមានការសឹកសង្គ្រាមមកច្រើនឆ្នាំហើយ ក្នុងឆ្នាំនេះកុំឲ្យទារយកពន្ធសួយសារអាករឡើយ ៗ

លុះព្រឹកឡើង ខៅឡូវជិះសេះ ចូលទៅដល់ទ្វារស្រុក ទទួលជួបប្រទះនឹងខៅហ៊ុំ ៗ ក៏និយាយថា ទាហានទាំងអម្បាលនេះ បានមកនៅក្នុងស្រុកតីដាវ ក៏ព្រោះគំនិតរបស់យើងផ្តើមគិតឡើង ទើបបានស្រុកនេះ ៗ

ទៅធូតបថា ខ្លួនអញក៏ជាចោរហានមានថ្វីដៃដែរ បានទាំងតតាំងបង្វាំង ដោយកាយ ទំលាយចូលទៅវាំងអាវុធ ទើបបានស្រុក ហេតុម្តេច ក៏ឯង មកអួតអាងថា ស្រុកនេះបានដោយសារគំនិតរបស់ខ្លួនវិញ ។ ទៅ-ហ៊ីវតបថា ខ្លួនឯងមានថ្វីដៃក៏ពិតមែន តែអញផ្តើមគំនិតឲ្យ ទើបឯងធ្វើតាម ឧបមាដូចអញជានាយពៅហ្វាយបានប្រើឯង ។ ទៅធូឮដូច្នោះ ក៏ខឹងណាស់ ទើបហូតគ្រប៊ីចេញហើយក៏កាប់ផាច់ក្បាលទៅហ៊ីវស្លាប់ នៅទីនោះ ហើយយួរយកក្បាល ចូលទៅជំរាបចូធូថា ទៅហ៊ីវនិយាយ មើលងាយខ្ញុំបាទជាពាក្យទ្រគោះយ៉ាងធ្ងន់ ឥឡូវ ខ្ញុំបាទធន់មិនបានទេ សម្លាប់ស្លាប់ហើយគាត់យកតែក្បាលមកជូនលោក ។ ចូធូតបថា “ ទៅហ៊ីវនោះ ជាគៀនសំឡាញ់របស់យើងមកពីដើម ដែលវាហ៊ាន និយាយដូច្នេះ ព្រោះជាផ្លូវអួតអាងលើកកំពស់ ហេតុម្តេច បានជា ខ្លួនមិនពិគ្រោះឲ្យល្អិតល្អសិន ហ៊ានកាប់សម្លាប់ទៅហ៊ីវចេញ ដោយអំពើចិត្តឯងនោះមិនគួរទេ ” ហើយចូធូក៏ឲ្យគាត់ទោសទៅធូដាក់គុក ទើបឲ្យតែងការសពទៅហ៊ីវ ហើយក៏ឲ្យនាំទៅបញ្ចុះតាមទំនៀមប្រពៃណី ។

ខណៈនោះ ចូធូក៏ឲ្យទៅបញ្ចុះបញ្ចូលអ្នកមានជំរេះប្រាជ្ញា ដែលនៅក្នុងអាណាខែត្រទិសឧត្តរ ត្រូវទៀងស្តាប់បង្គាប់ស្រុកគីជីវ បានស៊ុយតាំទីប្រឹក្សាអួនសេ្យវ ដែលបាននិយាយឃាត់ហាមអួនសៀវមកពីដើម អួន

សៀវម៉ិនព្រមជឿស្តាប់ ស៊ុយតាំ ក៏ធ្វើជាឈឺចេញទៅនៅផ្ទះវិញ ។ ប្អូនបានស៊ុយតាំចូលមកក៏មានចិត្តសោមនស្សណាស់ តាំងស៊ុយតាំជាទីប្រឹក្សា ហើយប្អូនបានយកបញ្ជីមនុស្សចំណុះស្រុកគីងីវដែលមានគ្រួសារដល់ទៅ ៣០ ម៉ឺនប្លាយ ប្អូននិយាយថា ស្រុកគីងីវនេះជាខេត្តឯក មានមនុស្សក៏ច្រើន ៗ ស៊ុយតាំដំរាបថា ដែលមានបញ្ជីចំណុះស្រុកនោះក៏មែនហើយ តែដែលលោកនឹងទុកចិត្តថា មានមនុស្សគ្រប់តាមបញ្ជីនោះមិនបានទេ ព្រោះមានសឹកសង្គ្រាមមកច្រើនឆ្នាំហើយ មនុស្សស្លាប់អស់ច្រើនណាស់ ឥឡូវអ្នកថាំងនឹងអ្នកស៊ុងកំពុងតែច្បាំងគ្នា មនុស្សនានាក៏បែកបាក់ខ្ចាត់ខ្ចាត់ទៅគ្រប់ដំបន់ សូមឲ្យលោកប្រាបប្រាមឲ្យរាបទាបជាប្រក្រតី ហើយបញ្ចុះបញ្ចូលឲ្យកូនស្រុកនៅជាសុខក្សេមក្សាន្ត ឯទាហាន ដែលបែកបាក់ទៅទាំងប៉ុន្មាន ក៏នឹងវិលត្រឡប់ចូលមកទីពឹងលោកវិញ ។ ប្អូនយល់ឃើញត្រូវ ក៏គិតធ្វើតាមពាក្យស៊ុយតាំនិយាយ ហើយក៏ឲ្យមនុស្សស្វែងទៅស្តាប់ដំណឹងអ្នកថាំងនឹងអ្នកស៊ុង ។

ឯអ្នកថាំង, អ្នកស៊ុង កាលប្អូនច្បាំងយកស្រុកគីងីវបាននោះ អ្នកថាំក៏លើកទ័ព ទៅវាយបានស្រុកកាំឡេង, ស្រុកហាំងបេង, ស្រុកពុតហៃ, ស្រុកហោក័ន ហើយកៀរប្រមូលទាហានយកឈ្លើយបានជាច្រើន លុះឮដំណឹងថា អ្នកស៊ុងរត់ពីប្អូនទៅលាក់ខ្លួនពួនអាត្មា នៅក្នុងព្រៃក៏លើកទ័ព

ជាប់តាមទៅ ឯអ្នកសុងក៏នាំទាហានទៅនៅនឹងអ្នកហ៊ុជាបង នៅស្រុកគុំ-ដីវ អ្នកថាំក៏មិនបានលើកទ័ពតាមអ្នកសុងទៅ ត្រឡប់លើកទ័ពវិលមកស្រុកពេងង៉ួនគួនវិញ ហើយក៏គិតថា ឥឡូវ បូឆូវាយបានស្រុកគីដីវហើយ បើនឹងស្ងៀមព្រងើយទៅឃើញថា សាច់សាលោហិតញាតិសន្តាននឹងអាណាប្រជារាស្ត្រ នឹងបានសេចក្តីក្តៅក្រហាយ ចាំនឹងលើកកងទ័ពទៅច្បាំងទំលាយបូឆូ ដណ្តើមយកស្រុកគីដីវឲ្យបានមកវិញ ។

ខណៈនោះ មានបំរើសេះម្នាក់ចូលមកប្រាប់អ្នកថាំថា មហាទេពដឲ្យហៅខ្ញុនលោកទៅនិយាយការរាជការ ។ អ្នកថាំក៏និយាយនឹងអ្នកបំរើថា ខ្ញុនចូលទៅប្រាប់បូឆូវិញចុះថា យើងទៅជាក្រោយ ។ បូឆូឮដូច្នោះក៏ធ្វើសំបុត្រឲ្យបំរើសេះគាន់ទៅឲ្យទៀតជាសេចក្តីថា "ខ្ញុនយើងជាធំឲ្យហៅខ្ញុនអ្នកថាំមកនិយាយការរាជការផង អ្នកថាំហេតុម្តេច បានជាខ្ញុនរឹងទទឹងមិនចូលទៅ ឯបុត្រីយើងដែលថានឹងលើកឲ្យជាភរិយាខ្ញុនអ្នកថាំនោះឥឡូវយើងឈប់លែងឲ្យវិញហើយ " បូឆូក៏ចាត់ចែងទាហានជាច្រើនលើកទៅវាយស្រុកពេងង៉ួនគួន ប្រាថ្នាដើម្បីនឹងច្បាំងកំចាត់អ្នកថាំចេញ ។

ចំណែកអ្នកថាំដឹងដំណឹងក្នុងសំបុត្រនោះហើយ ក៏ដឹងថាបូឆូលើកកងទ័ពមកវាយទៀត អ្នកថាំក៏ធ្វើសំបុត្រឲ្យទៅដល់ឡៅប៉ៀវ ហៅហ្វាយស្រុកកេងជីវ សេចក្តីថា បូឆូលើកកងទ័ពទៅវាយ យកស្រុកគីដីវបានហើយ

ឥឡូវនឹងលើកទៅវាយយកស្រុកពេងជួនគួនទៀត ប្ដូរអ្នកក្រទេសកឃើញ ដល់ផ្លូវមេត្រីនៃយើង សូមឲ្យលើកកងទ័ពទៅជួយ ។

ឡៅបៀវឃើញសេចក្ដីសំបុត្រនោះហើយ ក៏ប្រឹក្សានឹងឡៅពីៗគប ថា ឥឡូវប្អូនលើកទ័ពទៅវាយយកអាណាខេត្រទិសឧត្តរ បានអស់ហើយ ក៏មានចិត្តកំរើកធំទ្រើងទៀតពន្ទុកណាស់ បណ្ដាបុត្រញាតិសាលោហិតបងប្អូនរបស់អ្នកសៀវទាំងប៉ុន្មាន បានរិះគិតតតាំងច្បាំងសងសឹកនឹងប្អូននោះ ឃើញថាមិនបានទេ គឺសែអ្នកទាំងប៉ុន្មាននោះឃើញថា ប្អូននោះសោតនឹងសក្ដិសក្ដិនចាប់យកខ្លួនកំទេចអស់ហើយ ឯចិត្តប្អូននោះសោតក៏មុខជានឹងលើកទ័ពមកញីញក់ធ្វើអន្តរាយដល់ស្រុកយើងថែមទៀត ដែលលោកនឹងលើកទៅជួយអ្នកថាំនោះឃើញថា មិនស្រួលទេ សូមឲ្យលោកបម្រុងទាហានទុកឲ្យមានកំឡាំងសិន បើប្អូនលើកទ័ពមកក៏នឹងបានការពាររក្សាស្រុកឲ្យគង់ ។

ឡៅបៀវយល់ឃើញត្រូវ, ក៏និយាយថា ដែលយើងមិនលើកទ័ពទៅជួយអ្នកថាំនោះ គេនឹងឲ្យមានសំបុត្រឆ្លើយតបទៅវិញថា ម្ដេចទើបបានស្រួល ? ឡៅពីថា ខ្លួនលោកជាធំត្រូវធ្វើសំបុត្រទៅជាទីរលឹកប្រដៅអ្នកថាំថា ការសង្គ្រាមមកដល់ហើយ ត្រូវតែបង់ចិត្តគិតស្ម័គ្រសមាគមបងប្អូន

☛ ( មានត )

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

( តមក )

## លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង

## ៣- មហាទោសៈនៃព្រះនាងអាមាតេរ៉ាស៊ូ

( អាទិទេវី នៃព្រះសូរ្យា )

ព្រះនាងអាមាតេរ៉ាស៊ូ ( អាទិទេវីនៃព្រះសូរ្យា ) ទ្រង់បានទទួលនូវមហាមេឃជាមតិក ពីព្រះបរមរាជបិតាអ៊ីសាណាគី, ព្រះអាទិទេពត្សុគីណូគាមី (អាទិទេពនៃព្រះចន្ទ) បានទទួលព្រះរាជអាណាចក្រ "និសា" ព្រះអាទិទេពស៊ុសាណូ ( អាទិទេពនៃវ៉ាយោ ) បានទទួលមហាសាគរ ដែលមានរលកប្រាំបីសែន ។

ព្រះនាងអាមាតេរ៉ាស៊ូជាព្រះអាទិទេវីនៃសូរ្យា ជានារីមានទ្រង់ទ្រាយប្រកបដោយសាច់ណែនពេញ មានកេសាវែង, មានព្រះនេត្រភ្លឺចាំង, មានព្រះរូបប្រកបដោយរស្មីធ្មុះភ្លឺប្រាលផ្ដៅ ។

ក្នុងពេលនោះ ទទួលមានបេសកៈនៃព្រះអាទិទេព មកដល់ភ្លាមចំពោះព្រះភក្ត្រនាង ហើយក្រាបបង្គំទូលព្រះនាងថា :

បពិត្រព្រះនាងដ៏ចំរើនអើយ, ទូលបង្គំខំតែមកក្រាបបង្គំទូលថា ព្រះ

រាមដែលជាអាទិទេពនៃអយោ បានហោះមកកាន់ព្រះរាជអាណាចក្រព្រះអគ្គិ៖ ព្រះរាមទ្រង់បន្លឺនូវព្រះសូរសីហនាទដ៏ខ្លួរខ្លារ ហើយគ្រវីព្រះខ័នគួរឱ្យខ្លាចពន់ពេក ៗ នៅតាមផ្លូវនៃព្រះរាជដំណើរព្រះរាម , អ្នកខ្លាចតក់ស្លុត, អ្នកណាក៏រន្ធត់ញាប់ញ័រពន់ពេក . . . មានគេសួរគ្នាថា ម្ដេចក៏ព្រះអាទិទេពស្ទុះទៅកាន់មហាមេឃ ចេញពីមហាសាគរផ្លូវបេះ ៗ

ព្រះនាងមាមាតេរាស៊ីទ្រង់កម្រើកប្រមោយ៉ាងញាប់សម្បើមអស្ចារ្យ ៗ ព្រះរាមព្រះអង្គតែងធ្វើឱ្យទ្រង់លំបាកជាច្រើនលើក៖ ឥឡូវនេះ៖ ព្រះរាមនេះទ្រង់កាន់តែធ្វើព្រះនាង ឱ្យតក់ស្លុតរន្ធត់ខ្លាំង៖ តើព្រះរាមនេះធ្វើព្រះរាជដំណើរមកកាន់ទីនេះដើម្បីអ្វី ? ៗ

ព្រះនាងទ្រង់មានព្រះបន្ទូលដោយព្រះអង្គឯងថា៖ ហេតុដែលព្រះរាមទ្រង់យាងមកកាន់ទីនេះ មិនមែនស្រួលទេ គឺប្រាកដជាមានរឿងមួយមិនខាន, ប្រហែលជាព្រះរាមចង់ដេញអញចេញពីព្រះរាជអាណាចក្រ, តែអញប្រុងប្រៀបស្រេចនឹងតស៊ូ ៗ

ព្រះនាងទ្រង់យាងទៅកាន់ទីដែលស្ថិតជិតមហាមេឃ ហើយប្រថាប់នៅមាត់ទីនោះ ៗ ព្រះនាងទ្រង់ទ្រង់ស្ពាយប្រអប់ពីរ ដែលដាក់សរជាច្រើន៖ ទ្រង់យកស្រោមដៃកមកស្រោបព្រះហស្តព្រះអង្គ, ទ្រង់បានកាន់ធ្នូធំសម្បើមអស្ចារ្យ យកទៅដាក់ពីមុខព្រះភក្ត្រព្រះនាង រួចទ្រង់ញែក

ព្រះធរណី ដូចគេញែកព្រឹលទឹកកកដូច្នោះ ទ្រង់ក៏ចុះទៅស្ថិតនៅត្រឹមព្រះឧរុ (ភ្លៅ) ។

ព្រះនាងប្រុងប្រៀបរួចជាស្រេច ដើម្បីតយុទ្ធ នឹងពួកបច្ចាមិត្តដោយសេចក្ដីក្លៀវក្លា ។

ឥឡូវនេះ, ព្រះរាមនៃព្រះនាងទ្រង់យាងមកដល់, មានសភាពគួរឲ្យខ្លាចតក់ស្លុតខ្ទត់អស់អង្គ, ត្រវិសក់វែងអន្លាយ ហើយបន្លឺព្រះសូរសីហនាទខ្ទរខ្ទារខ្ទាំង, ព្រោះហេតុដូច្នោះ បានជាគេសន្មត់នាមព្រះរាមថា "ព្រះបុរសឃោរឃៅ" ។ ព្រះរាមឈរប្រថាប់ជាត្រៀមនឹងម្ចាស់ នៃមហាមេឃ ។ ព្រះនាងអាម៉ាតេរាស៊ូទ្រង់ស្រែកថា:

ស៊ុសាណូ, ម្ដេចបងឯងមិនស្ថិតនៅដែនបងឯង ? ហេតុម្ដេចក៏បងឯងយាងមកកាន់ទីនេះ ដោយគ្មានអ្នកណាហៅកេសោះឡើយ ? ។

“ឱព្រះកនិដ្ឋា, បងមកនេះ ដើម្បីមកលេងកំសាន្ត” ហើយព្រះអាទិទេពក៏ទ្រង់ព្រះសម្រួល ។

ព្រះនាងទ្រង់នៅតែមិនទុកចិត្ត ។ ត្រូវតែស៊ុសាណូថ្លែងម្ដងទៀតបញ្ជាក់សេចក្ដីថា:

បងចង់ឃើញប្អូន, បងមកលេងនឹងប្អូន, នេះជាហេតុដែលបងមកកាន់ទីនេះ ។ ម្ដេចក៏មានការប្រុងប្រៀបគ្រឿងប្រដាប់សង្គ្រាមដូច្នេះ

ម្តេចក៏មានគ្រឿងសស្ត្រាវុធយ៉ាងនេះ ? ចូរអូនបំផ្លាញគ្រឿងសស្ត្រាវុធនេះចេញ ។ សន្តិភាពប្រសើរជាងការសង្គ្រាម ? ចូរយើងព្រមព្រៀងគ្នាទាំងពីរនាក់ ប្រកាសសន្តិភាព ហើយចូរយើងស្រឡាញ់គ្នា ដោយភាតរភាព ។

ស៊ុសាណូហុចព្រះខ័នថ្វារបស់ខ្លួន ទៅព្រះនាងអាម៉ាតេរ៉ាស៊ូ ទ្រង់ក៏យកព្រះខ័នថ្វានោះមកកាប់បំបាក់ជាបីកំណាត់ ។ ព្រះនាងទ្រង់បោះគ្រឿងសស្ត្រាវុធរបស់ខ្លួន ទៅថ្វាយព្រះពាយ ៗ ក៏ផ្លុំទៅលើ គ្រឿងសស្ត្រាវុធទាំងនោះ រលាយអស់គ្មានសល់ ។

ស៊ុសាណូនឹងត្រូវព្រះនាងទទួលទៅទីនោះជាភ្ញៀវកិត្តិយស ។ តែភ្ញៀវនេះ មានចរិយាមិនរម្យទម, ឃោរឃៅ, មិនមានសណ្តាប់ធ្នាប់សោះឡើយ ។

ព្រះអាទិទេពវាយោទ្រង់យាងទៅកាន់ទីណា, ទីនោះមិនអាចទប់ទល់នឹងវិនាសកាលបាន, វត្ថុទាំងឡាយតែងធ្លាក់ចុះរលួយអស់, របងដែលខាំងស្រែ រលំធ្លាក់បែកខ្ទេចខ្ទី, ដីធ្លាក់ពេញព្រែកដីកដែលសម្រាប់ធ្វើជាសាស្ត្រកសិកម្ម, សូម្បីតែប្រាសាទព្រះនាងក៏កម្រើកញាប់ញ័រទាំងអស់ ។

ព្រះនាងអាម៉ាតេរ៉ាស៊ូទ្រង់ព្រះក្រោធខ្លាំង តែទ្រង់លាក់សេចក្តីក្រោធនោះក្នុងព្រះរាជហឫទ័យ មិនឲ្យស៊ុសាណូជ្រាប ។

មានព្រឹត្តិការណ៍មួយថ្មី ធំសម្បើមអស្ចារ្យ ដែលនឹងបញ្ចេញសេចក្តីក្រោធព្រះនាងឲ្យផ្សាយមកក្រៅ ។

មានមួយថ្ងៃ, ព្រះនាងទ្រង់កំពុងគង់នៅបន្ទប់ដេរប៉ាក់អាវទេវតា. ទ្រង់មានព្រះនេត្រទំនៃត្រួតត្រានាងទេវធីតា កំពុងដេរប៉ាក់អាវសម្រាប់ពពួកទេវបុត្រ ទេវតានោះ, នាងខ្វះវៃអំបោះទិញ, នាងខ្វះត្បាញសំពត់ទិញ, នាងខ្វះប្រៀងសប្បាយ ក៏ស្រាប់តែឮសូរសព្ទគឹកកងរំពងជាខ្លាំង ដែលជាហេតុឲ្យនាងទាំងនោះឈប់ធ្វើការទាំងអស់គ្នាគឺ ពីលើតំបូលត្រង់បន្ទប់ដេរប៉ាក់នោះ មានកូនពាជីមួយដែលគេបកស្បែកអស់ ធ្លាក់មកក្រោម ។

ក្នុងពេលនោះ នាងទេវធីតាក្រោកឈរឡើង រត់ប៉ាត់ប៉ាយ នាងខ្វះម្ជុលចាក់ដៃរបួស, ចេញឈាម, នាងខ្វះទទួលអនិច្ចកម្ម ក្នុងពេលនោះ ។

នេះជាអាកប្បកិរិយាក់ប្លង់លេងសើច មិនសមគួរនៃអាទិទេពស៊ុសាណូ ។

ព្រះនាងអាមាតេរ៉ាស៊ូទ្រង់ទប់ទល់នូវព្រះក្រោធ លែងបានសោះឡើយ ហើយទ្រង់ក្តាប់ព្រះហស្ថ, សំដែងនូវព្រះកំហឹងជាយ៉ាងមហិមា ។ ព្រះនេត្រចេញផ្កាភ្លើង, ព្រះឃានញ័រជាខ្លាំង ។ ព្រះនាងទ្រង់បន្លឺនូវព្រះសូរសីហនាទសម្រេចថា នឹងលាក់បំពួនខ្លួនព្រះអង្គ បើអាទិទេពឯទៀតនៅតែអនុញ្ញាតឲ្យអាទិទេពស៊ុសាណូ ឋិតនៅលើព្រះពជអាណាចក្រព្រះអង្គ ។

ព្រះនាងទ្រង់យាងថយទៅប្រថាប់លើថ្មក្ដារមួយ ដែលបិតជិតព្រះបរមរាជវាំង; ទ្រង់បានលៃលកធ្វើឲ្យទ្វារគុហានោះជាប់មុតមាំ ។

ព្រះសូរ្យោអស្ដង្គត ។ នៅមហាមេឃនិងព្រះធរណីគ្មានរស្មីអ្វីសោះឡើយ គឺជាយប់ងងឹតសូន្យសុង ។

ពួកអាទិទេពសម្រេចថា នឹងប្រជុំគ្នានៅដើងក្លាយលើនភាល័យ ។ បន្ទិច មានអាទិទេពមួយរូបយាងមកដល់ បន្ទិចទៀតពីរ, រួចបី, បួន, ប្រាំ, ឥឡូវនេះ មានអាទិទេពចំនួនដប់រូប, មួយរយ, មួយពាន់, មួយម៉ឺន, មួយ-លាន ប្រាំបីលានរូប ។

អាទិទេពប្រាំបីលានរូប ទ្រង់យាងមកជួបជុំ នៅដើងក្លាយព្រុសរសព្វ ជួបសួររុយ ហើរពេលវស្សានរដូវដ៏ព្នាះ ។

ពួកអាទិទេពទាំងនេះ បានសន្ទនាគ្នានឹងគ្នាថា ត្រូវរកមធ្យោបាយយ៉ាងណា ដើម្បីឲ្យព្រះនាងអាមាតេរ៉ាស៊ូទ្រង់យាងចេញមកវិញបាន ។

ពួកអាទិទេពក៏ទូលស្នើទៅអាទិទេព ដែលប្រមូលចិន្ដា ទ្រង់ព្រះនាម តក មី-មុស៊ឹប ជាអាទិទេពឧបាយកល ។

អាទិទេព តក មី-មុស៊ឹប ទ្រង់មានបន្ទូលតបមកថា: "ប្រហែលជាបាន ព្រោះថា ព្រះនាងអាមាតេរ៉ាស៊ូចំណាំតែចេញពីប្រាសាទកាលណាព្រះនាងទ្រង់ឮមាន់រងាវ " ។

ក្នុងមួយរំពេច គេក៏យកបង្អោងឈើមកដាក់ហើយគេយកមាន់ដែលមានស្លាបរលើបរលង់ហើយមានកម្លាំង មកឲ្យទំលើបង្អោងនោះ ។

មាន់នោះក៏តាំងរងាវ តែគេមិនបានឃើញរស្មីព្រះសូរិយាដែលធ្លាប់តែតាំងពេលបច្ចូសសម័យសោះឡើយ ។ ព្រះនាងទ្រង់ក៏មិនបានចេញមកសោះ ។

អាទិទេពឧបាយកល ទ្រង់ក៏គិតធ្វើផែនការមួយផ្សេងទៀត ។ ទ្រង់ព្រះតម្រិះថា ព្រះនាងអាមាតេរាស៊ូភេទស្រី . . . បើប្រសិនជាធ្វើកិច្ចការអ្វីមួយ ដោយយកលំអជាបុព្វហេតុ នាំឲ្យទ្រង់មានព្រះរាជហឫទ័យច្រណែននឹងស្ត្រីណាមួយ ដែលមានរូបកាយល្អសមសួនជាងព្រះនាង ប្រហែលជាព្រះនាងចេញមកមិនខាន ។

ពួកអាទិទេពក៏ទ្រង់ចាត់ឲ្យហៅព្រះវិស្សកម្មទេវបុត្រ ដែលមានព្រះនេត្រតែមួយ, ហើយត្រាស់បង្គាប់ឲ្យធ្វើកញ្ចក់មួយ ដែលគេយកទៅបញ្ឈរចំពីមុខគុហាជិតក្លោងទ្វារចូលប្រាសាទព្រះនាង ។ នៅពីលើកញ្ចក់នោះគេយកខ្សែកនឹងផ្កាយឯទៀតព្រមទាំងព្រះពស្ត្រ, ទៀវមកដាក់ ។

នៅជិតគុហានោះ, គេបានយកក្តារមកក្រាលលើដីមាំរឹង, ហើយគេចាត់ឲ្យនាងទេវធីតាអ៊ុហ្សុមេរាំនៅលើនោះ ។

តើគេនឹងឃើញរស្មីព្រះសូរិយាចាំងពីក្នុងគុហាមកឬ ? ឬក៏ព្រះនេត្រ

នៃពួកអាទិទេពមិនធ្លាប់ឋិតនៅក្នុងទីងងឹត ។ ។

តែពួកអាទិទេពទាំងអស់ទ្រង់ទតទៅឃើញព្រះនាងអាមាតេរាស៊ូដែរ, ហើយទ្រង់មានព្រះរាជហឫទ័យសោមនស្សជាមុន បើប្រសិនជាទ្រង់ទតទៅឃើញព្រះភក្ត្រព្រះនាងមូល, ក្តៅសប្បាយ, ថ្ពាល់ធំ មានសភាពរាងរៀបតូច ។

នៅលើដើមម៉ាវែង នាងទេវធីតាអ៊ុហ្សមេក ។ នាងក៏មានលំនាំគួរឲ្យសើច សប្បាយរីករាយពន់ពេក ។ ពួកអាទិទេពទ្រង់លេងកំសាន្តសប្បាយ ។ គេបានឮសូរស័ព្ទព្រមទាំងសំណើច នៃពួកអាទិទេពដែលធ្វើឲ្យដើមក្លាយកក្រើកអំពើកជាខ្លាំង ។

ព្រះនាងអាមាតេរាស៊ូទ្រង់ព្រះសណ្តាប់នូវសំណូរគឹកកងរំពងដូច្នោះ មានព្រះរាជហឫទ័យឆ្ងល់ពន់ពេក, ទ្រង់ចង់ជ្រាបណាស់អំពីរឿងរ៉ាវ ដែលមានក្នុងពេលនោះ ។ ទ្រង់ក៏បើកទ្វារគុហានោះឡើង, មិនទាន់បានទតមកក្រៅផង ទ្រង់ក៏មានព្រះសូរសីហនាទថា :

" ខ្ញុំគិតថា ការដែលខ្ញុំធ្វើដំណើរទៅនេះ នាំឲ្យលោកអ្នកព្រួយបារម្ភខ្លាំង, តែមិនដូច្នោះ, ទៅជាលោកអ្នកសប្បាយចិត្តទៅវិញ ។ ឱពួកអាទិទេពទាំងប្រាំបីលានរូប, លោកទាំងអស់គ្នា ម្តេចក៏ទៅជាសើចក្អាកក្អាយសប្បាយទៅវិញ " ។

(មានត)

# រឿងអ្នកគង្វាលចៀមចិត្តស្លូតត្រង់នឹងព្រះរាជធីតា

លោក ផែង-ជ្រីវ នៅក្រសួងឃោសនាការជាតិ

ប្រែតាមសៀវភៅ កុងត៍អេឡេសង់ដ៍ ដឺរូមានី

( តមក )

( Contes et Légen des deRoumanie. )

---

ចំណែកអ្នកគង្វាលយើងក៏ឡើងទៅទៀត ៗ លុះទៅដល់ត្រង់កន្លែងកំពូលចុងទៀប មាណពស្រាប់តែជួបជាស្ថិតនៅក្នុងប្រាសាទកែវមួយ ហើយនឹកក្នុងចិត្តថា: ហ្នឹងហើយ ប្រាកដជាលំនៅរបស់ព្រះយមរាជ ៗ អើផ្លែមាសអើនុ៎ះ ! និយាយផង បេះផង ៗ លុះយកផ្លែទៀបដាក់ក្នុងហោប៉ៅហើយ ក៏សំរូតចុះមកវិញ ៗ

ប៉ុន្តែ ខណៈនោះ ការវញ្ញូយកម្រើកតាំងពីចុងរហូតដល់គល់ទៀប ផែនដីញាប់ញ័ររបណ្ដាយ ហើយសូរសព្ទយ៉ាងខ្លាំងនោះ ក៏ឮដល់ព្រះសោតនៃព្រះយមរាជ ។ ស្ទុះហោះមកវិញ ដេញតាមកិតពីក្រោយខ្នង ៗ គេក៏យញាក់ដូចគ្រុន តែមិនព្រមលះបង់ចោលផ្លែទៀប ហើយសូមអង្វរថា: បពិត្រព្រះអង្គជាអម្ចាស់ . សូមព្រះគុណមេត្តាអត់ទោស ដល់ខ្ញុំម្ចាស់

សូមព្រះគុណប្រទានផ្លែទៀបទាំងនេះឲ្យខ្ញុំម្ចាស់ . . . . . ។ ព្រះចៅរាជា-ធិរាជនឹងព្រះរាជធីតា មិនដឹងជាទ្រង់អត់សង្កត់ព្រះរាជហឫទ័យ ដើម្បីចាំមើលផ្លូវ ខ្ញុំម្ចាស់យ៉ាងណាទេ !

- ណ្ហើយអ្នកកំឡោះប្ដូរយកចុះ ដ្បិតឯងចេះនិយាយតន្ត្រអញជោយត្រឹមត្រូវល្អ ! អញឲ្យផ្លែនេះដល់ឯង ហើយប្ដូរផ្លែទៀបជួយឲ្យឯងបានសេចក្ដីសុខសួស្ដី ។

អ្នកកល់គ្នាឃើញថាទេ សូម្បីព្រះយមរាជដែលជាទេវតាមិនដែលអត់ទោសឲ្យដល់អ្នកណាម្នាក់ គង់មិនអាចទប់នឹងសេចក្ដីអន្ធរបស់អ្នកគង្វាលចិត្តស្លូតត្រង់ ហើយអ្នកកំឡោះក៏ចុះមកទៀត ចំណែកព្រះយមរាជត្រឡប់ទៀងទៅកាន់ប្រាសាទកែវវិញ ឈប់សម្រាកមួយស្របក់ មុននឹងត្រាច់ទៅរកកត់បញ្ជីក្នុងដីដទៃទៀត ។

អ្នកគង្វាលចិត្តស្លូតត្រង់ ចូលទៅកាន់សំណាក់លោកតាព្រះកេតុនិយាយអរគុណចំពោះលោក រួចសូមលាលោកចុះមកទៀត ទាំងទឹកភ្នែករហាម ៗ តមក គេបានដល់សំណាក់យាយព្រះសៅរ៍ យកសេះទាំងពីរ ហើយនាំទាំងនាងក្រមុំយកមកផង ៗ លុះដល់សំណាក់យាយព្រះសុក្រ គេចូលលាគាត់ហើយចុះមកទៀត រហូតដល់ព្រះបរមរាជវាំងនៃព្រះចៅ ។

វេលាដែលមុនទឹងចុះដល់ដី គេឲ្យកូនស្រីរបស់យាយព្រះសៅរ៍ នឹងសេះលោកហក់ទៅឈប់ចាំឯក្នុងព្រៃមួយឆ្ងាយបន្តិច ចំណែកខ្លួនចុះជាមួយនឹងសេះមួយរហូតមក ។

បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមព្រះអង្គស្តេចទតចុះ ទឹកក្នុងកែវតែមានរទិតអ៊ីបន្តិច ហើយនេះផ្លែទៀបមាស សូមព្រះអង្គទតដោយព្រះហឫទ័យរីករាយ ។

ព្រះចៅពាលាធិរាជ ស្តេចទតផ្លែទៀបមាស ដោយព្រះទ័យស្នេហាព្រមទាំងអ្នកគង្វាលចៀម ដែលទ្រង់ឈប់សំគាល់ទុកជាអ្នកគង្វាលសាមញ្ញ គឺទ្រង់ទុកជាមនុស្សដែលផុតវិស័យនឹងគិត ហើយទ្រង់មានព្រះបន្ទូលថា: ចំជាអស្ចារ្យមែន នេះគឺជាអព្ភូតបុព្វហេតុ ! ។

ព្រះចៅពាលាធិរាជ ព្រះរាជធិតា ព្រះរាជអគ្គមហេសី និងព្រះរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី ដែលនឹកស្មានថា អ្នកគង្វាលប្រហែលជាស្លាប់បាត់ជាយូរណាស់ទៅហើយ ស្រាប់តែនាំគ្នាកោតសរសើរ នូវកិច្ចការដែលគេបានបំពេញដោយមិនចតនេះ ។ ប៉ុន្តែអ្នកដែលសប្បាយជាងគេតើគឺអ្នកណា? យើងអាចទាយត្រូវតែពីបាកទេ ។ អ្នកគង្វាលក្រាបទូលថា:

បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ឥឡូវនេះ សូមព្រះអង្គទ្រង់នូវពាក្យសត្យ ហើយសូមព្រះទាននូវព្រះរាជដីកាដល់ទូលព្រះបង្គំ ។

គេក៏ឲ្យព្រះអង្គម្ចាស់ក្សត្រីដល់អ្នកគង្វាល តើគេនឹងនៅវាំអ្វីទៀត ។

មិនយូរប៉ុន្មាន អ្នកគង្វាលលើកព្រះរាជដីកាដាក់លើខ្នងមនោម័យ ហើយហោះទៅកាន់ព្រៃ ដែលកូនយាយព្រះសៅរនៅនៅរង់ចាំក្នុងទីនោះ ។ រូបអ្នកទាំងអស់គ្រាប់ទៅជាមួយគ្នា ទៅកាន់សំណាក់អ្នកគង្វាលជាបងដែលតាំងពីបីឆ្នាំមកហើយ តែងធ្វើបុណ្យនឹងសូត្រធម៌ឧទ្ទិសផលជូនដល់វិញ្ញាណក្ខន្ធរបស់ប្អូន ដែលគាត់ស្មានថាជាធ្វើមរណកាលរូបទៅហើយឯក្នុងព្រះបរមរាជវាំង ។

លុះឃើញប្អូនទៅដល់ មុនដំបូងបងយកដៃជូតភ្នែក ដោយស្មានថា ខ្លួនដេកយល់សប្តិ ។ រួចគាត់តាំងតែស្រែកហៅ ស្ទុះទៅឱបប្អូនដោយសេចក្តីត្រេកអររកអ្វីប្រៀបគ្មាន ។ គាត់ស្មានថាជាក្បាលរបស់ប្អូនគាត់ទៀងតែគេដោតនៅឯចុងបង្គោលរបងទៅហើយ ។ បងសួរថា: ចុះពីមុនឯងនៅឯណា ? ក្នុងរវាងពេលនោះតើឯងធ្វើអ្វី ? រឿងនេះត្រូវតែនិយាយប្រាប់គាត់ឲ្យសព្វគ្រប់ ប៉ុន្តែប្អូនបានសម្រេចថា : បពិត្រអ្នកបង ណ្ហើយឈប់ពិយារប់រឿងហ្នឹងសិនចុះ ។ តើអ្នក

បងបានជួយថែរក្សាចៀមរបស់ខ្ញុំបានផងឬទេ ? ចំណែកខ្លួនខ្ញុំៗ បាននាំប្រពន្ធមួយមកជូនអ្នកបង រូបគេបង្ហាញកូនស្រីយាយព្រះសៅរ៍ ហើយនាងក៏មិនមានសេចក្ដី យល់តាស់ឡើយ ។

គ្រានោះអ្នកទាំងអស់ពេញដោយសេចក្ដីរីករាយតែសព្វខ្លួន ក៏នាំគ្នាវិលទៅកាន់ព្រះបរមរាជវាំងវិញ ។ ហើយមង្គលការអាពាហ៍ពិពាហ៍របស់បងប្អូនទាំងពីរ ក៏កើតឡើងក្នុងព្រះបរមរាជវាំង ដែលអ្នកទាំងពួងតែងនាំគ្នានិយាយតៗមក ។

ចប់ ។

ខ្មាសគ្រូគ្មានវិជ្ជា ខ្មាសភរិយាពុំមានកូន
ខ្មាសការងារសោះសូន្យ ខ្មាសបងប្អូនគ្មានភៀរឡើង
ខ្មាសទាសខានប្រើការ ខ្មាសអាហារពោះក្រៀមក្រើង
ខ្មាសយសស័ក្ដិពុំថ្កើង ខ្មាសអ្នកយើងខានធ្វើបុណ្យ
ខ្មាសបារីគ្មានអាជ្ញា ខ្មាសមុសាលក់ខាតទុន
ខ្មាសសិស្សខានដើរមុន ខ្មាសព្រះគុណខានធ្វើកាប
ខ្មាសកូនខានប្រដៅ ខ្មាសញាតិផៅសៅអំណាប
ខ្មាសខ្លៅទើបគេខ្លាប ខ្មាសអ្នកប្រាជ្ញបោរព្រើលធំ ។

*ពាក្យព្រេងតែងប្រតិស្ឋ ប្រដៅសិស្សដោយនិយម*
*និយាយតាមបរម បុរាណថាទុកដូច្នេះ ។*
*ឯពាក្យគ្រូអាចារ្យ បំណងការឲ្យសិស្សចេះ*
*ចង់ឲ្យមានចំណេះ ចង់ឲ្យចេះតែគ្រប់គ្នា ។*

# រឿងចៅបាយក្ដាំង

## លោក ទៀង តែ-ឈុន

ប្រែរៀបរៀង ( តមក )

---

ប្រាក់មួយផង លុះបន់ស្រន់រួចស្រេច, ចៅបាយក្ដាំងយកកែវមណីជាតិគ្រវីមួយជុំហើយពោលថា សូមឲ្យលោកម្ចាស់ជួយបំផុះវត្ថុខាងលើនេះតាមបំណងខ្ញុំ! ។

កាលណោះ ចៅបាយក្ដាំងគ្រវីត្បូងទិព្វបានបីជុំ, ស្រាប់តែកើតស្ពានមាស-ប្រាក់មួយនិងប្រាសាទមាសមួយយ៉ាងត្រចះត្រចង់អស្ចារ្យ ។

ចៅបាយក្ដាំងសប្បាយរីករាយឥតឧបមា ដោយយល់ឃើញថា ខ្លួនចង់បានរបស់អ្វី, របស់នោះផុះឡើងដូចសេចក្ដីប្រាថ្នា ហើយដើម្បីពិសោធន៍មើល, ចៅបាយក្ដាំងនិយាយថា ឱលោកម្ចាស់, ខ្ញុំចង់ឲ្យរបស់ទាំងនេះរលាយបាត់ទៅវិញ ។

បន្ទាប់មក, ប្រាសាទមាស និងស្ពានមាស ប្រាក់ក៏បាត់អស់ទៅវិញដូចបំណងមែន ។

លុះយប់ស្ងាត់ពិតប្រាកដហើយ ចៅបាយក្តាំងដើរដម្រង់ទៅរកព្រះបរមរាជវាំង ទិសខាងជើង ។ នៅទីនោះ ចៅបាយក្តាំងបួងសួងសុំឲ្យកើតប្រាសាទមាសមួយ និងស្ពានមាស-ប្រាក់មួយផង ដោយគ្រវីកែវមណីជាតិបីដុំដូចលើកមុន ។ ពេលនោះស្ពាននិងប្រាសាទកើតឡើង មានរស្មីភ្លឺព្រោងព្រាតពាសពេញផ្ទៃមេឃ ។

វត្ថុអស្ចារ្យទាំងនេះកើតមានស្រេចអស់ហើយ, ចៅបាយក្តាំងត្រឡប់មកផ្ទះដេកវិញ ។

លុះថ្ងៃព្រឹកស្អែក, ព្រះរាជាទ្រង់បើកបង្អួច ហើយទតទៅទិសខាងជើងព្រះបរមរាជវាំង ឃើញប្រាសាទមាស និងស្ពានមាសប្រាក់ ពេលរស្មីត្រចះត្រចង់ពាសពេញផ្ទៃមេឃដូច្នោះ, ព្រះអង្គទ្រង់ចាត់ព្រះរាជបំរើម្នាក់ទៅស៊ើបសួរពីវត្ថុអស្ចារ្យនេះ ។

ព្រះរាជបំរើត្រឡប់មកទូលព្រះរាជាថា សូមទ្រង់មេត្តាប្រោស, គ្មានអ្នកណាដឹងរឿងដែលប្រាសាទមាស និងស្ពានមាសប្រាក់ ដែលផុះមកនេះទេ ។

តមកទៀត, ព្រះមហាក្សត្រិយ ទ្រង់ត្រាស់បង្គាប់ឲ្យហៅដូនពាស់មកហើយ ទ្រង់មានព្រះបន្ទូលថា នែយាយ, កាលណោះខ្ញុំបានដាក់កំហិតឲ្យចៅយាយធ្វើតាមបំណងខ្ញុំដែលខ្ញុំស្មានថា មិនអាចនឹងធ្វើឲ្យសម្រេច

បាន ៗ ឥឡូវនេះ រាប់ទេវនិម្មិតកើតបានក្តែទាំងនេះដោយសាររាប់ទេវ មន្តអាគម ៗ បើដូច្នេះ យាយទៅហៅទៅយាយមក, ខ្ញុំផ្សំផ្គុំនឹងកូនស្រីខ្ញុំ ៗ កាលបើឮព្រះរាជឱង្ការហើយ, ជូនតាសក់តែទៅប្រាប់ទៅយាយក្តាំង នៅពេលនោះ ព្រះរាជាទ្រង់ត្រាស់បង្គាប់ ទៅរដ្ឋមន្ត្រី ឲ្យរៀបចំសង់រោងធ្វើអាពាហ៍ ពិពាហ៍ ៗ

លុះដល់ថ្ងៃកំណត់ចូលរោង, ព្រះមហាក្សត្រទ្រង់ត្រាស់បញ្ជាព្រាហ្មណ៍នឹងបុរោហិត ឲ្យទៅប្រសិទ្ធពរដល់ទៅយាយក្តាំង នឹងព្រះអង្គម្ចាស់ក្សត្រី ជាទីបង្ហើយកិច្ចនៃអាពាហ៍ពិពាហ៍ ៗ

បន្ទាប់មក, ទៅយាយក្តាំងតាក៏បរើទៅនាំយាយ, ឆ្កែ, នឹងឆ្មាមកនៅប្រាសាទអស្ចារ្យនេះជាមួយគ្នា ដោយសុវត្ថិភាព ៗ

មានកាលថ្ងៃមួយ, មានស្តេចមួយព្រះអង្គ មានព្រះចិន្តាប្រាថ្នានឹងប្រទេសខ្មែរ, ព្រោះប្រទេសនេះមានប្រាសាទនឹង ស្ពានល្អអស្ចារ្យណាស់ៗ កំពែងព្រះបរមរាជវាំងធ្វើសុទ្ធតែអំពីមាសនឹងប្រាក់ ហើយដាំពេជ្រទាំងអស់ ៗ ស្ពានក៏ល្អដូច្នោះដែរ ៗ ជាហេតុឲ្យព្រះរាជអាណាចក្រកម្ពុជារុងរឿងនឹងសប្បាយសម្បូណ៌ ដោយភោគសម្បត្តិ ប្រកបដោយកិត្តិសព្ទយ៉ាងក្រៃលែង ៗ ប្រជារាស្ត្រស្គាល់តែសេចក្តីសុខសាន្តនឹងសិរីសួស្តី ៗ

ស្ដេចប្រាំណៃនេះ, ទ្រង់ត្រាស់បញ្ជារដ្ឋមន្ត្រីឲ្យផ្គត់ផ្គង់គ្រឿងសាស្ត្រាវុធគ្រប់មុខ មានកាំភ្លើងធំជាដើមពេញកប៉ាល់សមុទ្រ ហើយលើកកងទ័ពមកវាយប្រទេសខ្មែរ ដែលកំពុងស្គាល់តែស្ដេចក្ដីសប្បាយសម្បូណ៌ ដោយភោគសម្បត្តិយ៉ាងអស្ចារ្យ ដើម្បីបង្ក្រាបព្រះរាជអាណាចក្រនេះយកធ្វើជាស្រុកចំណុះប្រទេសព្រះអង្គ ។

លុះកប៉ាល់ចម្បាំងបានបោះយុថ្កានៅក្នុងប្រទេសខ្មែរហើយ ស្ដេចប្រាំណៃទ្រង់ចាត់ដោយរួសរាន់នូវទូតម្នាក់ ឲ្យទៅបង្គំព្រះរាជាខ្មែរ ដើម្បីឲ្យទទួលស្គាល់ព្រះអង្គជាអធិរាជ ។ ព្រះអង្គទ្រង់យកសារលិខិតចុះបូលដែលសរសេរលើបន្ទះមាស ទៅថ្វាយស្ដេចបព្វាមិត្របំពោះព្រះភក្ត្រ ។ បើព្រះរាជានេះទ្រង់មិនព្រមទេ, ស្ដេចប្រាំណៃនឹងរៀបចំធ្វើចម្បាំង ។

កាលណោះ, ស្ដេចខ្មែរទ្រង់មានព្រះចិន្តាទុក្ខព្រួយយ៉ាងខ្លាំង, ព្រះអង្គទ្រង់ត្រាស់បញ្ជាឲ្យរដ្ឋមន្ត្រី និងនាយទាហានទាំងអស់ ឲ្យមកគាល់ព្រះអង្គ ហើយទ្រង់មានព្រះបន្ទូលថា លោកទាំងឡាយ! ឥឡូវនេះ ប្រជារាស្ត្ររបស់ស្ដេចប្រាំណៃនឹងប្រទេសយើង ដែលមានទ្រព្យសម្បត្តិច្រើន បានកាន់អាវុធគ្រប់គ្នាមកបង្ក្រាបយើង ឲ្យចុះចូលតែម្ដង ។ បើយើងមិនសុខចិត្តចុះចូលទេ, ត្រូវតែយើងធ្វើចម្បាំង ។ ដូច្នេះ, ក្នុងចំណោមពួកយើងទាំងអស់គ្នា, មានលោកណាម្នាក់ មានសមត្ថភាពអាចហ៊ានលើកទ័ពទៅច្បាំង នឹង

បច្ចាមិត្រ ឬទេ? ។ ពេលនោះ, គ្មានទាហានណាមួយ ហ៊ានធានាអះអាងនឹងចាត់ការនេះឡើយ ។

បន្ទាប់មក, ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យទៅនាំចៅបាយក្លាំងមក ហើយមានព្រះបន្ទូលថា: កូនជាទីស្នេហា, ឥឡូវនេះ មានស្តេចបច្ចាមិត្រមួយព្រះអង្គ បានលើកទ័ពមកវាយដណ្តើមយកនគរយើង, ឯងមានសមត្ថភាពនឹងធ្វើចម្បាំងនោះបានឬទេ? ។ ចៅបាយក្លាំងក្រាបទូលទៅព្រះបរមរាជបិតាក្មេកថា: សូមទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំបន់ច្បាំងដោយពិត ។

- កូនឯងត្រូវការទាហានប៉ុន្មាននាក់? ។

- ទូលព្រះបង្គំជាខ្ញុំមិនត្រូវការទ័ពទេ ។ ទូលព្រះបង្គំជាខ្ញុំច្បាំងតែម្នាក់ឯង ។

- យីអើ! កូនសំឡាញ់! ឯងគិតតយុទ្ធនឹងទ័ពគេច្រើនយ៉ាងនេះ តែម្នាក់ឯង ហើយឲ្យមានជ័យជំនះថែមទៀត? ។

- សូមទ្រង់ព្រះមេត្តាប្រោស ព្រះអង្គកុំព្រួយព្រះទ័យពីទ័ពគេច្រើននោះឲ្យសោះ ។

បន្ទាប់មក, ចៅបាយក្លាំង លំអុតកាយថ្វាយបង្គំលា ព្រះបរមរាជ

បិតាក្មេក ហើយត្រឡប់ទៅប្រាសាទទិព្វវិញ ដើម្បីរៀបចំទៅច្បាំង ។ មុននឹងចេញទៅ, ចៅបាយក្តាំងសំបួងសួងនឹងបន្ទីលកែវមណីជោតិ ស្រាប់តែកើតមានទ័ពយ៉ាងច្រើនក្រាម មានកាំភ្លើងធំតូចគ្រប់បែបគ្រប់យ៉ាង ។ ចៅបាយក្តាំងនាំទ័ពទិព្វទាំងនេះទៅច្បាំង នឹងទ័ពរបស់ស្តេច-ប្រៃណន។

ទ័ពបច្ចាមិត្របរាជ័យ ក៏ថយអស់ទៅ ។ ចៅបាយក្តាំងទៅព្រះបរមរាជវាំង ក្រាបបង្គំទូលព្រះបរមរាជបិតាក្មេកថា ខ្ញុំច្បាំងមានជ័យជំនះហើយ ។ ឯទ័ពសត្រូវក៏បាក់បែកខ្ចាត់ខ្ចាយ ថយទៅបាត់អស់ឥតមានសេសសល់ឡើយ ។ លុះបានដំណឹងថា កងទ័ពសត្រូវបាលចាញ់គេជដៃរត់បាត់អស់ទៅហើយ, ព្រះរាជាទ្រង់មានព្រះរាជហឫទ័យត្រេកអរយ៉ាងក្រៃលែង ។ ចៅបាយក្តាំងក្រាបបង្គំលាព្រះបរមរាជបិតាក្មេកត្រឡប់ទៅប្រាសាទទិព្វវិញ ។

កាលណោះ, ស្តេចសត្រូវទ្រង់គិតក្នុងព្រះចិន្តាថា "ខ្មែរដែលមានអនុភាពយ៉ាងដូច្នេះ ដោយសារមានកែវមណីជោតិពិតប្រាកដ" ។

ស្តេចប្រៃណន កាលបើព្រះអង្គទ្រង់ត្រិះរិះយ៉ាងនេះហើយ ទ្រង់ត្រាស់ចាត់ព្រះរាជបំរើម្នាក់ដោយរួសរាន់ ឲ្យទៅសូមធ្វើជាអ្នកបំរើចៅបាយ

ក្កាំង ដើម្បីនឹងលួចយកត្បូងទិព្វ ។

លុះចូលបំរើបានបន្តិចទៅ, ចៅពញាយក្កាំងមានសេចក្ដីទុកចិត្តលើព្រះរាជបំរើនោះយ៉ាងពេញលេញ ហើយក៏ប្រគល់កែវមណីជោតិឲ្យថែរក្សា ។

ព្រះរាជបំរើនេះគិតថា "ព្រះអង្គដែលជាចៅហ្វាយអញ ទ្រង់ផ្ដាំថា ឲ្យយកកែវមណីជោតិ ទៅថ្វាយព្រះអង្គឲ្យបាន, ឥឡូវ គេឲ្យអញថែរក្សារតនវត្ថុនេះ, បើដូច្នេះអញលួចកែវនេះ យកទៅថ្វាយព្រះអង្គបានដោយងាយ" ។ ដំណើរនេះហើយបានជា ព្រះរាជបំរើរបស់ស្ដេចសត្រូវនឹងស្ដេចខ្មែរ លួចបានយកកែវមណីជោតិ ពីចៅពញាយក្កាំងទៅថ្វាយព្រះមហាក្សត្រ ដែលជាចៅហ្វាយខ្លួន ។ កាលបើបាន ត្បូងពេជ្រនេះស្ដេចបច្ចាមិត្ត ទ្រង់មានព្រះរាជហឫទ័យសប្បាយរីករាយយ៉ាងក្រៃលែង ហើយទ្រង់លើកទ័ពទៅវាយដណ្ដើមព្រះរាជអាណាចក្រ របស់ចៅពញាក្កាំងម្ដងទៀត ។ ចៅពញាយក្កាំងបរាជ័យ, ស្ដេចសត្រូវទ្រង់ចាប់ស្ដេចខ្មែរនឹងអគ្គមហេសី ព្រមទាំងប្រជាជនជាច្រើន យកទៅធ្វើជាឈ្លើយសង្គ្រាម ។ ប៉ុន្តែ កាលណោះ ចៅពញាយក្កាំងរត់រួច ។ ចៅពញាយក្កាំង ហៅនែកនឹងត្មាមកជិត ហើយនិយាយថា នែក្មប្អូន! ត្មាប្អូន កាលៈទេសៈនេះ ឯង

ទាំងពីរនាក់ត្រូវជួយអញ ។ បើកាលណាអញបានធ្វើស្តេច, អញតាំងម្នាក់ឲ្យធ្វើរដ្ឋមន្ត្រីទ័ពជើងទឹក, ម្នាក់ទៀត អញឲ្យធ្វើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ អញទុកចិត្តលើឯងទាំងពីរ ដើម្បីទៅយកកែវមណីជោតិ ដែលស្តេចបច្ចាមិត្តបានលួចយកទៅ ដោយសារតែត្បូងទិព្វនេះហើយ ទើបស្តេចនេះច្បាំងឈ្នះយើងដូច្នេះ ។

ឆ្កែនិងឆ្មាឆ្លើយថា: កុំព្រួយឲ្យសោះ យើងខ្ញុំទៅយកកែវនោះឲ្យបានភាមបន្ទាប់ ។

បន្ទាប់មក, ឆ្កែនិងឆ្មានាំគ្នាទៅទាំងពីរនាក់ ។ លុះទៅដល់មាត់សមុទ្រ, ក៏ឃើញក្រពើកំពុងហែលទឹក ។ ឆ្កែនិងឆ្មាបន្លូកហៅក្រពើ ហើយនិយាយថា: អ៊ំបងក្រពើ, អាណិតបម្លងយើងទៅត្រើយម្ខាងផង ។ ក្រពើព្រម ។ នៅពេលកំពុងឆ្លង, ឆ្កែដែលអង្គុយលើក្បាលក្រពើភិតភ័យខ្លាំងពេក ក៏លេបអាចម៍លើកញ្ចឹងកដំនេះវា ។ លុះបានដល់ទៅមាត់ច្រាំងសមុទ្រម្ខាងហើយ, ឆ្កែនិងឆ្មាលោតទៅលើដី ហើយអង្វរក្រពើឲ្យនៅរង់ចាំគេមកទៀត, ឆ្កែ និង ឆ្មា នាំគ្នាដើរតម្រង់ទៅរកព្រះបរមរាជវាំងនៃស្តេច ដែលលួចកែវមណីជោតិ ។ នៅតាមផ្លូវ ឆ្មាគិតតែម្នាក់ឯងថា "ឆ្កែវាចេះតែរកអាហារក្រោមខ្ញុំប៉ុណ្ណោះទេ" ។

លុះពេលយប់ឆ្មាដើរក្រឡឹងជុំវិញមហាប្រាសាទ ស្រាប់តែប្រទះឃើញស្តេចកណ្តុរសប្រែងមួយ កំពុងស្វះស្វែងរកអាហារ ៗ ឆ្មាស្ទុះដោយលាក់លៀមទៅចាប់កណ្តុរនោះបាន ៗ ស្តេចកណ្តុរនោះអង្វរឆ្មាថា: ឱបងឆ្មា, បើបងស៊ីខ្ញុំ តើនឹងបានឆ្អែតប៉ុន្មានថ្ងៃ? ទុកអាយុជីវិតខ្ញុំផង កាលណាបងមានទុក្ខធុរៈអ្វី ៗ ខ្ញុំធានាអះអាងនឹងជួយដោះស្រាយទុក្ខធុរៈនោះ ៗ ឆ្មាឆ្លើយថា: ហ្ហើយចុះម្ចាស់កណ្តុរស, បើឯងជួយយកកែវមណីជាតិរបស់ចៅហ្វាយអញ ដែលស្តេចទីក្រុងនេះលួចមកនោះ អញនឹងលែងឯងឲ្យរស់ជីវិត ៗ អញដឹងដំណឹងថា ត្បូងទិព្វនេះ ស្តេចទ្រង់ទុកដាក់ក្នុងទូដែកហើយចាក់សោជិត កណ្តុរឆ្លើយថា ខ្ញុំសន្យាយកកែវនោះមកឲ្យបង ៗ កាលបើបានឮពាក្យសន្យាយ៉ាងនេះហើយ ឆ្មាក៏លែងស្តេចកណ្តុរសនោះឲ្យរួចខ្លួន ៗ លុះបានរួចពីគ្រោះថ្នាក់, ស្តេចកណ្តុរសថយខ្លួនប្រញាប់ដើម្បីទៅប្រមូលកណ្តុរទាំងឡាយ ដែលនៅក្រោមអំណាចខ្លួន ៗ តាមបញ្ជារបស់ស្តេចខ្លួន, កណ្តុរទាំងនោះ នាំគ្នាទៅកកេរទូដែកទាល់តែធ្លុះពីម្ខាងទៅម្ខាង ៗ កណ្តុរខ្លះបាក់ធ្មេញអស់ នៅសល់តែធ្មេញមុខពីរ ៗ ទោះបីយ៉ាងដូចម្តេច កណ្តុរទាំងនោះយកបានត្បូងទិព្វ ទៅ

ប្រគល់ឲ្យឆ្មាជាស្រេច ៗ លុះបានកែវមណីជោតិនេះ, ឆ្មាសំដែងសេចក្ដីអរគុណដល់កណ្ដុរទាំងនោះ ហើយនាំឆ្កែត្រឡប់ទៅនគរវិញ ៗ ក្រពើក៏បានបម្លងឆ្មានិងឆ្កែ ទៅដល់ត្រើយម្ខាងវិញ ៗ

បន្ទាប់មក ឆ្មានិងឆ្កែ ដើរដល់ស្ពានមួយ ៗ ឆ្កែ និយាយទៅកាន់ឆ្មាថា ប្អូន ! ឲ្យកែវមណីជោតិមកអញ ១ បន្តិច ៗ ឆ្មាឆ្លើយថា: អញមិនឲ្យទៅឯងទេ ៗ ឯងជាសត្វនិយាយច្រើន ៗ អញខ្លាចក្រែងឯងឃើញវត្ថុអ្វី ១ ឯងព្រុះហើយធ្លាក់ត្បូងទៅក្នុងទឹក ៗ កាលបើឯងធ្វើឲ្យបាត់ មុខជាលំបាកវេទនាយើងទាំងពីរនាក់ទៀតហើយ ៗ ប៉ុន្តែ ឆ្កែមិនស្ដាប់ក៏ដណ្ដើមកែវមណីជោតិពីឆ្មា យកមកកាំ ហើយលោតទៅក្នុងទឹកឆ្លងស្ពាន ៗ លុះកំពុងតែហែលកាត់ស្ពាន, ឆ្កែឃើញត្រីពោរហែលចំហរមាត់នៅលើផ្ទៃទឹក ក៏ព្រុះដោយភ្ញាក់ភ្ញាំងស្មារតី ៗ ត្បូងទិព្វធ្លាក់ពីមាត់ហើយត្រីពោរលេបបាត់ទៅ ៗ កាលបើហែលដល់ច្រាំងម្ខាងហើយ ឆ្មាបានសួរឆ្កែថា: ហេតុម្ដេច បានជាឯងមិនជឿអញ, អញបាននិយាយហើយនិយាយទៀតថា ឯងជាសត្វនិយាយច្រើន ៗ ឥឡូវនេះ បាត់កែវ

ទៅហើយ ។ រកមកឲ្យអញ អញមិនដឹងធ្វើដូចម្ដេចទេ ។ ឆ្កែនៅស្ងៀម ស្ដាប់ឆ្មាបន្ទោសឥតឆ្លើយសោះ ។ ប៉ុន្តែ ឆ្មាជាសត្វប្រាជ្ញ (ប្រសប់ជោះកុន) ។ ក៏ដើរល្បួចចាប់បាន អគ្គមហេសីនៃស្ដេចកេមួយ ។ ដោយឮ អគ្គមហេសីកេនេះអង្វរគេ, ឆ្មាឆ្លើយថា នែអគ្គមហេសីកេ បើឯងសន្យា យកកែវមណីជោតិ ដែលត្រីពោរលេបបាន អញនឹងលែងឯងឲ្យរួចជីវិត ។

-. ឲ្យតែខ្ញុំរួចខ្លួនចុះ ខ្ញុំហ៊ានធានាអះអាងយកត្បូងទិព្វឲ្យបងឆ្មាបាន ។ លុះបានស្ដាប់សេចក្ដីសន្យាខាងលើនេះហើយ ឆ្មាក៏លែងអគ្គមហេសីកេ ឲ្យទៅប្រមូលសត្វកេទាំងឡាយ ដើម្បីមុជទឹកចាប់ ។ តែកាលណោះ សត្វកេហែកពោះត្រី ទៅមិនឃើញត្បូងទិព្វទេ ។ នៅសល់តែ ត្រីពោរមួយ ដែលពុំទាន់ចាប់បាន ។ បន្តិចមក សត្វកេក៏ចាប់បានត្រីខាងក្រោយនេះ យកមកហែកពោះ ទើបឃើញកែវមណីជោតិ ។ សត្វកេ យកកែវនោះទៅប្រគល់ឲ្យឆ្មា ។ នៅវេលានោះ, ឆ្មាបានទទួលយក កែវមណីជោតិជាស្រេច ហើយហៅឆ្កែនាំគ្នាធ្វើដំណើរទៅមុខទៀត ។ ដល់ពាក់កណ្ដាលផ្លូវ, ឆ្កែរកឿងដណ្ដើមត្បូងពីឆ្មាទៀត ។ ឆ្មាមិន

ព្រមឲ្យកែវនោះមកក្អែក តែក្អែកបង្ខំឆ្មាដោយអំណាច យកត្បូងមកពាំម្តង-ទៀត ៗ លុះពាំត្បូងបានបន្តិចទៅ, ក្អែកឃើញត្មាតកំពុងតែចុះមកហែកខ្មោចក្របីស៊ី, វាក៏ព្រុះត្មាតនោះឥតសំចៃ, ត្បូងធ្លាក់ពីមាត់ទៅដី ៗ ឃើញដូច្នោះ ត្មាតហោះមកចឹកយកកែវមណីជោតិ ហើយគ្រលៀវលេបបាត់ទៅ ៗ ឆ្មាទឹងយ៉ាងខ្លាំង ហើយនិយាយទៅកាន់ក្អែកថា ហេតុដូចម្តេច បានជាឯងមិនជឿពាក្យអញ! ឥឡូវនេះ តាមតែឯងធ្វើម្តេចបានធ្វើទៅចុះ ៗ ចំណែកអញ អញមិនដឹងទេ! អញទៅផ្ទះសិនហើយ ៗ ក្អែកមានទុក្ខព្រួយយ៉ាងក្រៃលែង គ្មាននិយាយមួយម៉ាត់សោះ ៗ ដោយគិតខ្លាចក្រែងចៅហ្វាយគាត់សម្លាប់ វាអង្គុយញ័រជើងចំប្រប់ ធ្វើមុខស្ងួតស្ញួតឲ្យអាណិត ហើយញាក់មុខទឹងបព្រិចភ្នែកផង ៗ រួចពីបន្ទោសក្អែកមក ឆ្មាដើរតម្រង់ទៅផ្ទះ នៅតាមផ្លូវវាប្រទះឃើញពស់វែកមួយ ក៏ខាំពស់នោះត្រង់កជាប់ បំរះមិនរួច ៗ នៅពេលពស់នោះអង្វរថា: ឱបងឆ្មា! អាណិតខ្ញុំផង, លែងខ្ញុំឲ្យរស់ជីវិតពេលនេះទៅ, ដល់ពេលក្រោយ ខ្ញុំនឹងជួយដោះទុក្ខបងជាមិនខាន ៗ

☛ (មានត)

## កំណត់ហេតុប្រវត្តិការណ៍

# ពិធីអនុសិវិប្បរៈមហាសន្និបាតលើកទី ១៤ នៃមន្ត្រីសង្ឃ សម្រាប់ឆ្នាំ ១៩៥៨ នៅមន្ទីរព្រះសទ្ធម្ម ក្នុងវត្តព្រះកែវមរកត

( តមក )

លោក ឯន - ប៊ីង រៀបរៀង

នូវអធិករណ៍ផ្សេងៗ ដែលមានកើតឡើងក្នុងភាពមខ្លះ ឲ្យបាត់បង់ទៅវិញ ដោយព្យាយាមពន្យល់ដល់ពុទ្ធបរិស័ទទាំងអស់ថា ការឈ្លោះប្រកែកគ្នានេះ នាំឲ្យបាត់បង់សាមគ្គីជាតិ ហើយជាបច្ច័យនាំឲ្យសង្គមយើងទាំងមូលថយកំឡាំងទៅវិញផង ។

នៅទីបំផុតខ្ញុំព្រះករុណា សូមប្រកាសបើកមហាសន្និបាតមន្ត្រីសង្ឃលើកទី ១៤ ព្រមទាំងប្រគេនសព្ទសាធុការពរ ចំពោះព្រះតេជព្រះគុណគ្រប់ព្រះអង្គ សូមឲ្យបានប្រកបដោយនូវសេចក្តីសុខសេចក្តីចំរើនរហូតដល់ព្រះនិព្វាន ។

តមក លោក មាស - យ៉ន់ អនុរដ្ឋលេខាធិការក្រសួងធម្មការ ថាប់ថ្លែងសុន្ទរកថា មានសេចក្តីដូចតទៅនេះ ៖

# សុន្ទរកថារដ្ឋមន្ត្រីក្រសួងធម្មការ

សូមព្រះតេជះដំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង

សម្តេចព្រះមហាក្សត្រិយានី

សម្តេចព្រះឧបយុវរាជ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានថ្វាយនូវអំណរព្រះករុណាធិគុណដ៏ជ្រាលជ្រៅ ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី សម្តេច ព្រះឧបយុវរាជ ដែលទ្រង់ព្រះមេត្តាប្រោស ស្តេចបានយាងមកជាព្រះរាជាធិបតី នៃព្រះរាជាធិបតាក្នុងពិធីបុណ្យ អនុសំវច្ឆរសន្និបាតមន្ត្រីសង្ឃ ទី ១៤ សម្រាប់ឆ្នាំរកានព្យសក ព. ស. ២៥០០, គ. ស. ១៩៥៨ នេះ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត ដើម្បីប្រស្រ័យជាមួយនឹងព្រះថេរានុត្ថេរៈទាំងឡាយ ដោយមានបំណងចង់ឲ្យព្រះសង្ឃបានជ្រាបនូវដំណើរកិច្ចការខ្លះខាងពុទ្ធចក្រនឹងអាណាចក្រ ដែលបានប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាលនេះ ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

សូមក្រាបថ្វាយបង្គំសម្ដេច នឹងព្រះថេរានុត្ថេរ គ្រប់ព្រះអង្គ ខ្ញុំព្រះករុណាមានសេចក្ដីកោតយ៉ាងខ្ពង់ខ្ពស់បំផុត ចំពោះសម្ដេចនឹងព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ដែលបាននិមន្តមកកាន់មហាសន្និបាតនេះ ; ។

សម្ដេច !

ព្រះករុណាគ្រប់អង្គ !

ឱកាសនេះ ជានក្ខត្តសម័យដែលខ្ញុំព្រះករុណាបានមកជួបព្រះភក្ត្រសម្ដេច នឹងព្រះករុណាគ្រប់ព្រះអង្គ គួរចាត់ទុកជាទស្សនានុត្តរិយៈមួយដ៏ប្រសើរ ។ ខ្ញុំព្រះករុណាបានចូលមកកាន់ការនៅក្រសួងធម្មការ ចំនួនជិត ៦ ខែហើយ ក្នុងរយៈវេលា ដែលខ្ញុំព្រះករុណាបានប្រតិបត្តិការមកនេះ ទោះបីមានសេចក្ដីធំធេងខ្លះ ពុំសមគួរទៅតាមព្រះទ័យក៏សូមសម្ដេច ព្រះករុណាគ្រប់ព្រះអង្គ មេត្តាអភ័យទោស ព្រោះការទាស់ខ្លួននេះប្រសិនបើមាន ក៏ពុំមែនប្រកបទៅដោយចេតនាឡើយ ។

ខ្ញុំព្រះករុណា សូមផ្ញើសេចក្ដីសង្ឃឹមលើព្រះករុណាគ្រប់ព្រះអង្គជាមេគណអនុគណថា នឹងជួយរិះរកមធ្យោបាយយ៉ាងណា សម្រួលកិច្ចការទាំងពួង ដែលខាងពុទ្ធចក្រមានដំណើរទៅស្រួល គួរយ៉ាងដូចជាអធិករណ៍សង្ឃជាដើម សូមកុំឲ្យកើតមានឡើង ក្នុងស្រុកខែត្រច្រើនពេក គឺថាអធិករណ៍ណាដែលកើតឡើងហើយ ក្នុងស្រុកខែត្រ សុំព្រះករុណាជាមេ

គុណានុគុណ រិះគមគន្ធាបាយស្ដាប់ស្ទង់មើលយ៉ាងហ្មត់ចត់ បើអាចរម្ងាប់បាន គួរតែសម្រុះសម្រួល ឲ្យបានសះជាក្នុងទីនោះ ដោយស្រួលពន់ សុំកុំឲ្យពន្យារពេលទុកឲ្យអធិករណ៍នោះ រីកពលធំឡើងនាំឲ្យអំពល់ដល់ព្រះរាជវរ្គាភិបាលចាត់ចែង ការឯទៀតដែលមានសារប្រយោជន៍បូជាមាតុប្រទេស ព្រោះខ្ញុំព្រះករុណាបានសង្កេតឃើញអធិករណ៍ខ្លះ ដែលកើតឡើងមុនដំបូង ជាការបន្តិចបន្តួចសោះ ពុំមែនជាអធិករណ៍រឹងត្អឹងទេ មានសភាពល្មម គួរតែព្រះតេជព្រះគុណមេគណអនុគណ សម្របសម្រួលបាន ដោយគ្រប់គ្រាន់ តែអធិករណ៍នោះត្រឡប់ទៅជារីកពលធំឡើងពុំអាចរម្ងាប់បាន ដោយងាយទៅវិញ ។ ឧទាហរណ៍ដូចជាភ្លើងសម្រាមធម្មតា ភ្លើងសម្រាមមុនដំបូងពុំសូវមានអណ្ដាតភ្លើងសន្ធោសន្ធៅប៉ុន្មានទេ តែបើបណ្ដោយឲ្យភ្លើងនោះឆេះតាមចិត្តទៅ ភ្លើងនោះក៏រមែងឆេះរាលដាល ក្លាយទៅជាឆេះផ្ទះសម្បែង មានអណ្ដាតសន្ធោសន្ធៅពុំអាចពន្លត់បានដោយងាយឡើយ ។

ត្រង់ខនេះ ជានិមិត្តរូបឲ្យឃើញថា អធិករណ៍ដែលកើតឡើងទាំងប៉ុន្មាន បណ្ដាលមកតែពីការបន្តិចបន្តួចប៉ុណ្ណោះ បីដូចជាភ្លើងសំរាម បើប្រសិនជារម្ងាប់ភ្លាមៗទៅ ភ្លើងនោះក៏ពុំអាចឆេះរាលដាលទៅបានឡើយៗ ចំពោះរឿងអធិករណ៍នេះ បើមានកើតឡើងក្នុងវត្តភាគណា ខ្ញុំព្រះករុណា

សូមព្រះតេជព្រះគុណមេគណ អនុគណ មេត្តាប្រួមជាមួយរាជការស្រុក ខេត្ត រិះរកមធ្យោបាយរម្ងាប់ហេតុ ក្នុងអារាមនោះភ្លាម ៗ ឲ្យបានសម្រេចតែម្តងទៅ ទើបបានលទ្ធផលល្អ ដើម្បីការពារកុំឲ្យអធិករណ៍នោះរីករាលធំទូលាយតទៅទៀតបានឡើយ ៗ

ព្រះតេជព្រះគុណគ្រប់ព្រះអង្គ ! យើងមានភ័ព្វល្អណាស់ ដែលមានព្រះពុទ្ធសាសនាប្រតិស្ឋាន នៅក្នុងប្រទេសយើងនេះ ព្រមទាំងបានកើតទាន់ពាក់កណ្តាលព្រះពុទ្ធសាសនា ហើយបានទាំងធ្វើពិធីបុណ្យរំលឹកពុទ្ធសករាជ ២៥០០ ព្រះវស្សា ចំនួន ៧ ទិវារាត្រីយ៉ាងឧឡារិក ត្រង់ទីប្រតិស្ឋាននៃព្រះសក្យមុនីចេតិយ នាមុខស្ថានីយរាជអយស្ម័យយាន ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំង ២ ព្រះអង្គ និងគ្រប់អាណាខេត្ត ក្នុងព្រះរាជអាណាចក្រទាំងមូលផង ៗ ព្រះពុទ្ធសាសនាជាលទ្ធិដឹកនាំសត្វឲ្យដើរទៅរកសេចក្តីស្ងប់ គឺសន្តិភាពមិនឲ្យមនុស្សរំលោភលើមនុស្សផងគ្នា ប្រដៅសត្វឲ្យជឿកម្មនិងផលនៃកម្ម ដូចព្រះតេជព្រះគុណជ្រាបស្រាប់ហើយ ៗ ខ្ញុំព្រះករុណាសង្ឃឹមថា ព្រះសង្ឃជាសិស្សផ្ទាល់នៃព្រះពុទ្ធបរមគ្រូ នឹងប្រកាន់យកផ្លូវស្ងប់តាមតម្រាយនៃព្រះពុទ្ធអង្គដោយពិត ៗ

យើងមានភ័ព្វម្យ៉ាងទៀត ដោយបានព្រះមហាក្សត្ររបស់យើង

ទ្រង់កាន់ព្រះពុទ្ធសាសនាយ៉ាងដិតស្និទ្ធ ហើយព្រះអង្គជាអគ្គពុទ្ធសាស-
នូបត្ថម្ភ គឺព្រះអង្គជាក្សត្រទ្រង់ទំនុកបម្រុងព្រះពុទ្ធសាសនា ដោយព្រះ
រាជហឫទ័យជ្រះថ្លាដ៏បរិសុទ្ធ ដូចជាក្នុងពិធីបុណ្យអនុសំវច្ឆរៈមហាសន្និ-
បាតមន្ត្រីសង្ឃរៀងរាល់ឆ្នាំមក ព្រះអង្គទ្រង់តែងបរិច្ចាគដោយព្រះបសាទ-
សទ្ធានូវថវិកាសម្រាប់ព្រះរាជទ្រព្យ ១ ម៉ឺនរៀល ដើម្បីចាត់ធ្វើភត្តប្រគេន
ព្រះករុណាគ្រប់ព្រះអង្គ ដែលនិមន្តមកកាន់ទីមហាសន្និបាតនេះ ។

ព្រះតេជព្រះគុណគ្រប់ព្រះអង្គ!

ព្រះពុទ្ធសាសនានៅប្រទេសយើង ពិតមែនតែប្រទេសតូចមាន
ពលរដ្ឋតិច ប៉ុន្តែ ប្រទេសទាំងឡាយដែលជាពុទ្ធសាសនិកបានទទួល
ស្គាល់ថាជាប្រទេសកាន់ពុទ្ធសាសនា យ៉ាងហ្មត់ចត់ត្រឹមត្រូវតាមពុទ្ធោវាទ
មានពុទ្ធសាសនិក ៩៩ ភាគរយ ។ កិត្តិគុណប្រទេសយើងដែលកើតឡើង
នេះគឺកើតដោយសារស្នាព្រះហស្ថ នៃសម្តេចព្រះឧបយុវរាជ ជាបិតាឯក-
រាជ្យព្រះអង្គបានបំពេញព្រះរាជបេសកកម្ម ប្រស្រ័យទាក់ទងនឹងប្រទេស
ឯទៀតជាច្រើន ដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា ឲ្យគេទទួលស្គាល់នូវ
គុណសម្បត្តិរបស់ប្រទេសយើងថាជាប្រទេសកាន់ព្រះពុទ្ធសាសនា ហើយ
ប្រជាពលរដ្ឋ ក៏សុទ្ធតែអ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់គ្នា ។

អាស្រ័យហេតុនេះ គួរព្រះតេជព្រះគុណ មេគណ អនុគណគ្រប់ព្រះ

អង្គប្រជុំលោកគ្រូចៅអធិការគ្រប់វត្តក្នុង១ ឆ្នាំ ២ ដង ឬ ៣ ដងពន្យល់ណែនាំអស់លោកគ្រូចៅអធិការគ្រប់វត្តគ្រប់អង្គ ឲ្យលោកបានយល់អំពីច្បាប់របស់ព្រះពុទ្ធសាសនា និងសេចក្ដីប្រតិបត្តិ ដែលព្រះសង្ឃត្រូវប្រតិបត្តិឲ្យមានសេចក្ដីរៀបរយ កុំឲ្យមានការយើករយាក ដូចដែលធ្លាប់ប្រទះមកហើយ ដើម្បីលើកកិត្តិសព្ទពុទ្ធសាសនា នៅប្រទេសយើងឲ្យល្បីខ្ចរខ្ចាយទូទៅ សមតាមព្រះរាជបំណងនៃសម្ដេចព្រះវរបយុវរាជ ដែលព្រះអង្គជាអគ្គពុទ្ធសាសនូបត្ថម្ភដ៏វិសេស ព្រោះប្រទេសយើងបានចក្រ ២ គឺពុទ្ធចក្រនិងអាណាចក្រ លុះត្រាតែចក្រទាំង ២ វិលទៅមានល្បឿនស្មើគ្នា ទើបនាំបានដល់ត្រើយនៃវឌ្ឍនភាព ។

បពិត្រព្រះករុណាគ្រប់ព្រះអង្គ ! ការសិក្សាខាងព្រះពុទ្ធសាសនានៅប្រទេសយើង ក្នុងបច្ចុប្បន្ននេះ ឃើញថាមានដំណើរជឿនទៅមុខគួរសមហើយ តែសេចក្ដីប្រតិបត្តិរបស់បព្វជិត ក្នុងព្រះរាជអាណាចក្រ បើពិនិត្យឲ្យល្អិតឃើញថា នៅខ្សោយជាងការសិក្សាទៅវិញ ព្រោះមានអធិករណ៍សង្ឃ ជាទោសគួរឲ្យយ៉ាងធំ ដែលជាមន្ទិលក្នុងព្រះពុទ្ធសាសនា ។

សូមព្រះតេជព្រះគុណគ្រប់ព្រះអង្គ ជ្រាបច្បាស់ចលនានៃព្រះពុទ្ធសាសនានៅប្រទេសយើង ដែលមានល្បឿនលឿន មកប៉ុណ្ណោះដោយសារ

សេចក្ដីខ្វះខាតនៃព្រះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម ដែលមានសម្ដេចព្រះឪបយុវរាជជាប្រធាន ព្រះអង្គទ្រង់ពុំមែនឈ្លៀងទតតែខាងកិច្ចការអាណាចក្រទេ គឺទ្រង់ទំនុកខាតបក្រទាំង ២ ឲ្យវិលទៅមានល្បឿនស្មើគ្នា ដើម្បីញ៉ាំងសេចក្ដីបរិបូរឲ្យកើតមានឡើងដល់ប្រទេសជាតិ ។

ហេតុនេះ ខ្ញុំព្រះករុណាសុំផ្ញើសេចក្ដីទុកចិត្ត លើព្រះករុណាគ្រប់ព្រះអង្គជាមន្ត្រីសង្ឃ មានព្រះតេជព្រះគុណមេគណ អនុគណជាដើម គ្រប់ខេត្តគ្រប់ស្រុកថា នឹងយកព្រះទ័យទុកដាក់ដាស់តឿនក្រើនរំលឹកលោកគ្រូចៅអធិការគ្រប់វត្តនូវអស់ភិក្ខុសាមណេរគ្រប់រូប ព្រមទាំងពុទ្ធបរិស័ទចំណុះវត្ត ឲ្យខំបំពេញករណីយកិច្ចឲ្យបានសមតាមពុទ្ធដីកា នៃអង្គសម្ដេចព្រះសព្វញ្ញុតញ្ញាណរបស់យើង ដែលព្រះអង្គទ្រង់និយមយកសន្ដិភាពជាគោលសេចក្ដីប្រតិបត្តិ ។

សូមទ្រង់ព្រះមេត្តាប្រោស !

ទីបំផុតនៃសុន្ទរកថានេះ ទូលព្រះបង្គំជាខ្ញុំសូមបង្អោនព្រះរាជកុសលថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំង ២ ព្រះអង្គ ព្រមទាំងសម្ដេចព្រះឪបយុវរាជ សូមព្រះអង្គគង់នៅជាសុខ គង់ព្រះរាជសិរីសម្បត្តិព្រមទាំងបានប្រកបដោយសិរីសួស្ដីជយមង្គលគ្រប់ប្រការ កំចាត់បង់នូវចបសគ្គទាំងពួង កុំឲ្យកើតមានឡើងដល់ព្រះអង្គ ដើម្បីបានទ្រង់ដឹកនាំ

ប្រទេសជាតិ និងព្រះពុទ្ធសាសនា ឲ្យដើរឆ្ពោះទៅរកសន្តិភាពនិងវឌ្ឍន-ភាពជានិច្ចនិរន្តរតអផ្សែងទៅ ។

ចប់សុន្ទរកថា ។

នៅពេលដែលចប់សុន្ទរកថានៃ លោក មាស-យ៉ង់ អនុរដ្ឋលេខាធិការក្រសួងធម្មការហើយ ព្រះតេជព្រះគុណព្រះបាឡាត់បទុមវង្សាកេត វត្ត-ទេពធីតាកម ខែត្រកំពង់ឆ្នាំង ថ្វាយសុន្ទរកថាតបវិញ មានសេចក្ដីដូចតទៅនេះ

# សុន្ទរកថា

សូមថ្វាយព្រះពរព្រះករុណាជាម្ចាស់ជីវិតទាំង ២ ព្រះអង្គ និងសម្ដេចព្រះបិតាឯកពជ្យ សូមទ្រង់ជ្រាប ។

សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក បានតម្រូវលើរូបអាត្មាភាព ឲ្យជាតំណាងសង្ឃដែលបាននិមន្តមកជួបជុំ ក្នុងទីចំពោះព្រះភក្ត្រ នាមហាសន្និបាតនេះ ឲ្យអាត្មាភាពថ្វាយសេចក្ដីតបសុន្ទរកថានៃអ្នកឧកញ៉ារដ្ឋមន្ត្រីក្រសួងធម្មការ ។

អាត្មាភាពសូមព្រះពរទានព្រះបរមានុញ្ញាត សូមថ្វាយសេចក្ដីដោយសង្ខេប ចំពោះតែត្រង់ខ្លះ ដែលមានសារប្រយោជន៍ ស្រប គ្នានឹងសុន្ទរកថានៃលោករដ្ឋមន្ត្រីក្រសួងធម្មការ ។

សូមថ្វាយព្រះពរ,

មន្ត្រីសង្ឃគ្រប់ថ្នាក់ គ្រប់ដំណែងសុទ្ធសឹងតែធុញទ្រាន់ ស្អប់ខ្ពើមអធិករណ៍ ដែលកើតមានក្នុងវត្តអារាម, ស្រឡាញ់តែសេចក្តីសុខស្ងប់ជានិច្ច, ក៏ខំប្រឹងរកមធ្យោបាយកុំឲ្យមានអធិករណ៍, ដែលបានជាជួលកើតមានខ្លះហើយ ក៏ខំរលត់រលាយណាស់ដែរ, ជួនកាលក៏បានស្ងប់រម្ងាប់ ជួនកាលក៏ក្លាយទៅជារីករាលធំឡើង ពុំអាចធ្វើឲ្យរលត់បានទៅវិញ ដែលបែរទៅជាផ្ទុយដូច្នេះ ដោយមកពីហេតុដូចខាងក្រោមនេះ ៖

អធិករណ៍ដែលកើតឡើងក្នុងវត្តអារាមណាមួយ, ព្រះវិន័យប្រាប់ថា ត្រូវរម្ងាប់ដោយសារសមថៈ ៧ យ៉ាង ទោះសមថៈណាក៏ដោយ តាមយថាហេតុ ដូចជាភ្លើងឆេះសំពមជាដើម ត្រូវរលត់ដោយគ្រឿងលត់មានទឹកជាដើម ដូច្នោះដែរ ។ ក្នុងសម័យសព្វថ្ងៃនេះ នឹងយកសមថៈទាំងនោះមករម្ងាប់អធិករណ៍ឲ្យសព្វគ្រប់ តាមក្បួនព្រះវិន័យពុំកើត ព្រោះមកពីគូវិវាទ ច្រើនតែពុំទទួលគោរពព្រះវិន័យទាំងព្រះរាជក្រម ព្រះរាជក្រឹត្យ នឹងប្រកាសផ្សេងៗ ដែលជាជំនួយព្រះវិន័យនោះ ក៏គូវិវាទច្រើនតែពុំសូវគោរពដែរ ដោយមកពីបេះគេរបខខ្លួនឥតមានកំហុសក្នុងប៉ុន្មាន ម្ល៉ោះហើយអធិករណ៍ សូម្បីតូចមួយសោះទេ ក៏អាចរីករាលទៅជាអធិករណ៍ធំបាន ក៏សឹងតែមានខ្លះ ។

ក្រន់ចនេះ សូមព្រះរាជរដ្ឋាភិបាលជួយលៃលក ឲ្យគណៈសង្ឃមានសិទ្ធិប្រតិបត្តិការឲ្យបានបរិបូណ៌ តាមលំអានព្រះវិន័យ និងព្រះរាជក្រម ព្រះរាជក្រឹត្យ ព្រមទាំងប្រកាសទាំងពួងនោះឡើង ទើបនឹងបានងាយប្រតិបត្តិការ, អធិករណ៍ក៏នឹងពុំសូវកើតមានឡើងប៉ុន្មាន បើទុកជាកើតមានឡើងបន្តិចបន្តួច សង្ឃក៏អាចនឹងរម្ងាប់បានដោយងាយៗ ។

អាត្មាភាពសូមថ្លែងសេចក្ដីសង្ខេបតែត្រឹមប៉ុណ្ណេះ ដ្បិតក្រសួងធម្មការដែលបានប្រតិបត្តិការរាល់ថ្ងៃមក ក៏បានជ្រាបដំណើរអធិករណ៍ទាំងពុទ្ធចក្រដោយជាក់លាក់ណាស់ហើយ ។

នៅទីបញ្ចប់នេះ អាត្មាភាពជាដំណាងមន្ត្រីសង្ឃ សូមលើកយកកុសលបុញ្ញរាសី ដែលសង្ឃគ្រប់វត្ត បានប្រព្រឹត្តប្រតិបត្តិក្នុងរយៈកាល ១ ឆ្នាំមកហើយនេះ ជាព្រះរាជកុសល ថ្វាយចំពោះព្រះករុណាជាម្ចាស់ជីវិតទាំង ២ ព្រះអង្គ និងសម្ដេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ សូមទ្រង់ទទួលអនុមោទនា ហើយសូមទ្រង់ប្រកបដោយសិរីសុខគ្រប់ប្រការ ព្រមទាំងសូមព្រះអង្គ មានព្រះជន្មាទីឃាយុយឺនយូរអស់កាលអង្វែងវែងឆ្ងាយ !

សូមថ្វាយព្រះពរ ។

មួយទៀត សូមជូនសាធុការពរ ចំពោះអស់លោកគណៈរដ្ឋមន្ត្រី

និងអស់លោកមន្ត្រីធំតូច គ្រប់ថ្នាក់ គ្រប់ក្រុម សូមបានប្រកបដោយសុភមង្គលគ្រប់យ៉ាង សព្វកាលវេលាទិវារាត្រី !

សូមកម្ពុជរដ្ឋ ឯករាជ្យ អព្យាក្រឹត បិតនៅជាស្ថាពរដោយការចំរុងចំរើនជានិច្ចនិរន្តរ៍ !

សូមចំរើនពរ ៗ

ក្រោយដែលចប់សុន្ទរកថា នៃព្រះតេជព្រះគុណព្រះបាទឡាត់បទុមវង្សាគេត វត្តទេពធីភារាម ខេត្រកំពង់ឆ្នាំងហើយ ព្រះសង្ឃទាំងអស់ក៏ស្វាធ្យាយធម៌ជយន្តោប្រសិទ្ធិពរ ថ្វាយព្រះមហាក្សត្រទាំងពីរព្រះអង្គនិងឥស្សរជនទាំងឡាយ ៗ

ម៉ោង ៩ និង ៣០ នាទី ព្រះមហាក្សត្រទាំងពីរព្រះអង្គថ្វាយបង្គំលាព្រះសង្ឃ ស្តេចយាងចូលព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិពារ ហែហមអម ព្រះអង្គ ៗ ចំណែកឥស្សរជនទាំងអស់ក៏អញ្ជើញទៅកាន់ដំណែងរៀងខ្លួនវិញ ៗ

ម៉ោង ១០ និង ៣០ នាទី មានការប្រគេនភត្ត ក្នុងព្រះបរមនាមព្រះករុណាជាម្ចាស់ជីវិតលើត្បូងដល់ព្រះសង្ឃ នៅមហាកុដិវត្តឧណ្ណាលោម ចំពោះមុខលោកម៉ាស់-យ៉ង់អនុរដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងមន្ត្រីក្រសួងធម្មការ-ឧបាសក ឧបាសិកា ៗ

ចប់ ៗ

# មហាសន្និបាតសមាគមមិត្តពុទ្ធិកវិទ្យាល័យ

លោកកា៉យ - ប៊ុករៀបរៀង

កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៥៨ វេលាម៉ោង ១៩ និង៣០នាទី នៅសាលាបាលីរងវត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ គេឃើញមានការជួបជុំនៃពុទ្ធបរិស័ទ ទាំងភេទបព្វជិត និងគ្រហស្ថចំនួនច្រើន ក្រោមបរិយាកាសយ៉ាងស្និទ្ធស្នាលក្រៃលែងដែលជាមិត្តភាព ។

ចំណែកភ្ញៀវខាងព្រះសង្ឃ មានព្រះតេជគុណ ព្រះញាណកោសល ញាណ-ឈឺន ព្រះពុទ្ធវង្ស កៅ-ស៊ុម និងព្រះមហា ប៉ាង-ខាត់ ជាដើម ព្រមទាំងភិក្ខុសាមណេរ អង្គឯទៀតជាច្រើន ដែលយើងសុំអភ័យទោសពុំអាចនឹងរាប់នាមប្រគេនឲ្យអស់បាន ។

ប៉ែកខាងភ្ញៀវគ្រហស្ថមាន លោក សម-ញាណ លោកកា៉យ លុត និងលោក កា៉យ ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យជាដើម និងអស់លោកៗឧបាសកៗឧបាសិកា ជាច្រើនទៀត ដែលយើងសុំអភ័យទោសដោយពុំបានរាប់ឈ្មោះជូនឲ្យបានសព្វគ្រប់ ។

លុះដល់ម៉ោង ១៦ និង៣០នាទី មហាសន្និបាតក៏បានបើកសម័យឡើង ។ ដើមដំបូងលោក កា៉យ ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ ចាប់ថ្លែងសុន្ទរកថាមួយ ដ៏ពិរោះក្បោះក្បាយ រៀបរាប់អំពីស្ថានការណ៍សមាគម

ក្នុងឆ្នាំ ១៩៥៧ ដែលកន្លងហួសមកនេះ ដោយសង្ខេប ហើយនឹងបាន បញ្ជាក់ដល់មហាសន្និបាត នូវកិច្ចការជាអត្ថប្រយោជន៍សំខាន់ ដែលសមាគមបានបំពេញរួចខ្លះមកហើយ នឹងដំហានមិត្តភាព ខាងពុទ្ធសាសនាកម្ពុជរដ្ឋ ពាំងពុទ្ធសាសនាបរទេសផង ដែលគេបានទទួលស្គាល់សមាគមយើងដោយពេញលក្ខណៈ ។

នៅទីបំផុតលោក ពាយ ប៊ុក អំពាវនាវដល់មហាសន្និបាតថា សូមឲ្យអស់លោកជាពុទ្ធបរិស័ទមេត្តាជួយទំនុកបំរុង សមាគមនេះឲ្យបានរឹងដំហរឋិតថេរចិរកាល ដោយរុងរឿងតទៅអនាគត ។

បន្ទាប់ពីនោះតទៅទៀត លោកមៅ-ម៉ុ ក្នុងឋានៈជាអគ្គហេរញ្ញិកថាប់ថ្លែងរៀបរាប់ពីស្ថានភាពហិរញ្ញវត្ថុ របស់សមាគមក្នុងឆ្នាំ ១៩៥៧ ដែលកន្លងផុតមកនេះ ។

ប្រាក់ចំណូល ចំណាយ ដូចមានតទៅនេះ ៖

១- ប្រាក់ចំណូល មានចំនួន ១៦១ ១៤៥ រ៉ូ០០

២- ប្រាក់ចំណាយ មានចំនួន ១១៤ ៤៥៧ រ៉ូ០០

៣- ប្រាក់នៅសល់មានចំនួន ៤៦ ៦៨៨ រ៉ូ ៩០ ក្នុងហិបសមាគមសព្វថ្ងៃ ។

ចប់សេចក្ដីថ្លែងការហើយ លោក មៅ ម៉ុ ថ្លែងអំណរគុណចំពោះ

មហាសន្និបាតដែលមានសភាពគគុះគរ សឲ្យឃើញថា អ្នកកាន់ព្រះពុទ្ធ-សាសនានៅប្រទេសយើង កាន់តែមានដំណើរលឿនទៅមុខជាដរាប ។

សូមបញ្ជាក់ថា: នៅពេលចប់សុន្ទរកថានីមួយ សេចក្ដីថ្លែងការម្ដងៗ សូរស័ព្ទទះដៃពុតគិកកងរំពងឡើង ជាសញ្ញាទទួលសេចក្ដីគោរព ចំពោះសមាគម ។

លំដាប់តទៅទៀត មហាសន្និបាត បានរៀបចំពិធីបោះឆ្នោត រើសគណៈកម្មាធិការនាយកថ្មីសម្រាប់ឆ្នាំ ១៩៥៨ ជាជំនួសគណៈកម្មាធិការនាយកចាស់ ដែលសុំលាលែងឈប់ពីតំណែង ។ មហាសន្និបាតបានតាំងគណៈកម្មការបណ្ដោះអាសន្នមួយ គម្រប់លើលោក សម ញាណ ជា-ប្រធាន លោក សូរ ស៊ីផន និង លោក គាន់-គឹមគិក ជាលេខាធិការ ។

ពិធីបោះឆ្នោតក៏ចាប់ផ្ដើមឡើង ដែលមានបេក្ខជន ២៦ រូប ឈរឈ្មោះសម្រាប់ឲ្យគេបោះឆ្នោត ជ្រើសរើសយក ១៦ រូប ធ្វើជាគណៈកម្មាធិការ-នាយកសម្រាប់ឆ្នាំថ្មី ។

លទ្ធផលនៃការបោះឆ្នោត បានសម្រេចដូចតទៅនេះ

| | | | | |
|---|---|---|---|---|
| ១- | លោក | ពៅយ ប៊ុក | បានឆ្នោត | ៦០ |
| ២- | លោក | ផេង-ជ្រៅ | -ដ- | ៥៧ |
| ៣- | លោក | មៅ មុី | -ដ- | ៥៤ |

| | | | |
|---|---|---|---|
| ៤- លោក | សាម-ឡាមុត | -ដ- | ៤៣ |
| ៥- លោកស្រី | សម-ញាណ | -ដ- | ៤៨ |
| ៦- លោក | យក់-សាមេត | -ដ- | ៤៧ |
| ៧- លោក - | អ៊ុក-ផន់ | -ដ- | ៤៤ |
| ៨- លោក | ស៊ូរ-ស៊ុផន | -ដ- | ៤២ |
| ៩- លោកស្រី | សម-ណៃ | -ដ- | ៤១ |
| ១០- លោកស្រី | តុប-ស្អាត | -ដ- | ៣៩ |
| ១១- លោកស្រី | ពៅយ-លុត | -ដ- | ៣៩ |
| ១២- លោកស្រី | ពៅយ-ប៊ុក | -ដ- | ៣៦ |
| ១៣- លោក | ម៉ុង ឌុនលីន | -ដ | ៣៥ |
| ១៤- លោក | អ៊ុង-ទួន | -ដ- | ៣៤ |
| ១៥- លោក | មាឃ-គុម | -ដ- | ៣២ |
| ១៦- លោក | ញ៉ុង-សឿង | ដ- | ៣២ |

រួចហើយ លោកប្រធានក៏បានប្រកាស ដល់មហាសន្និបាតឲ្យបានដឹងថា:បេក្ខជនទាំង ១៦ រូបខាងលើនេះ ដែលបានឆ្នោតច្រើនជាងគេ ត្រូវបានតែងតាំងជាគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៥៨ ។

មហាសន្និបាតបានលើកពេលប្រជុំ នៅវេលាម៉ោង ១៨ ក្រោយពី

បានទទួលជយន្តមង្គលពីក្រុមព្រះសង្ឃ ដែលបាននិមន្តចូលមកប្រជុំមហា-សន្និបាត នឹងក្រោមបរិយាកាសយ៉ាងរីករាយបំផុត ។

លុះដល់ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៥៨ សមាគមបានអញ្ជើញក្រុមអភិបាល ដែលបានជាប់ឆ្នោតទាំង ១៦ រូប ដើម្បីបែកមុខការងារធ្វើការសម្រាប់ឆ្នាំ ១៩៥៨ ។ បានសម្រេចដូចតទៅនេះ ៖

| | | | |
|---|---|---|---|
| ១- | លោក | ពៅយ-ប៊ុក | ប្រធាន |
| ២- | លោកស្រី | ពៅយ-លូត | អនុប្រធាន |
| ៣- | លោក | អ៊ីង-ទូន | អនុប្រធាន |
| ៤- | លោក | ផេង-ជ្រឿ | លេខាធិការ |
| ៥- | លោក | យក់-សាមេត | អនុលេខាធិការ |
| ៦- | លោក | សួរ-ស៊ីផន | អនុលេខាធិការ |
| ៧- | លោក | ម៉ៅ-ម៉ី | អគ្គហេរញ្ញិក |
| ៨- | លោក | សាម-ឡាមុត | អនុហេរញ្ញិក |
| ៩- | លោក | ម៉ុង-ជុនលីន | អនុហេរញ្ញិក |
| ១០- | លោក | អ៊ុក-ផង់ | បណ្ណារក្ស |
| ១១- | លោក | មាឃ-តុម | បណ្ណារក្ស |
| ១២- | លោកស្រី | សម-ញាណ | ស្នងការ |

១៣- លោកស្រី ក៉យ-ប៊ុក ស្នងការ

១៤- លោកស្រី តូច-ស្អាត ស្នងការ

១៥- លោកស្រី គង់-សរ ស្នងការ

១៦- លោក ញូង-សឿង ស្នងការ

ធ្វើនៅភ្នំពេញ នៅថ្ងៃទី ២០ កុម្ភៈ ១៩៥៨

ប្រធាន

# ទេសភាពរវាងប្រទេសនេប៉ាល់និងរដ្ឋពិហ្គល (ប្រទេសឥណ្ឌា) ពីព្រៃលុម្ពិនីទៅទីក្រុងកុសិនារា ។

លោក ភ័យ-ប៊ុក រៀបរៀង

ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង ទ្រង់ប្រសូតនៅព្រៃលុម្ពិនី (ប្រទេសនេប៉ាល់) ទ្រង់បានត្រាស់សម្មាសម្ពោធិញ្ញាណ នៅក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរនៅពុទ្ធគយា (ប្រទេសឥណ្ឌា) ទ្រង់បានសំដែងព្រះធម្មចក្រ នៅព្រៃឥសិបតនៈមិគទាយវ័ន ជិតទីក្រុងពារាណសី (ប្រទេសឥណ្ឌា) ទ្រង់ចូលបរិនិព្វាន នៅចន្លោះដើមសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា (ប្រទេសឥណ្ឌា) ដូចបានទុកពុទ្ធតំណែលមកដល់សព្វថ្ងៃ ។

ពុទ្ធដំណែលទាំងបួនកន្លែងនេះ ជាបូជនីយដ្ឋានដែលពួកទេសចរគ្រប់ប្រទេសអញ្ជើញមកទស្សនា ជាច្រើនម៉ឺននាក់សព្វៗ ឆ្នាំ ។ ព្រោះហេតុដូច្នេះ យើងនឹងពណ៌នាអំពីទិដ្ឋភាពសម័យបច្ចុប្បន្ន ដែលយើងបានទៅទស្សនាដូចតទៅនេះ ៖

## ១ លុម្ពិនីស្ថានដែលព្រះអង្គទ្រង់ប្រសូត

ទីឧទ្យានលុម្ពិនី ដែលយើងបានទៅទស្សនានោះ គឺស្ថិតនៅប្រទេសនេប៉ាល់ មានរបងដែកពទ្ធជុំវិញ សសរដែលព្រះបាទអសោក បានសាងពីមុន

មក សសរនេះឯងជាទីកន្លែងដែលព្រះនាងមហាមាយាទេវី ពុទ្ធមាតា. ទ្រង់មានព្រះកាយស្ងាយរំដួលព្រះរាជហឫទ័យ យកព្រះហស្តចាប់មែកសាលព្រឹក្ស ហើយប្រសូតព្រះរាជបុត្រ គឺព្រះសម្ពុទ្ធ ។ ឆ្ងាយបន្តិច មានស្រះបោក្ខរណី ដែលព្រះគិលៀនបានយកព្រះរាជបុត្រទៅស្រង់ទឹក នៅកន្លែងស្រះបោក្ខរណីនេះ គេបានសាងនូវមុដ្ឋដ្ឋានធ្វើពីឥដ្ឋមានលំអអស្ចារ្យ ។ នៅជិតនោះ មានព្រះវិហារមួយចាស់ ដែលមានរូបគំនូរជាក្បាច់ផ្ចាំងនៃព្រះសម្ពុទ្ធទ្រង់ប្រសូត ។ នៅជិតព្រះវិហារមានអក្សរចារឹកថា: "នៅទីនេះជាទីដែលព្រះសក្យមុនីទ្រង់ប្រសូត" ។

យើងបានទៅពិនិត្យសសរ ដែលព្រះបាទអសោកបានចាត់ឲ្យសាងពីឆ្នាំ ២៥០ មុន គ.ស. (ព.ស ២៩៣), នោះបានឃើញថា: សសរនេះធ្វើពីថ្មមានកំពស់១០ម៉ែត្រ ។

មានគោជនាគារមួយ ដែលរដ្ឋាភិបាលប្រទេសនេប៉ាល់បានសាងទុកសម្រាប់ឲ្យពួកបូជនីយេសក៍ ស្នាក់អាស្រ័យបានដោយងាយ ។

លុម្ពិនីនេះ, សព្វថ្ងៃ គេហៅថា "រុម្មិណេ" គេតែងទៅតាមរថយន្តពីស្ថានីយ៍ អយស្ម័យយាន ណោតានវ៉ា ទៅរដ្ឋបិដ្ឋ៍រ (ប្រទេសឥណ្ឌា) ចម្ងាយ ១៩ ម៉ៃ ។ សព្វថ្ងៃ រដ្ឋាភិបាលប្រទេសនេប៉ាល់កំពុងរៀបចំធ្វើផ្លូវថ្នល់ ដើម្បីសម្រួលដំណើរពួកពុទ្ធសាសនិកជន ដែលមាន

បំណងចង់ទៅទស្សនាលុម្ពិនី ។ ផ្លូវនេះ គេអាចទៅបានតាមអាកាស-យានពីទីក្រុងកល់កុត្តា ទៅទីក្រុងកាត្មណ្ឌុ (ប្រទេសនេប៉ាល់) ។

## ២- ពុទ្ធគយា ស្ថានដែលព្រះអង្គត្រាស់ដឹងនូវអនុត្តរ-សម្មាសម្ពោធិញ្ញាណ

យើងបានទស្សនាឃើញព្រះពោធិព្រឹក្សមួយដើម ទៅតូចដែលដុះចេញពីពោធិព្រឹក្សចាស់ ដែលជាព្រះរាជបុត្រីព្រះបាទអសោកបានកាប់ចោល។

នៅជិតមហាពោធិព្រឹក្សនោះ មានក្អឿតូចមួយនាមថា "មោរមហារះគឺ នៅលើកំពូលក្អឿតូចនេះឯង ដែលព្រះសម្ពុទ្ធទ្រង់ស្ដេចយាងទៅពិចារណានូវធម៌ទាំងឡាយដោយសេចក្ដីស្ងប់ស្ងាត់ ។

នៅទីនេះ គេបានសាងមហាពោធិវិហារ តាំងពីសតវត្សរ៍ ទី១១មានសើនមួយខ្ពស់ប្រកបដោយទ្រង់ទ្រាយជាត្រីកោណ មានជ្រុងត្រង់ហើយមានស្តូបពីលើផង ។ នៅខាងក្នុង គេបានឃើញព្រះពុទ្ធរូបអង្គធំលាបទឹកមាស យកព្រះហស្តចង្អុលព្រះធរណីជាសាក្សីថា ព្រះអង្គទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ។ មហាពោធិវិហារនេះ គឺគេធ្វើតាមគំរូក្បាច់សិល្ប ព្រះមហាពោធិវិហារនៃប្រទេសភូមា ។

☛ (មានត)

វចនានុក្រមសំស្ក្រឹត-ខ្មែរ

( តមក )

# ព្រះមហា ប៉ាង-ខាត់ រៀបរៀង

*អគ្គ* ធាតុ ទៅ ។

*អគ្គ* និបាតប្រាប់សេចក្ដីសួរ ឬ បញ្ជាក់ ដូចជា ពិត, បាទជាដើម ។ *កិមគ្គ* តាំងបាច់និយាយថ្វី ។

*អគ្គ* នបុំ. អង្គ, អវយវៈតូចធំ, រាងកាយ, ចំណែក, អង្គនៃវេទៈ, ផ្នែកវិទ្យា ដូចជាវេទាង្គៈទាំង៦; ឈ្មោះគម្ពីរធំនៃលទ្ធិជិនៈ, អង្គមន្ត្រៈមាន៥ ប្រការគឺៈ ១- *កម៌ាណាំ អារម្ភាបាយ* ឧបាយប្រារព្ធដើម្បីធ្វើការងារ, ២- *បុរុមទ្រវ្យ សម្បទ*, សម្បទ គឺបុរសនឹងទ្រព្យ, ៣-*ទិគ កាល-វិភាគ*, ការចែកនូវទិសនឹងកាល, ៤-*វិបត្តិ-ប្រតីការ* ការធ្វើប្រឆាំងតនឹងសេចក្ដីវិបត្តិ, ៥-*កាយ៌-សិទ្ធិ* ការសម្រេចនូវកិច្ចការ ទាំង ៥ ប្រការនេះ ហៅថា បញ្ចាង្គៈ ។ *អគ្គតា* ស្ត្រី. ភាវនៃកិរិយាតាំងតាក់ ។ អង្គ-ក្ឫ សូម, កំណត់, បង្កើត ប្រព្រឹត្តទៅតាម, យល់ព្រមតាម ។ -*កតិន* នបុំ. កិរិយាកាត់នូវអង្គ ។ -*កម៌ន* នបុំ., ឬ -*ក្រិយា* ស្រី. កិរិយាប្រុសព្រំនូវរាងកាយ (ដោយគ្រឿងក្រអូប)។-*គ្រហ* បុំ. "កិរិយាចាប់នូវអង្គ" ការកន្ត្រាក់ ។ -*គ្លានិ* ស្រី. កិរិយាស្វាក់នៃអង្គ ឬ រាងកាយ ។

☞ (មានត)

ការពារ និងបុគ្គលិកមន្ទីរពេទ្យព្រះសង្ឃ ទ្រង់នឹងជួយឧបត្ថម្ភមន្ទីរពេទ្យនេះឲ្យមានវឌ្ឍនភាពតទៅអនាគតជាដើម ។

លំដាប់មកលោក យួន-ណៃ ប្រធានសមាគមគិលានសង្គ្រោះ បានថ្លែងសុន្ទរកថា រៀបរាប់អំពីព្រះរាជអំណោយដ៏ថ្លៃថ្លានៃសម្ដេចព្រះបិតាឯករាជ្យជាតិ អំពីរាជរដ្ឋាភិបាលដែលបានជួយឧបត្ថម្ភឲ្យមន្ទីរពេទ្យព្រះសង្ឃ អំពីការខ្វះខាតទឹកភ្លើងឱសថ អំពីឧបសគ្គផ្សេងៗជាដើម ។

កាលចប់សុន្ទរកថារបស់លោកយួន-ណៃ សម្ដេចព្រះបិតាឯករាជ្យជាតិ ទ្រង់មានព្រះបន្ទូលទៅកាន់រាជរដ្ឋាភិបាលឲ្យជួយឧបត្ថម្ភការខ្វះខាត និងសម្រួលកិច្ចការ ឲ្យសមាគមនេះមានវឌ្ឍនភាពតទៅ ។

រួចហើយសហជីវិន ក៉យ-លុត រដ្ឋមន្ត្រីក្រសួងធម្មការ បានថ្លែងសុន្ទរកថាទទួលអំណរព្រះគុណាធិគុណនៃសម្ដេចជាម្ចាស់ ដែលទ្រង់ផ្ញើព្រះរាជអំណោយរថយន្ត ចំពោះសមាគមគិលានសង្គ្រោះនេះនឹងទ្រង់ផ្ដល់បច្ច័យចំនួន ១០០០៛ ក្នុង ១ ខែ ដល់សមាគមនេះផង សម្រាប់ចាយរាយក្នុងការប្រើប្រាស់រថយន្តនេះតទៅ ថា ទាននេះត្រូវទុកជាព្រហ្មទានមួយដ៏ប្រសើរ ចំពោះព្រះពុទ្ធសាសនា ។

ក្រោយពីសហជីវិនក៉យ-លុត ថ្លែងសុន្ទរកថា សម្ដេចព្រះបិតាឯក-រាជ្យទ្រង់ស្ដេចយាងទតមន្ទីរពេទ្យព្រះសង្ឃ ទ្រង់មានព្រះបន្ទូលថា ទ្រង់នឹងព្យាយាមជួយទំនុកបម្រុងមន្ទីរពេទ្យនេះ តាមព្រះពលភាព ។

ម៉ោង ១៨ សម្ដេចព្រះឧបយុវរាជទ្រង់ស្ដេចត្រឡប់មកកាន់ព្រះបរមរាជវាំងវិញ ។

ពិធីនេះចប់នៅម៉ោង ១៨និង៣០ នាទី ដោយបរិយាកាសដ៏រីករាយ ។